សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droit et des Sciences Economiques

Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# ចំណាត់ការរបស់ចៅក្រមជំនុំជម្រះលើរឿងក្តីព្រហ្មទណ្ឌ

## ( សាលាដំបូង )

ស្រាវជ្រាវចាប់ពីថ្ងៃទី០២ ខែមេសា ឆ្នាំ២០១៨ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៨


តាក់តែងឡើងដោយ

និស្សិតឈ្មោះ លោក **សំ ម៉េងហ៊ាង**

លោក **អ៊ុំ សុធា**

សាស្ត្រាចារ្យណែនាំ

**លោក ហោ សុភ័ណ្ឌ**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ១៨

ឆ្នាំចូលសិក្សា ២០១៤

ឆ្នាំសរសេរសារណា ២០១៨

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំទាំងពីរនាក់ឈ្មោះ **សំ ម៉េងហ៊ាង** និង **អ៊ុំ សុធា** ជានិស្សិតបរិញ្ញាបត្រនីតិសាស្រ្តជំនាន់ទី ១៨ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច។

## សូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះ

លោកអ្នកមានគុណទាំងពីរផ្តល់កំណើត ដែលបានចិញ្ចឹមបីបាច់ថែរក្សាតាំងពីតូចរហូតដល់រូបកូនធំពេញវ័យព្រមទាំងផ្តល់ដំបូន្មានប្រៀនប្រដៅ និងបានទំនុកបម្រុងកូនឱ្យចូលសាលាដើម្បីក្រេបយកចំណេះដឹងតាំងពីបឋមសិក្សា រហូតដល់បញ្ចប់ថ្នាក់បរិញ្ញាបត្រនីតិសាស្រ្តនៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ព្រមទាំងជួយជ្រោមជ្រែងគ្រប់បែបយ៉ាងទាំងផ្នែកបញ្ញានិងស្មារតី។

**ឯកឧត្តមសាកលវិទ្យាធិការនៃសាកលវិទ្យាល័យ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស និង លោក លោកស្រីសាស្រ្តចារ្យនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តទាំងអស់** ដែលបានយកចិត្តទុកដាក់ និងចំណាយពេលវេលាដ៏មានតម្លៃរបស់លោក ដើម្បីបណ្តុះបណ្តាល ចែករំលែកចំនេះដឹងដែលលោកមាន ព្រមទាំងបទពិសោធន៍ផ្ទាល់ខ្លួនក្នុងសង្គម មកបង្ហាត់បង្រៀនយើងខ្ញុំ និងមិត្តរួមថ្នាក់ទាំងអស់គ្នា គ្រប់មុខវិជ្ជាតាំងពីថ្នាក់មូលដ្ឋានរហូតដល់បាន បញ្ចប់ការសិក្សា ។

ជាពិសេសសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ **លោកសាស្រ្តចារ្យ ហោ សុត្ថ័ណ្ណា** ដែលបានដឹកនាំក្នុងការសរសេរសារណាបញ្ចប់ការសិក្សារបស់យើងខ្ញុំ និងបានចំណាយពេលវេលាដ៏មានតម្លៃទាំងកម្លាំងកាយ កម្លាំងចិត្ត គំនិតប្រាជ្ញាស្មារតី ដើម្បីបណ្តុះបណ្តាល និងពន្យល់ណែនាំដើម្បី ឱ្យការចងក្រងសារណាមួយនេះទទួលបានជោគជ័យ។

ជាទីបញ្ចប់យើងខ្ញុំបាទសូមគោរពជូនពរ**លោកអ្នកមានគុណទាំងពីរ ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង លោក លោកស្រីសាស្ត្រាចារ្យទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច** សូមឲ្យសមប្រកបជួបប្រទះតែនឹងសេចក្តីសុខ សេចក្តីចំរើន សុខភាពល្អបរិបូរណ៍ ជន្មាយុយឺនយូរ មានកម្លាំងពលំខ្លាំងក្លា ប្រាជ្ញាស្មារតីចងចាំបានល្អ និងមានឲ្យមានសំណាងល្អគ្រប់ពេលវេលា ជាពិសេសសូមឲ្យទទួលបានជោគជ័យគ្រប់ភារកិច្ច ។

# អារម្ភកថា

ស្ថានប័នតុលាការ ជាស្ថានប័នមួយក្នុងចំណោមស្ថាប័នធំៗទាំង ៣ មានស្ថាប័ននីតិបញ្ញត្តិ ស្ថាប័ននីតិប្រតិបត្តិ និងស្ថាប័នតុលាការ ។ ស្ថាប័នតុលាការគឺស្ថាប័នកំពូលមួយដែលមានចែងក្នុងរដ្ឋធម្មនុញ្ញកម្ពុជាឆ្នាំ១៩៩៣ ដែលជាស្ថាប័នទទួលបន្ទុកក្នុងការជំនុំជម្រះវិនិច្ឆ័យសេចក្ដីតាមកំណត់ច្បាប់។ យ៉ាងណាមិញ យើងខ្ញុំសូមលើកយកតែ " **ចំណាត់ការរបស់ចៅក្រមជំនុំជម្រះលើរឿងព្រហ្មទណ្ឌ (សាលាដំបូង)** " ដើម្បីចងក្រងជាសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ។ ក្រោយពីបានសិក្សាលើមុខជំនាញផ្នែកនីតិសាស្ត្រអស់រយៈពេល ៤ ឆ្នាំ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច បានធ្វើឱ្យយើងខ្ញុំទទួលបានពុទ្ធិ គុណវុឌ្ឍិ និងអាចយកទៅប្រើជាប្រយោជន៍ ក្នុងសង្គម ។ ក្រោយពីបានសិក្សាលើទ្រឹស្ដីផ្នែកច្បាប់នីតិវិធីព្រហ្មទណ្ឌកន្លងមកនេះ ជាសញ្ញាណមួយ ជម្រុញឱ្យយើងខ្ញុំសម្រេចចិត្តក្នុងការជ្រើសរើសប្រធានចងក្រងទាក់ទងនឹងនីតិវិធីព្រហ្មទណ្ឌ ក្នុងការសរសេរសារណាដើម្បីបញ្ចប់ឆ្នាំសិក្សាបរិញ្ញាបត្រក្រោមប្រធានបទ "**ចំណាត់ការរបស់ចៅ-ក្រមជំនុំជម្រះលើរឿងព្រហ្មទណ្ឌ (សាលាដំបូង)**"។ ក្នុងការជ្រើសរើសប្រធានបទនេះផងដែរ គឺជាកត្តាមួយដែលធ្វើឱ្យយើងបានសិក្សាស្រាវជ្រាវយល់បានច្បាស់អំពីប្រធានបទនេះផងដែរ។

ក្នុងការសម្រេចចិត្តក្នុងការចងក្រងសារណានេះឡើងក្នុងគោលបំណងសម្រាប់ជាគន្លឹះ ឬជំនួយស្មារតីក្នុងវិស័យច្បាប់ និងជាការចងក្រងទុកជាឯកសារដើម្បីជាប្រយោជន៍ដល់អ្នកសិក្សាជំនាញផ្នែកនីតិសាស្ត្រក្នុងការស្រាវជ្រាវ ដើម្បីធ្វើការសិក្សាស្វែងយល់ឱ្យបានច្បាស់លាស់ អំពីចំណាត់ការរបស់ចៅក្រមជំនុំជម្រះលើរឿងក្ដីព្រហ្មទណ្ឌសម្រាប់ដល់និស្សិតគ្រប់រូបផងដែរ។

ទន្ទឹមនឹងនោះ ចំពោះការតាក់តែងចងក្រងសារណានេះឡើងគឺជៀសមិនផុតអំពីភាពខ្វះចន្លោះទាំងផ្នែកអត្ថន័យខ្លឹមសារ និង ពាក្យពេជន៍ អក្ខរាវិរុទ្ធដែលមាននៅក្នុងសារណាមួយនេះ។

ដូចនេះ យើងខ្ញុំនឹងរងចាំទទួលការរិះគន់ក្នុងន័យស្ថាបនាគ្រប់ពេលវេលា រាល់ភាពខ្វះចន្លោះទាំងឡាយណាដែលមាននៅក្នុងសារណាមួយនេះ ពីសំណាក់លោក លោកស្រី សាស្ត្រាចារ្យ និងបណ្ឌាអ្នកច្បាប់ផងនោះ។

# មាតិកា

**ទំព័រ**

**សេចក្តីផ្តើម** ..... ១

**ជំពូកទី១ ៖**

**សញ្ញាណទូទៅនៃការជំនុំជម្រះ**

**ផ្នែកទី១៖ សមត្ថកិច្ចរបស់សាលាដំបូង** ..... ៣

**កថាខណ្ឌទី១ ៖ សមត្ថកិច្ចដែនដី** ..... ៣

១.១ សមត្ថកិច្ចនាទីកន្លែងបទល្មើស ..... ៣

១.២ សមត្ថកិច្ចនាលំនៅឋានរបស់ជនជាប់ចោទ ..... ៤

១.៣ សមត្ថកិច្ចនាទីកន្លែងចាប់ខ្លួនជនជាប់ចោទ ..... ៤

**កថាខណ្ឌទី២៖ សមត្ថកិច្ចសម្ភារៈ** ..... ៥

២.១ សមត្ថកិច្ចរបស់ចៅក្រមជំនុំជម្រះ ..... ៥

២.២ សមត្ថកិច្ចទៅលើបណ្តឹង ..... ៥

២.៣ សមត្ថកិច្ចលើអង្គហេតុ និង សមត្ថកិច្ចលើបុគ្គល ..... ៥

**ផ្នែកទី២ ៖ របៀបប្តឹងទៅកាន់តុលាការ** ..... ៦

**កថាខណ្ឌទី១ ៖ ការបញ្ជូនសំណុំរឿងទៅជំនុំជម្រះផ្ទាល់របស់ព្រះរាជអាជ្ញា** ..... ៦

១.១ លក្ខខណ្ឌនៃការបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ ..... ៦

១.២ នីតិវិធីនៃការបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ ..... ៧

**កថាខណ្ឌទី២៖ ការចូលបង្ហាញខ្លួនភ្លាមដែលធ្វើដោយព្រះរាជអាជ្ញា** ..... ៧

២.១ លក្ខខណ្ឌនៃការបង្ហាញខ្លួនភ្លាមនៅចំពោះតុលាការជាន់ដំបូង ..... ៧

២.២ នីតិវិធីនៃការបង្ហាញខ្លួនភ្លាម ..... ៨

**កថាខណ្ឌទី៣៖ ដីកាបញ្ជូនរបស់ចៅក្រមស៊ើបសួរ ឬ សាលដីកាបញ្ជូនរបស់សភាស៊ើបសួរ** ..... ៨

៣.១ ដីកាបញ្ជូនរបស់ចៅក្រមស៊ើបសួរ ..... ៨

៣.២ ការបញ្ជូនរឿងទៅជំនុំជម្រះរបស់សភាស៊ើបសួរ ..... ៩

**ផ្នែកទី៣៖ ការកោះហៅគូភាគីឲ្យចូលសវនាការ** ..... ៩

**កថាខណ្ឌទី១៖ ការកោះហៅជនជាប់ចោទឲ្យចូលសវនាការ** ..... ១០

១.១ ការកោះហៅជនជាប់ចោទតាមដីកាបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ ..... ១០

១.២ ការកោះហៅជនជាប់ចោទតាមកំណត់ហេតុស្ដីពីការបង្ហាញខ្លួនភ្លាម ........ ១១
១.៣ ការកោះហៅតាមដីកាបញ្ជូនរបស់ចៅក្រមស៊ើបសួរ ឬសាលដីបញ្ជូនរបស់សភាស៊ើបសួរ ........ ១១
**កថាខណ្ឌទី២ ការកោះហៅបុគ្គលពាក់ព័ន្ធក្រៅពីជនជាប់ចោទឲ្យចូលសវនាការ ........ ១២**
២.១ បុគ្គលដែលត្រូវកោះហៅឲ្យចូលសវនាការ ........ ១២
២.២ រយៈពេលដែលត្រូវគោរពសម្រាប់ការកោះហៅបុគ្គលពាក់ព័ន្ធ ........ ១៣
២.៣ នីតិវិធីនៃការប្រគល់ដីកាកោះ ........ ១៣

## ជំពូកទី២៖
## កិច្ចដំណើរការនីតិវិធីជំនុំជម្រះ

**ផ្នែកទី១ ដំណាក់កាលមុនប្រកាសបើកសវនាការ ........ ១៤**
**កថាខណ្ឌទី១ ការចូលខ្លួនរបស់ភាគី ........ ១៤**
១.១ ការចូលខ្លួនរបស់ជនជាប់ចោទ ........ ១៤
១.២ ការចូលខ្លួនរបស់ភាគីក្រៅពីជនជាប់ចោទ ........ ១៥
**កថាខណ្ឌទី២ ការដឹកនាំសម្បថ ........ ១៦**
២.១ បុគ្គលដែលត្រូវធ្វើសម្បថ ........ ១៦
២.២ នីតិវិធីនៃការធ្វើសម្បថ ........ ១៧
**ផ្នែកទី២ លំដាប់លំដោយនៃនីតិវិធីជំនុំជម្រះ ........ ១៧**
**កថាខណ្ឌទី១ ការប្រកាសបើកសវនាការ ........ ១៧**
១.១ សវនាការជាសាធារណៈ ........ ១៧
១.២ នីតិវិធីនៃការប្រកាសបើកសវនាការ ........ ១៧
**កថាខណ្ឌទី២ កិច្ចពិភាក្សាដេញដោល ........ ១៨**
២.១ ការសួរនិងស្ដាប់ចម្លើយ ........ ១៩
២.២ ការពិនិត្យវត្ថុតាង ........ ២១
២.៣ សិទ្ធិនិយាយស្ដីរបស់ភាគីក្រោយបញ្ចប់កិច្ចពិភាក្សាដេញដោល ........ ២១
**កថាខណ្ឌទី៣ ការប្រកាសថយទៅពិភាក្សា ........ ២២**
៣.១ ការពិភាក្សាសម្រេចរបស់តុលាការ ........ ២២
៣.២ អានុភាពនៃការថយខ្លួនដើម្បីពិភាក្សាសម្រេច ........ ២៣

## ជំពូកទី៣ ៖
# សាលក្រម

**ផ្នែកទី១ ការតាក់តែងសាលក្រម** ........ ២៤
កថាខណ្ឌទី១ ក្បាលសាលក្រម ........ ២៤
១.១ សំអាងហេតុ ........ ២៥
១.២ ផ្នែកសម្រេចនៃសាលក្រម ........ ២៦
**ផ្នែកទី២ ប្រភេទសាលក្រម** ........ ២៧
កថាខណ្ឌទី១ សាលក្រមលើអង្គសេចក្ដី ........ ២៧
១.១ សាលក្រមកំបាំងមុខ ........ ២៧
១.២ សាលក្រមដែលត្រូវចាត់ទុកថាចំពោះមុខ ........ ២៩
១.៣ សាលក្រមចំពោះមុខ ........ ៣០
កថាខណ្ឌទី២ សាលក្រមនីតិវិធី ........ ៣១
២.១ សាលក្រមមុនអង្គសេចក្ដី ........ ៣១
២.២ សាលក្រមចាត់របៀប ........ ៣២
**សេចក្ដីសន្និដ្ឋាន** ........ ៣៤
**អនុសាសន៍** ........ ៣៥
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

## ១.លំនាំបញ្ហា

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលព្រះមហាក្សត្របានឡាយព្រះហស្ថលេខាដាក់ឲ្យប្រើប្រាស់កាលពីថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ គឺជាច្បាប់កំពូលមួយរបស់រដ្ឋ ដែលមានបញ្ញត្តិអំពីស្ថាប័នធម្មនុញ្ញ និងបានធ្វើការបែងចែកអំណាចនៃការគ្រប់គ្រងរដ្ឋតាមបែបលទ្ធិប្រជាធិបតេយ្យគឺ អំណាចនីតិបញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ។ ទន្ទឹមនឹងនោះ យើងដឹងហើយថា តាមស្ថាប័ននីមួយៗខាងលើគឺមាន ភារកិច្ច និង តួនាទីផ្សេងៗគ្នាដើម្បីធានាកុំឲ្យមានភាពរំលោភអំណាចគ្នាទៅវិញទៅមក។ យ៉ាងណាមិញចំពោះ ស្ថាប័នតុលាការគឺជា អង្គដ៏សំខាន់មួយដែលជាអ្នកធានានូវការអនុវត្តច្បាប់ និងធ្វើការដាក់ទណ្ឌកម្មចំពោះជនទាំងឡាយណាដែលល្មើសនឹងបញ្ញត្តិច្បាប់ តាមរយៈការសម្រេចសេចក្តីដោយសម្អាងលើបទបញ្ញប្បត្តិច្បាប់ដែលនូវជាធរមាន។ លើសពីនេះទៅទៀត ដើម្បីធានាបាននូវការការពារដល់សិទ្ធិ និងសេចក្តីថ្លៃថ្នូររបស់មនុស្សមុននឹងសន្មត់ថាជនណាមួយមានទោសលុះត្រាតែត្រូវបានតុលាការចេញសាលក្រម ឬសាលដីកាបញ្ជាក់អំពីពិរុទ្ធភាពទៅលើជននោះ ។ ប៉ុន្តែមុននឹងឈានដល់ការចេញសេចក្តីសម្រេច។ យើងឃើញថាត្រូវឆ្លងកាត់នូវកិច្ចនីតិវិធីជាច្រើនដំណាក់កាលដែលមានបញ្ញត្តិនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ ដូចជា ដំណាក់មន្ត្រីនគរបាលយុត្តិធម៌ ដំណាក់កាលអយ្យការ ដំណាក់កាលស៊ើបសួរ និងដំណាក់កាលជំនុំជម្រះជាដើម។

ចំពោះដំណាក់កាលទាំងបួនខាងលើ យើងខ្ញុំបានជ្រើសរើសយកដំណាក់កាលជំនុំជម្រះយកមកធ្វើជាប្រធានបទសារណាដើម្បីបកស្រាយ ក្នុងគោលបំណងបង្ហាញឲ្យឃើញពីភាពសំខាន់ចាំបាច់អំពីនីតិវិធីនៅក្នុងដំណាក់កាលជំនុំជម្រះ ដោយបង្ហាញឲ្យឃើញពីអត្ថិភាព ឬនត្ថិភាពនៃបទល្មើស។

## ២.ចំណោទបញ្ហានៃការស្រាវជ្រាវ

ដើម្បីយល់កាន់តែច្បាស់នូវប្រធានបទសារណាដែលបានលើកឡើងខាងលើ យើងបានចោទជាចំណោទគត្តិយុត្តមួយចំនួនដូចជា ក្នុងករណីដែលសំណុំរឿងព្រហ្មទណ្ឌត្រូវបានបញ្ជូនដល់ដំណាក់កាលជំនុំជម្រះហើយនោះ តើចៅក្រមជំនុំជម្រះមានសិទ្ធិអំណាច និងភារកិច្ចយ៉ាងណាខ្លះដើម្បី ចំណាត់ការរឿងក្តីព្រហ្មទណ្ឌ? តើចៅក្រមជំនុំជម្រះមានចំណាត់ការនីតិវិធីយ៉ាងណាដើម្បីស្វែងរកឲ្យឃើញពី អត្ថិភាព ឬនត្ថិភាពនៃបទល្មើស?

## ៣.គោលបំណងនៃការស្រាវជ្រាវ

ការតាក់តែងនូវសារណា ដែលមានប្រធានបទស្តីអំពី **ចំណាត់ការរបស់ចៅក្រមជំនុំជម្រះលើរឿងក្តីព្រហ្មទណ្ឌនៅដំណាក់កាលសាលាដំបូង** នេះឡើង គឺមានបំណងចង់ឆ្លុះបញ្ចាំងឲ្យយល់ច្បាស់

ពីស្ថាប័នតុលាការ ជាពិសេសជាងនេះគឺកិច្ចដំណើរការរឿងក្ដីនៅដំណាក់ជំនុំជម្រះដែលជាដំណាក់កាលចុងក្រោយនៃសាលាដំបូង។

## ៤.ដែនកំណត់នៃការស្រាវជ្រាវ និងវិធីសាស្ត្រនៃការស្វែងរកឯកសារ

ចំពោះដែនកំណត់នៃការស្រាវជ្រាវអំពីប្រធានបទនៃសារណានេះ គឺយើងបានធ្វើការសិក្សាស្រាវជ្រាវត្រឹមតែដំណាក់កាលជំនុំជម្រះតែប៉ុណ្ណោះ។ ដោយហេតុថា ប្រធានបទគឺផ្ដោតសំខាន់អំពីកិច្ចនីតិវិធីនៅក្នុងដំណាក់ជំនុំជម្រះលើរឿងក្ដីព្រហ្មទណ្ឌនៅសាលាដំបូង។

ទន្ទឹមនឹងការសិក្សាស្រាវជ្រាវអំពីប្រធានបទខាងលើនេះ យើងខ្ញុំបានធ្វើការសិក្សាស្រាវជ្រាវលើលិខិតបទដ្ឋានគតិយុត្តមួយចំនួនដូចជា រដ្ឋធម្មនុញ្ញកម្ពុជាឆ្នាំ១៩៩៣ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ ជាឯកសារគោល ព្រមទាំងឯកសារច្បាប់ និងឯកសារជំនួយស្មារតីមួយចំនួនទៀតដែលពាក់ព័ន្ធជាមួយប្រធានបទ។

## ៥. សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ

ការដែលជ្រើសរើសប្រធានបទខាងលើនេះ មកធ្វើការសិក្សាស្រាវជ្រាវពិតជាមានសារៈសំខាន់ណាស់ចំពោះបណ្ដាអ្នកច្បាប់ និងនិស្សិតនាមហាវិទ្យាល័យនីតិសាស្ត្រជាដើម គឺបានផ្ដល់នូវឯកសារជាជំនួយស្មារតីឲ្យមានការស្វែងយល់ឲ្យបានច្បាស់លាស់ អំពីកិច្ចនីតិវិធីនៃដំណើរការរឿងក្ដីនៃនីតិវិធីជំនុំជម្រះលើរឿងក្ដីព្រហ្មទណ្ឌនាតាមសាលាដំបូងរាជធានីខេត្តនាពេលបច្ចុប្បន្ន។ ទន្ទឹមនឹងនោះ អាចស្វែងយល់អំពីភាពបត់បែននៃកិច្ចនីតិវិធីរបស់ចៅក្រមជំនុំជម្រះ ដែលផ្លាស់ប្ដូរទៅតាមបរិបទនៃប្រភេទរឿងក្ដីនីមួយៗ។

## ៦.រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ដើម្បីធ្វើការឆ្លើយតបទៅនឹងចំណោទគតិយុត្តខាងលើយើងបានធ្វើការបែងចែកនិងរៀបរាប់អំពីដំណាក់កាលនីមួយៗឲ្យបានច្បាស់លាស់ ជំពូកទី១ សញ្ញាណទូទៅនៃការជំនុំជម្រះ ជំពូកទី២ កិច្ចដំណើរការនៃនីតិវិធីជំនុំជម្រះ និងជំពូកទី៣ ការប្រកាសសាលក្រម។

ដោយជំពូកនីមួយៗនឹងមានការបកស្រាយយ៉ាងលម្អិតនៅទំព័របន្ទាប់

# ជំពូកទី១ ៖
# សញ្ញាណទូទៅនៃការជំនុំជម្រះ

ចំពោះរឿងក្ដីព្រហ្មទណ្ឌ ការជំនុំជម្រះអាចធ្វើទៅបានលុះត្រាតែមានការបញ្ជូនសំណុំរឿងជូនយុត្តាធិការជំនុំជម្រះតាមរយៈរបៀបប្ដឹងមកតុលាការ។ ទន្ទឹមនឹងនោះ ដើម្បីឱ្យយុត្តាធិការជំនុំជម្រះ អាចបន្តចំណាត់ការលើសំណុំរឿងព្រហ្មទណ្ឌបាន។ ជំហានដំបូង ប្រធានសាលាដំបូងគប្បីពិនិត្យមើល អំពីសមត្ថកិច្ចរបស់សាលាដំបូងជាមុនសិន ថាតើចំពោះសំណុំរឿងដែលខ្លួនត្រូវបន្តចំណាត់ការនោះស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួនដែរឬទេ?

## ផ្នែកទី១៖ សមត្ថកិច្ចរបស់សាលាដំបូង

សាលាដំបូងមានសមត្ថកិច្ចជំនុំជម្រះទៅលើរឿងក្ដីដែលស្ថិតនៅក្នុងដែនដីរបស់ខ្លួន លើកលែងតែរឿងក្ដីទាំងឡាយណាដែលច្បាប់ប្រគល់ទៅសាលាជម្រះក្ដីផ្សេងទៀត។

ចំពោះចំណាត់ការលើរឿងក្ដីព្រហ្មទណ្ឌ ច្បាប់តែងតែធ្វើការកំណត់អំពីដែនសមត្ថកិច្ចរបស់សាលាដំបូង។ ទន្ទឹមនឹងនោះ នៅតាមទីប្រជុំជននៃខេត្ត ឬក្រុងនីមួយៗ មានតុលាការជាន់ដំបូងមួយដែលមានសមត្ថកិច្ចលាតសន្ធឹងលើដែនដីខេត្ត ឬក្រុងទាំងមូល ហៅថា សាលាដំបូង[1]។ យ៉ាងណាមិញ សមត្ថកិច្ចរបស់សាលាដំបូង គឺត្រូវបានបែងចែកទៅតាមប្រភេទនឹងមុខងារខុសៗគ្នា សមត្ថកិច្ចសម្ភារៈ និង សមត្ថកិច្ចដែនដី ។

### កថាខណ្ឌទី១ ៖ សមត្ថកិច្ចដែនដី

នៅពេលមានបទល្មើសព្រហ្មទណ្ឌមួយបានកើតឡើង ដើម្បីបញ្ជូនរឿងនោះទៅជំនុំជម្រះបាន គឺគប្បីពិនិត្យអំពីសមត្ថកិច្ចរបស់សាលាដំបូងនីមួយៗជាមុនសិន។ ជាក់ស្ដែង តុលាការដែលមានសមត្ថកិច្ចជំនុំជម្រះលើរឿងក្ដីព្រហ្មទណ្ឌគឺ តុលាការនាទីកន្លែងបទល្មើស តុលាការនាលំនៅឋានរបស់ជនជាប់ចោទ ឬតុលាការនាទីកន្លែងចាប់ខ្លួនជនជាប់ចោទ[2]។

#### ១.១ សមត្ថកិច្ចនាទីកន្លែងបទល្មើស

តុលាការនាទីកន្លែងបទល្មើស គឺសំដៅដល់តុលាការដែលមានសមត្ថកិច្ចនាទីកន្លែងដែលបទល្មើសបានកើតឡើង។ ឧទាហរណ៍ៈកាលពីថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ ២០១៦ លោក ក និង បក្សពួករបស់ខ្លួនបានធ្វើសកម្មភាពឆក់កាបូបនារីម្នាក់ដែលកំពុងជិះម៉ូតូស្របទិសគ្នាបានសម្រេច ដែលស្ថិតនៅសង្កាត់ផ្សារដេប៉ូទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ។ ដូចនេះតុលាការដែលមានសមត្ថកិច្ច គឺសាលាដំបូងរាជធានីភ្នំពេញ។

[1] មាត្រា២៨៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

[2] មាត្រា ២៩០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

## ១.២ សមត្ថកិច្ចនាលំនៅឋានរបស់ជនជាប់ចោទ

តុលាការនាលំនៅឋានរបស់ជនជាប់ចោទ គឺសំដៅដល់សាលាដំបូងដែលមានសមត្ថកិច្ចជំនុំជម្រះ ចំពោះទីតាំងដែលលំនៅឋានរបស់ជនជាប់ចោទស្ថិតនៅ។ ឧទាហរណ៍៖ ចំពោះអង្គហេតុនៃចំណុច ក ខាងលើ ដែលមានជនជាប់ឈ្មោះ ក និងបក្សពួក។ ដោយជនជាប់ចោទឈ្មោះ ក និងបក្សពួកមានទីលំនៅស្ថិតនៅខេត្តកណ្តាល ។ ដូចនេះ តុលាការខេត្តកណ្តាល ក៏មានសមត្ថកិច្ចដែនដីលើរឿងក្តីនោះផងដែរ។

## ១.៣ សមត្ថកិច្ចនាទីកន្លែងចាប់ខ្លួនជនជាប់ចោទ

តុលាការនាទីកន្លែងចាប់ខ្លួនជនជាប់ចោទ គឺសំដៅដល់ដែនសមត្ថកិច្ចដែនដីរបស់សាលាដំបូងដែលបានចាប់ខ្លួនជនជាប់ចោទ។ ឧទាហរណ៍៖ ករណីដែល លោក ក និងបក្សពួករបស់ខ្លួនបានធ្វើសកម្មភាពឆក់រួចមក ក៏ត្រូវបានប៉ូលីសដេញតាមចាប់រហូតចូលដល់ដែនដីដែលសមត្ថកិច្ចរបស់សាលាដំបូងខេត្តកំពង់ស្ពឺ។ ដូចនេះ តុលាការដែលមានសមត្ថកិច្ចក្នុងការចំណាត់ការចំពោះបទល្មើសព្រហ្មទណ្ឌក៏ជាសាលាដំបូងខេត្តកំពង់ស្ពឺផងដែរ។

យ៉ាងណាមិញ ក្នុងករណីតុលាការច្រើនដែលស្ថិតក្រោមសមត្ថកិច្ចដែនដីរបស់សាលាឧទ្ធរណ៍តែមួយ ហើយបានទទួលពាក្យបណ្តឹងលើរឿងក្តីតែមួយដូចគ្នានោះ។ ប្រធានសាលាឧទ្ធរណ៍ជាអ្នកកំណត់អំពីតុលាការដែលមានសមត្ថកិច្ចទទួលចាត់ការលើពាក្យបណ្តឹងដែលបានដាក់នោះ ដោយឆន្ទានុសិទ្ធិរបស់ខ្លួនបាន។

មួយវិញទៀត បើសិនជាមានវិវាទសមត្ថកិច្ចដែនដី រវាងតុលាការច្រើនដែលមានថ្នាក់ស្មើគ្នានោះ។ ការសម្រេចអំពីតុលាការមានសមត្ថកិច្ច គឺត្រូវបានផ្តល់សិទ្ធិទៅឲ្យតុលាការជាន់ខ្ពស់ ដោយសេចក្តីសម្រេចនេះ ជាសេចក្តីសម្រេចបិទផ្លូវតវ៉ាផងដែរ។

ទន្ទឹមនឹងនោះ អានុភាពនៃការកំណត់អំពីសមត្ថកិច្ចដែនដីនេះគឺអាចបន្លាយទៅដល់លំនៅដ្ឋានរបស់សហចារី អ្នកផ្តើមគំនិត និងអ្នកសមគំនិតទាំងអស់ផងដែរ។

ក្នុងករណីដែលតុលាការបានទទួលពាក្យបណ្តឹងយល់ឃើញថាសំណុំរឿងនេះមិនស្ថិតក្នុងដែនសមត្ថកិច្ចដែនដីរបស់ខ្លួនទេ ដូចនេះតុលាការត្រូវប្រកាសអំពីភាពអសមត្ថកិច្ចដោយសាលក្រម និងត្រូវបង្គាប់ឲ្យបង្វិលសំណុំរឿងនេះជូនព្រះរាជអាជ្ញាវិញ ដើម្បីឲ្យព្រះរាជអាជ្ញាធ្វើការបញ្ជូនសំណុំរឿងនេះជូនដល់តុលាការដែលមានសមត្ថកិច្ចដែនដី។ជាយថាហេតុ តុលាការនេះត្រូវសម្រេចសេចក្តីលើការបន្តដាក់ជនជាប់ចោទឱ្យស្ថិតក្នុងការឃុំខ្លួន ឬការពាគ្រួតពិនិត្យតាមផ្លូវតុលាការ[3]។

[3] មាត្រា២៩០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

## កថាខណ្ឌទី២៖ សមត្ថកិច្ចសម្ភារៈ

សមត្ថកិច្ចសម្ភារៈ គឺសំដៅលើប្រភេទនៃសមត្ថកិច្ចរបស់សាលាដំបូងដែលមានយុត្តាធិការជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌដែលទទួលបាន។ ទន្ទឹមនឹងនោះ ចំពោះសមត្ថកិច្ចសម្ភារៈយើងអាចបែងចែកជាប្រភេទដូចខាងក្រោម៖

### ២.១ សមត្ថកិច្ចរបស់ចៅក្រមជំនុំជម្រះ

និយមន័យ ចៅក្រមជំនុំជម្រះ មានន័យថា ចៅក្រមទាំងឡាយត្រូវសម្រេចសេចក្តីដោយមិនលម្អៀង ដោយ ឈរលើគោលការណ៍គោរពច្បាប់ ដោយមិនទទួលការគាបសង្កត់ ការគំរាមកំហែង ឬការបំភិតបំភ័យ ការបង្គាប់បញ្ជាដោយផ្ទាល់ ឬដោយប្រយោលពីភាគីណាមួយក្នុងរឿងក្តី ឬពីបុគ្គលណាមួយឡើយ[4]។

នៅក្នុងជំនុំជម្រះលើបទល្មើសព្រហ្មទណ្ឌ សាលាដំបូងមានសមត្ថកិច្ចជំនុំជម្រះចំពោះបទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុ ។ សម្រេចជាក្រុមសមូហភាពដែលមានចៅក្រម ៣ (បី) រូប ចំពោះបទឧក្រិដ្ឋ ព្រមទាំងបទមជ្ឈិម និង បទលហុដែលជាប់ទាក់ទង ។ ប៉ុន្តែបើសិនជាជំនុំជម្រះបទមជ្ឈិម និងបទលហុវិញ សាលាដំបូងត្រូវសម្រេចដោយចៅក្រមទោល[5]។

### ២.២ សមត្ថកិច្ចនៅលើបណ្តឹង

ក្នុងរឿងក្តីព្រហ្មទណ្ឌ តុលាការបើកការជំនុំជម្រះបាន លុះត្រាតែសាលាដំបូងបានទទួលបណ្តឹងតាមរយៈដីកាបញ្ជូនរបស់ចៅក្រមស៊ើបសួរ ឬសាលដីកាបស់សភាស៊ើបសួរ ដីកាបញ្ជូនទៅតុលាការដើម្បីជំនុំជម្រះដោយផ្ទាល់ពរបស់ព្រះរាជអាជ្ញា និងតាមរយៈកំណត់ហេតុស្តីពីការចូលបង្ហាញ ខ្លួនភ្លាមដែលធ្វើឡើងដោយព្រះរាជអាជ្ញា[6]។

### ២.៣ សមត្ថកិច្ចលើអង្គហេតុ និង សមត្ថកិច្ចលើបុគ្គល

#### ២.៣.១ សមត្ថកិច្ចលើអង្គហេតុ

សមត្ថកិច្ចលើអង្គហេតុនេះ មានន័យថា តុលាការអាចធ្វើការសម្រេចបានទៅលើតែចំពោះអំពើទាំងឡាយណា ដែលមានបង្ហាញនៅក្នុងសាលដីកាបញ្ជូនរបស់សភាស៊ើបសួរ ឬ ដីកាបញ្ជូនទៅជំនុំជម្រះរបស់ចៅក្រមស៊ើបសួរ ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ ឬកំណត់ហេតុនៃការបង្ហាញខ្លួនភ្លាមប៉ុណ្ណោះ។ ដូចនេះ ក្នុងករណីដែលតុលាការធ្វើការជំនុំជម្រះជាក្រុម ហើយយល់ឃើញថាអង្គហេតុដែលត្រូវបានប្តឹងនោះ បង្កើតបានជាបទមជ្ឈិម ឬបទលហុ តុលាការនោះនៅតែមានសមត្ថកិច្ចដើម្បីជំនុំជម្រះសេចក្តីដដែល។ ប៉ុន្តែបើសិនជា តុលាការដែលសម្រេចសេចក្តីដោយចៅក្រមទោល ហើយយល់ឃើញថាមានអង្គហេតុបង្កើតបានជាបទឧក្រិដ្ឋ តុលាការត្រូវបង្វិលសំណុំ

[4] មាត្រា ៨នៃច្បាប់ស្តីពី លក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៤

[5] មាត្រា២៨៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ខែសីហា ឆ្នាំ២០០៧

[6] មាត្រា២៩១ កថាខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ខែសីហា ឆ្នាំ២០០៧

រឿងនោះជូនព្រះរាជអាជ្ញាដើម្បីឲ្យចៅក្រមស៊ើបសួរបើកការស៊ើបសួរ តាមរយៈការចេញដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ[7]។

### ២.៣.២ សមត្ថកិច្ចលើបុគ្គល

តុលាការ អាចបើកការជំនុំជម្រះបានចំពោះតែបុគ្គលដែលត្រូវបានកោះហៅឲ្យចូលខ្លួនទៅចំពោះមុខ ខ្លួនក្នុងឋានៈជាជនជាប់ចោទតែប៉ុណ្ណោះ។ ចំណុចនេះមានន័យថា បុគ្គលដែលចូលទៅកាន់តុលាការត្រូវតែមានឋានៈជាជនជាប់ចោទ ទើបតុលាការអាចធ្វើការសម្រេចសេចក្តីទៅលើជននោះបាន។ មួយវិញទៀត ទោះបីជនផ្សេងទៀតដែលបានចូលរួមប្រព្រឹត្តបទល្មើសជាមួយជនជាប់ចោទនោះក៏ដោយ ប៉ុន្តែតុលាកាបែរជាធ្វើការកោះហៅក្នុងឋានៈជាសាក្សី ដើម្បីចូលរួមឆ្លើយបំភ្លឺអំពីហេតុការណ៍ដែលខ្លួនបានដឹងវិញនោះ។ តុលាការមិនអាចធ្វើការសម្រេចសេក្តីលើជននោះបានទេ លើកលែងតែនៅពេលដែលតុលាការធ្វើការសាកសួរចម្លើយ ហើយតុលាការអាចកំណត់ឬរកឃើញថាជននោះក៏ជាអ្នកចូលរួមប្រព្រឹត្ត បទល្មើសផងដែរទោះបីជាក្នុងឋានៈជាជនដៃដល់ ឬអ្នកសមគំនិតបុគ្គលនោះនឹងត្រូវតុលាការធ្វើការជំនុំជម្រះបាន បន្ទាប់ពីត្រូវបានចោទប្រកាន់ដោយព្រះរាជអាជ្ញាតាមរយៈមាត្រា ៨៣ ស្តីពីការចោទប្រកាន់ នៃក្រមនីតិវិធីព្រហ្មទណ្ឌ[8]។

## ផ្នែកទី២ ៖ របៀបប្តឹងទៅកាន់តុលាការ

ដូចដែលបានធ្វើការរៀបរាប់នៅផ្នែកទី១ខាងលើនេះរួចមកហើយគ្រង់ (**ចំណុច.ខ. សមត្ថកិច្ចលើបណ្តឹង**) តុលាការអាចធ្វើការជំនុំជម្រះបានលុះត្រាតែបានទទួលបណ្តឹង។ ដូចនេះ បណ្តឹងដែលទទួលបានគឺមានបីប្រភេទដូចជា តាមរយៈដីកាបញ្ជូនរបស់ចៅក្រមស៊ើបសួរ ឬសាលដីកាបញ្ជូនរបស់សភាស៊ើបសួរ ដីកាបញ្ជូនទៅតុលាកាជំនុំជម្រះដោយផ្ទាល់ដោយព្រះរាជអាជ្ញា និងតាមរយៈកំណត់ ហេតុស្តីពីការចូលបង្ហាញខ្លួនភ្លាមដែលធ្វើដោយព្រះរាជអាជ្ញា[9]។

### កថាខណ្ឌទី១ ៖ ការបញ្ជូនសំណុំរឿងទៅជំនុំជម្រះផ្ទាល់របស់ព្រះរាជអាជ្ញា

ការបញ្ជូនសំណុំរឿងទៅជំនុំជម្រះផ្ទាល់នេះ គឺជាជម្រើសនៃការចោទប្រកាន់របស់ព្រះរាជអាជ្ញាចំពោះបទល្មើសព្រហ្មទណ្ឌ[10]។ ការបញ្ជូនសំណុំរឿងទៅជំនុំជម្រះផ្ទាល់របស់ព្រះរាជអាជ្ញាត្រូវធ្វើឡើងតាមរយៈការចេញដីកាបញ្ជូនទៅជំនុំជម្រះដោយផ្ទាល់របស់ព្រះរាជអាជ្ញា។

### ១.១ លក្ខខណ្ឌនៃការបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់

ព្រះរាជអាជ្ញាអាចបញ្ជូនជនជាប់ចោទទៅជំនុំជម្រះផ្ទាល់នៅចំពោះមុខសាលាដំបូងបាន។ ប្រសិនបើគ្រប់លក្ខខណ្ឌដូចខាងក្រោម៖

---

[7] មាត្រា៣៤៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

[8] មាត្រា៣៤៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

[9] មាត្រា ២៩១ កថាខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

[10] មាត្រា៤៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

- ជនជាប់ចោទជានីតិជន ឬជនជាប់ចោទជាអនីតិជនលើសពី១៤ (ដប់បួន)ឆ្នាំ
- បទល្មើសជាបទលហុ ឬបទមជ្ឈិម
- រឿងក្តីសមល្មមដែលអាចជំនុំជម្រះបាន

### ១.២ នីតិវិធីនៃការបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់

បន្ទាប់ពីព្រះរាជអាជ្ញា សម្រេចបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ដោយបានពិនិត្យមើលថាបទល្មើសនោះបានបំពេញលក្ខខណ្ឌដែលបានរៀបរាប់ខាងលើរួចហើយនោះ។ ព្រះរាជអាជ្ញាត្រូវបញ្ជាឲ្យជនជាប់ចោទចូលទៅបង្ហាញខ្លួននៅមុខតុលាការជាន់ដំបូង។ ទន្ទឹមនឹងនោះ នៅក្នុងដីកាកោះហៅបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ត្រូវសរសេរឲ្យបានច្បាស់លាស់នូវ អត្តសញ្ញាណនៃជនជាប់ចោទ សេចក្តីសង្ខេបនៃអង្គហេតុ ឈ្មោះបទល្មើសដែលត្រូវចោទប្រកាន់ និង អត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើស។ មួយវិញទៀត នៅក្នុងដីកាកោះហៅបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ត្រូវចង្អុលបង្ហាញឲ្យបានច្បាស់លាស់អំពី ទីកន្លែង កាលបរិច្ឆេទ និងម៉ោងសវនាការជាដើម។ ដោយដីកានេះត្រូវបញ្ជាក់ថា ជនជាប់ចោទមានសិទ្ធិអាចពឹងពាក់មេធាវីឲ្យអមខ្លួនបាន[11]។

## កថាខណ្ឌទី២៖ ការចូលបង្ហាញខ្លួនភ្លាមដែលធ្វើដោយព្រះរាជអាជ្ញា

ការចូលបង្ហាញខ្លួនភ្លាមរបស់ជនជាប់ចោទនៅចំពោះមុខតុលាការ ត្រូវធ្វើឡើងតាមរយៈកំណត់ ហេតុស្តីពីការបង្ហាញខ្លួនភ្លាម គឺ ជាជម្រើសនៃការចោទប្រកាន់របស់ព្រះរាជអាជ្ញា ដោយគោរពនៃលក្ខខណ្ឌ និងធ្វើតាមនីតិវិធីមួយតាមបញ្ញត្តិច្បាប់។

### ២.១ លក្ខខណ្ឌនៃការបង្ហាញខ្លួនភ្លាមនៅចំពោះតុលាការជាន់ដំបូង

មុននឹងព្រះរាជអាជ្ញាសម្រេចបញ្ជូនរឿងទៅតុលាការជាន់ដំបូងតាមនីតិវិធីនៃការបង្ហាញខ្លួនភ្លាមបាន។ លុះត្រាតែសំណុំរឿងនោះបានបំពេញនូវលក្ខខណ្ឌមួយចំនួនដូចខាងក្រោម៖

- បទល្មើសជាប្រភេទបទល្មើសជាក់ស្តែង តាមអត្ថន័យនៃមាត្រា ៨៦ (និយមន័យបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង) និងមាត្រា ៨៨ (ការចាត់ទុកដូចជាបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង) នៃក្រមនីតិវិធីព្រហ្មទណ្ឌ២០០៧
- បទល្មើសត្រូវផ្តន្ទាទោសដាក់ពន្ធនាគារយ៉ាងតិច១ (មួយ) ឆ្នាំ និងយ៉ាងច្រើន៥ (ប្រាំ) ឆ្នាំ
- ជនជាប់ចោទជានីតិជន
- រឿងក្តីសមល្មមមានលក្ខណៈគ្រប់គ្រាន់ល្មមនឹងទទួលបានការជំនុំជម្រះ[12]។

យ៉ាងណាមិញ បើសិនជាសំណុំរឿងដែលព្រះរាជអាជ្ញាធ្វើការចោទប្រកាន់នោះ មិនបានបំពេញនៃលក្ខខណ្ឌខាងលើនោះទេ។ ព្រះរាជអាជ្ញាត្រូវចេញដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរទៅចៅក្រមស៊ើបសួរ ដើម្បីបើកការស៊ើបសួរលើសំណុំរឿងដែលមានបង្ហាញក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរនោះ។

[11] មាត្រា ៤៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

[12] មាត្រា ៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

### ២.២ នីតិវិធីនៃការបង្ហាញខ្លួនភ្លាម

បន្ទាប់ពីមន្ត្រីនគរបាលយុត្តិធម៌បញ្ជូនសំណុំរឿងមកឲ្យខ្លួនដើម្បីធ្វើការចោទប្រកាន់។ អំឡុងពេលនោះបើសិនជា ព្រះរាជអាជ្ញាពិនិត្យឃើញថាមានលក្ខខណ្ឌគ្រប់គ្រាន់សម្រាប់បង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាមនៅចំពោះមុខតុលាការ ព្រះរាជអាជ្ញាត្រូវះ

- ត្រូវធ្វើការពិនិត្យអត្តសញ្ញាណជនជាប់ចោទ
- ឲ្យដំណឹងដល់ជននោះ អំពីរឿងរ៉ាវដែលបានចោទប្រកាន់ និងឈ្មោះបទល្មើសដែលបានចោទប្រកាន់
- ទទួលចម្លើយពីជននោះ បើសិនជាសាមីខ្លួនចង់និយាយ
- ធ្វើកំណត់ហេតុស្តីពីការបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាម។

ព្រះរាជអាជ្ញាត្រូវចុះនិទ្ទេសឲ្យបានត្រឹមត្រូវតាមទម្រង់ការនៃនីតិវិធីនៅក្នុងកំណត់ហេតុស្តីពីការបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាម។ បើពុំដូច្នោះទេ នីតិវិធីនៃការបង្ហាញខ្លួនភ្លាមនេះនឹងត្រូវទុកជាមោឃៈ។ តុលាការជាន់ដំបូងត្រូវបានទទួលបណ្តឹងតាមកំណត់ហេតុស្តីពីការបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាម។

ព្រះរាជអាជ្ញាអាចប្រាប់ជនជាប់ចោទថា ខ្លួនមានសិទ្ធិសុំពឹងមេធាវីតាមការជ្រើសរើសរបស់ខ្លួន ឬ ចាត់តាំងឡើងដោយអនុលោមតាមច្បាប់ស្តីពីលក្ខន្តិកៈមេធាវី។

មេធាវីជ្រើសរើស ឬចាត់តាំងត្រូវបានទទួលដំណឹងភ្លាម។ មេធាវីអាចពិនិត្យសំណុំរឿង និងទាក់ទងជាមួយជនជាប់ចោទបាន។ និទ្ទេសទម្រង់ទាំងនេះ ត្រូវចុះនៅក្នុងកំណត់ហេតុ បើពុំដូច្នោះទេ នីតិវិធីត្រូវទុកជាមោឃៈ[13]។

## កថាខណ្ឌទី៣៖ ដីកាបញ្ជូនរបស់ចៅក្រមស៊ើបសួរ ឬ សាលដីកាបញ្ជូនរបស់សភាស៊ើបសួរ

### ៣.១ ដីកាបញ្ជូនរបស់ចៅក្រមស៊ើបសួរ

ដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់ចៅក្រមស៊ើបសួរ គឺជាប្រភេទមួយនៃដីកាដំណោះស្រាយដែលចៅក្រមស៊ើបសួរបានចេញ បន្ទាប់ពីបិទការស៊ើបសួរ។ ទន្ទឹមនឹងនោះ មូលហេតុដែលចៅក្រមស៊ើបសួរចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះគឺដោយពិនិត្យឃើញថាសំណុំរឿង ដែលខ្លួនបានបើកការស៊ើបសួរនោះ ជាបទឧក្រិដ្ឋ បទមជ្ឈិម ឬ បទលហុ ។ ក្នុងដីកាបញ្ជូនទៅជំនុំជម្រះត្រូវរៀបរាប់ពីអំពើដែលត្រូវចោទប្រកាន់និង ឈ្មោះបទល្មើសតាមច្បាប់[14]។

#### ៣.១.១ លក្ខខណ្ឌនៃការបញ្ជូនរឿងទៅជំនុំជម្រះរបស់ចៅក្រមស៊ើបសួរ

ចៅក្រមស៊ើបសួរចេញនូវដីកាបញ្ជូនរឿងទៅជំនុំជម្រះ បន្ទាប់ពីខ្លួនបានយល់ឃើញថាមានបន្ទុកគ្រប់គ្រាន់ចំពោះអំពើរបស់ជនត្រូវចោទ ជាបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ ដើម្បីបើកសវនាការជំនុំជម្រះ។

[13] មាត្រា ៤៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

[14] មាត្រា២៤៧ថ្មី នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

### ៣.១.២ នីតិវិធីនៃការបញ្ជូនដីកាបញ្ជូនទៅជំនុំជម្រះ

ប្រសិនបើចៅក្រមស៊ើបសួរ សម្រេចចេញដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះ ចៅក្រមស៊ើបសួរបញ្ជូនសំណុំរឿងជាបន្ទាន់ទៅប្រធានតុលាការ ដើម្បីកំណត់ពេលវេលាសវនាការជំនុំជម្រះ[15]។

## ៣.២ ការបញ្ជូនរឿងទៅជំនុំជម្រះរបស់សភាស៊ើបសួរ

បន្ទាប់ពីចៅក្រមស៊ើបសួរបានចេញដីកាសម្រេចលើកលែងការចោទប្រកាន់ តាមបញ្ញត្តិមាត្រា២៤៧ថ្មីនៃក្រមនីតិវិធីព្រហ្មទណ្ឌ២០០៧ ដោយមានសំអាងហេតុដូចករណីខាងក្រោម៖

- អំពើប្រព្រឹត្តមិនមែនជាបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ
- ជនដែលបានប្រព្រឹត្តអំពើនោះនៅតែគេមិនស្គាល់
- គ្មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនត្រូវចោទ

ចំពោះដីកាខាងលើនេះ ចៅក្រមស៊ើបសួរត្រូវធ្វើការជូនដំណឹងក្នុងរយៈពេលដ៏ខ្លីបំផុតដល់ព្រះរាជអាជ្ញា ជនត្រូវចោទ និងដើមបណ្តឹងរដ្ឋប្បវេណី។ ក្នុងករណីនេះ ប្រសិនបើអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ព្រះរាជអាជ្ញា ជនរងគ្រោះ ឬដើមបណ្តឹងរដ្ឋប្បវេណីមិនសុខចិត្តជាមួយដីកាលើកលែងចោទប្រកាន់នោះទេគឺអាចដាក់ពាក្យបណ្តឹងទៅកាន់មកសភាស៊ើបសួរនៃសាលាឧទ្ធរណ៍នោះបាន។

### ៣.២.១ ចំណាត់ការរបស់សភាស៊ើបសួរ

បន្ទាប់ពីសភាស៊ើបសួរ បានទទួលពាក្យបណ្តឹងចំពោះដីកាសលើកលែងការចោទប្រកាន់របស់ចៅក្រមស៊ើបសួរ ពីអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ព្រះរាជអាជ្ញា ជនរងគ្រោះ ឬដើមបណ្តឹងរដ្ឋប្បវេណី។ ក្នុងករណីនេះ ប្រសិនបើសភាស៊ើបសួរយល់ឃើញថាការចេញដីកាលើកលែងការចោទប្រកាន់របស់ចៅក្រមស៊ើបសួរសម្រេចត្រឹមត្រូវហើយនោះ សភាស៊ើបសួរត្រូវចេញសាលដីកាសម្រេចតម្កល់ដីកាសម្រេចរបស់ចៅក្រមស៊ើបសួរនៃសាលាដំបូងនោះបាន ។ប៉ុន្តែ ប្រសិនបើសភាស៊ើបសួរយល់ឃើញថាសំណុំរឿងនោះមានភស្តុតាងគ្រប់គ្រាន់ អាចនឹងបើកការជំនុំជម្រះបានពេលនោះសភាស៊ើបសួរត្រូវចេញសាលដីបញ្ជូនរឿងទៅជំនុំជម្រះទៅតុលាការដើមវិញ ។

## ផ្នែកទី៣៖ ការកោះហៅគូភាគីឲ្យចូលសវនាការ

ការកោះហៅ គឺជាការបង្គាប់របស់តុលាការ ដែលតម្រូវឲ្យបុគ្គលណាម្នាក់ ត្រូវតែមកបង្ហាញខ្លួននៅចំពោះមុខតុលាការ តាមកាលបរិច្ឆេទកំណត់។ ការកោះហៅអាចធ្វើបានតាមវិធីបញ្ជូនដីកា ឬ ដោយជូនដំណឹងអំពីកាលបរិច្ឆេទ។ យើងបានដឹងហើយថា ចៅក្រមជំនុំជម្រះអាចបើកសវនាការជំនុំជម្រះក្តីលើសំណុំរឿងព្រហ្មទណ្ឌបាន លុះត្រាតែបានធ្វើការកោះហៅបុគ្គលដែលពាក់ព័ន្ធឲ្យចូលមកកាន់សវនាការតាមកាលកំណត់។ ទន្ទឹមនឹងនោះ តុលាការក៏អាចកោះហៅជនទាំងឡាយ

[15] មាត្រា២៥០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

ណាដែលមានផលប្រយោជន៍ដល់ការជំនុំជម្រះ មានដូចជា ជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី ជនរងគ្រោះ សាក្សី អ្នកជំនាញ មេធាវីការពារដើមចោទមេធាវីការពារដើមបណ្តឹងរដ្ឋប្បវេណី អ្នកបកប្រែ ឬ អ្នកតំណាងស្របច្បាប់នៃជនទាំងនោះ[16]។

## កថាខណ្ឌទី១៖ ការកោះហៅជនជាប់ចោទឲ្យចូលសវនាការ

ការកោះហៅជនជាប់ចោទ ត្រូវបានធ្វើឡើងតាមរយៈដីកាបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ កំណត់ ហេតុស្តីពីការបង្ហាញខ្លួនភ្លាម ,ដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់ចៅក្រមស៊ើបសួរ និង សាលដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់ចៅក្រមស៊ើបសួរ។

### ១.១ ការកោះហៅជនជាប់ចោទតាមដីកាបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់

#### ១.១.១ ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះ

ព្រះរាជអាជ្ញាអាចបញ្ជាឲ្យជនជាប់ចោទទៅមុខតុលាការជំនុំជម្រះតាមដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់បាន។ ដោយដីកាកោះនេះត្រូវមាននិទ្ទេសដូចខាងក្រោម៖

- អត្តសញ្ញាណជនជាប់ចោទ
- សេចក្តីសង្ខេបនៃអង្គហេតុ
- ឈ្មោះបទល្មើស
- អត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើស
- សិទ្ធិពឹងពាក់មេធាវីអមជាមួយ

ដីកានេះត្រូវចង្អុលប្រាប់ពីតុលាការ ព្រមទាំងទីកន្លែង កាលបរិច្ឆេទ និងម៉ោងពេលនាសវនាការ។ ដីកានេះត្រូវបញ្ជាក់ថា ជនជាប់ចោទអាចពឹងមេធាវីឲ្យអមខ្លួនបាន[17]។ ដើមដីកាដែលមានចុះកាលបរិច្ឆេទ ទីកន្លែងកំណើត និងលំនៅឋានរបស់ជនជាប់ចោទត្រូវតែមានការចុះកាលបរិច្ឆេទ និងចុះហត្ថលេខាដោយព្រះរាជអាជ្ញា[18]។

#### ១.១.២ រយៈពេលដែលត្រូវគោរព

រយៈពេលដែលត្រូវគោរព រវាងការប្រគល់ដីកាកោះហៅ តាមដីកាបញ្ជូនទៅជំនុំជម្រះផ្ទាល់ឲ្យដល់ជនជាប់ចោទ និងថ្ងៃកំណត់ឲ្យចូលបង្ហាញខ្លួនក្នុងសវនាការ ត្រូវអនុវត្តដូចតទៅ៖

- ១៥ (ដប់ប្រាំ)ថ្ងៃ ប្រសិនបើជនជាប់ចោទរស់នៅក្នុងដែនដី ទីស្នាក់ការរបស់តុលាការជាន់ដំបូង
- ២០ (ម្ភៃ) ថ្ងៃ ប្រសិនបើជនជាប់ចោទរស់នៅក្នុងទីកន្លែងមួយផ្សេងទៀតក្នុងដែនដីជាតិ

[16] មាត្រា២៩៤ មាត្រា២៩៥ មាត្រា២៩៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ខែសីហា ឆ្នាំ២០០៧

[17] មាត្រា ៤៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ខែសីហា ឆ្នាំ២០០៧

[18] មាត្រា ៤៥៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ខែសីហា ឆ្នាំ២០០៧

– ២ (ពីរ) ខែ ប្រសិនបើជនជាប់ចោទរស់នៅក្នុងរដ្ឋមួយជាប់ព្រំដែនព្រះរាជាណាចក្រកម្ពុជា
– ៣ (បី) ខែ ប្រសិនបើជនជាប់ចោទរស់នៅក្នុងទីកន្លែងដទៃផ្សេងៗទៀត[19]។

## ១.២ ការកោះហៅជនជាប់ចោទតាមកំណត់ហេតុស្ដីពីការបង្ហាញខ្លួនភ្លាម

### ១.២.១ នីតិវិធីនៃការបញ្ជូនជនជាប់ចោទទៅកាន់តុលាការជាន់ដំបូង

ក្នុងករណីដែលតុលាការជាន់ដំបូងត្រូវបានទទួលបណ្ដឹងតាមការកំណត់ហេតុស្ដីពីការបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាមនោះ។ ដូចនេះជនជាប់ចោទ ត្រូវបានបង្ខាំងទុកដោយមានកងកម្លាំងការពារ រហូតដល់ពេលសាមីខ្លួនចូលបង្ហាញខ្លួននៅចំពោះមុខតុលាការដែលត្រូវបើកសវនាការក្នុងថ្ងៃនោះតែម្ដង។ យ៉ាងណាមិញបន្ទាប់ពីបានបញ្ជូនជនជាប់ចោទទៅចំពោះមុខតុលាការ ជនជាប់អាចសុំរយៈពេល ឬ ប្រសិនបើតុលាការយល់ឃើញថា រឿងក្ដីនោះមិនទាន់អាចជំនុំជម្រះបានភ្លាមៗបានទេនោះ សំណុំរឿងត្រូវលើកទៅសវនាការពេលក្រោយ។ តុលាការអាចបង្គាប់ឲ្យឃុំខ្លួនជនជាប់ចោទជាបណ្ដោះអាសន្ន ដោយសាលក្រមដែលមានបញ្ជាក់ពីសំអាងហេតុ។ ទន្ទឹមនឹងនោះតុលាការត្រូវយោងតាមលក្ខខណ្ឌនៃមាត្រា២០៥ **(មូលហេតុនៃការឃុំខ្លួនបណ្ដោះអាសន្ន)** នៃក្រមនីតិវិធីព្រហ្មទណ្ឌ២០០៧។ ប៉ុន្តែការឃុំខ្លួនបណ្ដោះអាសន្នមិនត្រូវលើសពីរយៈពេល២ (ពីរ) សប្ដាហ៍គិតចាប់ពីថ្ងៃចូលទៅបង្ហាញនៅចំពោះមុខតុលាការ[20]។

### ១.២.២ វិធីបញ្ជូនដីកាកោះហៅជនជាប់ចោទដែលនៅក្នុងឃុំ

ក្នុងករណីដែលជនជាប់ចោទត្រូវឃុំខ្លួននៅមណ្ឌលឃុំខ្លួន ឬក្នុងពន្ធនាគារនោះ គឺមិនមានរយៈពេលកំណត់ណាមួយជាក់លាក់ឡើយអំពីការប្រគល់ដីកាដល់ជនជាប់ចោទ និងថ្ងៃកំណត់ឲ្យចូលមកសវនាការ គោលបំណងដែលសំខាន់គឺធ្វើដូចម្ដេចឲ្យតែសម្រេចគោលបំណងនៃការកោះហៅ។ ជាក់ស្ដែង ការបញ្ជូនដីកានេះ ត្រូវធ្វើឡើងទៅកាន់ប្រធានមណ្ឌលឃុំខ្លួន ឬប្រធានពន្ធនាគារដើម្បីឲ្យនាំជនជាប់ចោទឲ្យចូលបង្ហាញខ្លួននៅចំពោះមុខតុលាការ។

## ១.៣ ការកោះហៅតាមដីកាបញ្ជូនរបស់ចៅក្រមស៊ើបសួរ ឬសាលដីបញ្ជូនរបស់សភាស៊ើបសួរ

ចំពោះការកោះហៅជនជាប់ចោទឲ្យចូលសវនាការតាមដីកាបញ្ជូនរបស់ចៅក្រមស៊ើបសួរ ឬសាលដីកាបញ្ជូនរបស់សភាស៊ើបសួរ ត្រូវបែងចែកជាពីរលក្ខខណ្ឌ គឺ ការកោះហៅជនជាប់ចោទដែលស្ថិតនៅក្រៅឃុំ និងការកោះហៅជនជាប់ចោទដែលស្ថិតនៅក្នុងឃុំ។

[19] មាត្រា៤៥៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ខែសីហា ឆ្នាំ២០០៧

[20] មាត្រា៤៨នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ខែសីហា ឆ្នាំ២០០៧

### ១.៣.១. ការកោះហៅជនជាប់ចោទដែលស្ថិតនៅក្រៅឃុំ

#### ១.៣.១.១ រយៈពេលដែលត្រូវគោរព

ក្រមនីតិវិធីព្រហ្មទណ្ឌ បានធ្វើការកំណត់យ៉ាងច្បាស់លាស់អំពីរយៈពេលដែលត្រូវគោរពក្នុងការធ្វើការកោះហៅជនជាប់ចោទឲ្យចូលសវនាការតាមរយៈដីកាបញ្ជូនរបស់ចៅក្រមស៊ើបសួរ ឬសាលដីកាបញ្ជូនរបស់សភាស៊ើបសួរ។ រយៈពេលដែលត្រូវគោរពក្នុងការប្រគល់ ត្រូវគិតចាប់ពីថ្ងៃបញ្ជូនដីកាកោះរហូតដល់ថ្ងៃចូលមកចំពោះមុខតុលាការ ដោយមានការកំណត់ដូចខាងក្រោម៖

- ១៥ (ដប់ប្រាំ)ថ្ងៃ ប្រសិនបើជនជាប់ចោទរស់នៅក្នុងដែនដី ទីស្នាក់ការរបស់តុលាការជាន់ដំបូង
- ២០ (ម្ភៃ) ថ្ងៃ ប្រសិនបើជនជាប់ចោទរស់នៅក្នុងទីកន្លែងមួយផ្សេងទៀតក្នុងដែនដីជាតិ
- ២ (ពីរ) ខែ ប្រសិនបើជនជាប់ចោទរស់នៅក្នុងរដ្ឋមួយជាប់ព្រំដែនព្រះរាជាណាចក្រកម្ពុជា
- ៣ (បី) ខែ ប្រសិនបើជនជាប់ចោទរស់នៅក្នុងទីកន្លែងដទៃផ្សេងៗទៀត[21]។

#### ១.៣.១.២ ទម្រង់នៃដីកាកោះហៅឲ្យចូលសវនាការ

ដីកាកោះហៅឲ្យចូលសវនាការតាមដីកាបញ្ជូនរបស់ចៅក្រមស៊ើបសួរ ឬសាលដីកាបញ្ជូនរបស់សភាស៊ើបសួរត្រូវមានការចុះនិទ្ទេសដូចខាងក្រោម៖

- អត្តសញ្ញាណនៃជនជាប់ចោទ
- លំនៅឋាននៃជនជាប់ចោទ
- ការយោងដីកា ឬសាលដីកាបញ្ជូន
- តុលាការដែលទទួលបណ្ដឹងជំនុំជម្រះ
- ទីកន្លែង កាលបរិច្ឆេទ និងម៉ោងសវនាការ
- កាលបរិច្ឆេទ និងហត្ថលេខារបស់ព្រះរាជអាជ្ញា

ក្នុងដីកាកោះនេះ ត្រូវបញ្ជាក់ថា ជនជាប់ចោទមានអាចមានមេធាវីអម[22]។

## កថាខណ្ឌទី២ ការកោះហៅបុគ្គលពាក់ព័ន្ធក្រៅពីជនជាប់ចោទឲ្យចូលសវនាការ

### ២.១ បុគ្គលដែលត្រូវកោះហៅឲ្យចូលសវនាការ

ក្នុងរឿងព្រហ្មទណ្ឌក្រៅពីជនជាប់ចោទ តុលាការត្រូវធ្វើការកោះហៅបុគ្គលពាក់ព័ន្ធមួយចំនួនដែលជាប្រយោជន៍ចំពោះភាគី ដោយបុគ្គលទាំងនោះមានដូចខាងក្រោមនេះ៖

- ដើមបណ្ដឹងរដ្ឋប្បវេណី
- ជនរងគ្រោះ

[21] មាត្រា៤៦៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

[22] មាត្រា៤៦៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

- សាក្សី
- អ្នកជំនាញ
- អ្នកបកប្រែ
- អ្នកទទួលខុសត្រូវរដ្ឋប្បវេណី

យ៉ាងណាមិញ ការកោះហៅបុគ្គលពាក់ព័ន្ធខាងលើនេះតាមរយៈដីកាកោះហៅឲ្យចូលសវនាការត្រូវមានចុះនិទ្ទេសដូចមានបញ្ញត្តិនៃមាត្រា៤៧៥ ដល់ មាត្រា៤៨១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ២០០៧។

## ២.២. រយៈពេលដែលត្រូវគោរពសម្រាប់ការកោះហៅបុគ្គលពាក់ព័ន្ធ

ចំពោះរយៈពេលដែលត្រូវគោរពសម្រាប់ការកោះហៅបុគ្គលពាក់ព័ន្ធឲ្យចូលសវនាការ ក្រមនីតិវិធីព្រហ្មទណ្ឌពុំបានបញ្ញត្តិនោះទេ។ ករណីនេះព្រះរាជអាជ្ញាត្រូវកំណត់រយៈពេលឲ្យបានសមរម្យសម្រាប់បុគ្គលពាក់ព័ន្ធ ដើម្បីឲ្យពួកគាត់ធ្វើការរៀបចំឯកសារពាក់ព័ន្ធនានា និង ចូលមកសវនាការតាមការកោះហៅនោះ។

## ២.៣ នីតិវិធីនៃការប្រគល់ដីកាកោះ

ចំពោះការប្រគល់ដីកាកោះហៅដល់ដើមបណ្ដឹងរដ្ឋប្បវេណី ជនរងគ្រោះ សាក្សី អ្នកជំនាញ អ្នកបកប្រែ និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណីឲ្យចូលមកសវនាការ ត្រូវតាមនីតិវិធីនៃការប្រគល់ដីកាកោះហៅជនជាប់ចោទឲ្យចូលមកកាន់សវនាការផងដែរ[23]។ ទន្ទឹមនឹងនោះបុគ្គលដែលមានសមត្ថកិច្ចក្នុងការប្រគល់ដីកាកោះហៅមានដូចខាងក្រោម៖

- ព្រះរាជអាជ្ញា
- អាជ្ញាសាលា
- មេឃុំ ឬ ចៅសង្កាត់ ឬ ជំទប់ ឬ ចៅសង្កាត់រងណាមួយ
- ក្រឡាបញ្ជី
- ឬតាមរយៈផ្លូវរដ្ឋបាល។

[23] មាត្រា៤៨១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

# ជំពូកទី២៖
# កិច្ចដំណើរការនីតិវិធីជំនុំជម្រះ

## ផ្នែកទី១ ដំណាក់កាលមុនប្រកាសបើកសវនាការ

បន្ទាប់ពីព្រះរាជអាជ្ញាបានធ្វើការកោះហៅភាគីពាក់ព័ន្ធដែលត្រូវចូលរួមសវនាការតាមរយៈដីកាកោះហៅ ឬតាមរយៈដីកាបង្គាប់នាំខ្លួន(ករណីជនជាប់ចោទជាប់ឃុំក្នុងពន្ធនាគារ) ហើយរួចនោះ។ ភាគីដែលទទួលបានដីកានោះត្រូវតែចូលខ្លួនមកកាន់តុលាការតាមការកំណត់ដែលមានបញ្ជាក់នៅក្នុងដីកា។

### កថាខណ្ឌទី១ ការចូលខ្លួនរបស់ភាគី

ក្នុងរឿងក្តីព្រហ្មទណ្ឌ បុគ្គលដែលត្រូវចូលខ្លួនទៅចំពោះមុខតុលាការគឺជាបុគ្គលទាំងឡាយណាដែលមបានធ្វើការកោះហៅដែលបានរៀបរាប់បង្ហាញនៅក្នុង (**ផ្នែកទី៣ ការកោះហៅគូភាគីឲ្យចូលសវនាការ**)នៃសារណានេះ។

#### ១.១ ការចូលខ្លួនរបស់ជនជាប់ចោទ

ជនជាប់ចោទត្រូវចូលបង្ហាញខ្លួននៅពេលសវនាការដោយផ្ទាល់។ ជនជាប់ចោទត្រូវអមដោយមេធាវីម្នាក់ដែលខ្លួនជ្រើសរើស។ ទន្ទឹមនឹងនោះ ជនជាប់ចោទក៏អាចសុំឲ្យចាត់តាំងមេធាវីឲ្យខ្លួនបានដែរ នៅក្នុងលក្ខខណ្ឌដែលមានចែងក្នុងច្បាប់ស្តីពីលក្ខន្តិកៈមេធាវី[24]។ យ៉ាងណាមិញជនជាប់ចោទចូលខ្លួនមកកាន់សវនាការតាមនីតិវិធីបីយ៉ាង គឺតាមរយៈនីតិវិធីជំនុំជម្រះផ្ទាល់ នីតិវិធីបង្ហាញខ្លួនភ្លាម ឬតាមរយៈដីកាបញ្ជូនរបស់ចៅក្រមស៊ើបសួរ ឬសាលដីកាបញ្ជូនរបស់សភាស៊ើបសួរ។ក្នុងករណីនីតិវិធីបញ្ជូនទៅជំនុំជម្រះផ្ទាល់ ជនជាប់ចោទត្រូវចូលបង្ហាញខ្លួនដោយខ្លួនឯងនៅពេលសវនាការនៃតុលាការជាន់ដំបូង តាមរយៈដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ដែលចេញដោយព្រះរាជអាជ្ញា ដោយក្នុងដីកានេះគឺផ្តល់សិទ្ធិឲ្យជនជាប់ចោទអាចពឹងមេធាវីឲ្យអមខ្លួនបាន[25]។

ចំពោះការចូលខ្លួនតាមនីតិវិធីបង្ហាញខ្លួនភ្លាមវិញនោះ ជនជាប់ចោទត្រូវចូលខ្លួននៅចំពោះមុខតុលាការដោយមានកម្លាំងអម ពីព្រោះថានៅក្នុងនីតិវីបង្ហាញខ្លួនភ្លាម ជនជាប់ចោទស្ថិតនៅក្រោមការឃុំគ្រងដោយកងកម្លាំងការពារ រហូតដល់ពេលដែលជននោះត្រូវបានចូលបង្ហាញខ្លួននៅចំពោះមុខតុលាការ។ ទន្ទឹមនឹងនោះ ពេលដែលជនជាប់ចោទបានចូលមកបង្ហាញខ្លួននៅក្នុងសវនាការ ក្រោយពីបានផ្ទៀងផ្ទាត់ពិនិត្យមើលអត្តសញ្ញាណរបស់ជនជាប់ចោទ និងរបាយការណ៍សង្ខេបរឿងហេតុដែលត្រូវចោទប្រកាន់មក តុលាការត្រូវប្រាប់ជនជាប់ចោទថា សាមីខ្លួនអាចមានរយៈពេលដើម្បីរៀបចំការពារខ្លួន។ ទន្ទឹមនឹងនោះ ប្រសិនបើមានការស្នើពីជនជាប់ចោទដើម្បីទុករយៈ

[24] មាត្រា៣០០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ខែសីហា ឆ្នាំ២០០៧

[25]មាត្រា៤៦ , មាត្រា៣០២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ខែសីហា ឆ្នាំ២០០៧

ពេលរៀបចំការពារខ្លួន ឬ ប្រសិនបើតុលាការយល់ឃើញថារឿងនោះមិនទាន់អាចជំនុំជម្រះបានទេនោះ។ តុលាការត្រូវលើកសវនាការនៅពេលក្រោយទៀតបាន។មួយវិញទៀត ចំពោះការឃុំខ្លួនជាបណ្តោះអាសន្នត្រូវតែបញ្ឈប់ដោយពេញលក្ខណៈច្បាប់ នៅពេលផុតថិរវេលា២ (ពីរ) សប្តាហ៍[26]។

ចំណែកឯការចូលខ្លួនរបស់ជនជាប់ចោទតាមរយៈដីកាបញ្ជូនរបស់ចៅក្រមស៊ើបសួរ ឬ សាលដីកាបស់សភាស៊ើបសួរ ជនជាប់ចោទត្រូវចូលបង្ហាញខ្លួនដោយសេរីនៅចំពោះតុលាការលើកលែងតែករណីដែលជនជាប់ចោទរងនៅការឃុំខ្លួនបណ្តោះអាសន្នប៉ុណ្ណោះ។ បើសិនជាជនជាប់ចោទត្រូវបានឃុំខ្លួបណ្តោះអាសន្ន ព្រះរាជអាជ្ញាត្រូវចាត់វិធានការចាំបាច់ ដើម្បីនាំជនជាប់ចោទដែលត្រូវបានឃុំខ្លួននោះទៅកាន់តុលាការដោយមានការអមជាមួយកងកម្លាំងសាធាណៈ។ ទន្ទឹមនឹងនោះ បើសិនជាមិនបាននាំជនជាប់ចោទឲ្យចូលទៅបង្ហាញខ្លួននៅចំពោះមុខតុលាការទេនោះក្នុងរយៈពេល៤ (បួន) ខែ ដែលជារយៈពេលជនជាប់ចោទនោះបានស្ថិតនៅក្រោមវិធានការឃុំខ្លួនបណ្តោះអាសន្ន។ជនជាប់ចោទត្រូវតែបានដោះលែងឲ្យមានសេរីភាពដោយឯកឯងវិញ[27]។

ចំពោះករណីអញ្ញាត្រកម្ម ប្រសិនបើមានមូលហេតុ ស្ថានភាពសុខភាពរបស់ជនជាប់ចោទ ឬដោយមានមូលហេតុធ្ងន់ធ្ងរ ដែលធ្វើឲ្យជនជាប់ចោទមិនអាចចូលទៅបង្ហាញខ្លួននៅចំពោះតុលាការបានទេនោះ ប្រធានសវនាការអាចបង្គាប់ឲ្យសួរចម្លើយជនជាប់ចោទ នៅទីកន្លែងដែលជននោះនៅ[28]។ ប៉ុន្តែបើសិនជា ជនជាប់ចោទមិនចូលបង្ហាញខ្លួនទ តុលាការអាចបង្គាប់ឲ្យបង្អង់រឿងទុកសិន និងចេញដីកាបង្គាប់ឲ្យនាំខ្លួនជនជាប់ចោទនោះមកកាន់តុលាការ។ តុលាការត្រូវកំណត់កាលបរិច្ឆេទនៃការបើកសវនាការថ្មី[29]។

## ១.២ ការចូលខ្លួនរបស់ភាគីក្រៅពីជនជាប់ចោទ

ក្រៅពីជនជាប់ចោទ ដែលត្រូវចូលខ្លួនមកនៅចំពោះមុខតុលាការដើម្បីបើកសវនាកាធ្វើការជំនុំជម្រះលើរឿងក្តីព្រហ្មទណ្ឌ ក៏មានការចូលរួមពីភាគីពាក់ព័ន្ធផ្សេងក្រៅពីជនជាប់ចោទផងដែរ ដោយក្នុងនោះមានដូចជា ជនរងគ្រោះ ដើមបណ្តឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី សាក្សី អ្នកជំនាញ អ្នកបកប្រែ ចំពោះដើមបណ្តឹងរដ្ឋប្បវេណីនៅពេលចូលបង្ហាញខ្លួននៅចំពោះមុខតុលាការក៏អាចត្រូវបានអមដោយមេធាវីផងដែរ។

យ៉ាងណាមិញ ដើមបណ្តឹងរដ្ឋប្បវេណីក៏អាចត្រូវបានតំណាងដោយមេធាវី ដោយសហព័ទ្ធ ឬដោយញាតិលោហិតខ្សែផ្ទាល់ដែរ។ អ្នកតំណាងដែលមិនមែនជាមេធាវីត្រូវមានលិខិតប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរ[30]។ ទន្ទឹមនឹងនោះ ការចូលខ្លួនរបស់អ្នកទទួលខុសត្រូវរដ្ឋប្បវេណីក៏មិនខុស

---

[26] មាត្រា៣០៣, មាត្រា ៣០៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ខែសីហា ឆ្នាំ២០០៧

[27] មាត្រា៣០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ខែសីហា ឆ្នាំ២០០៧

[28] មាត្រា៣០៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ខែសីហា ឆ្នាំ២០០៧

[29] មាត្រា៣១០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ខែសីហា ឆ្នាំ២០០៧

[30] មាត្រា៣១៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ខែសីហា ឆ្នាំ២០០៧

ពីការចូលខ្លួនរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែរ គឺអ្នកទទួលខុសត្រូវរដ្ឋប្បវេណីត្រូវបានអមដោយមេធាវី។ អ្នកទទួលខុសត្រូវរដ្ឋប្បវេណី ក៏អាចត្រូវបានតំណាងដោយមេធាវី ដោយសហព័ទ្ធ ឬដោយញាតិលោហិតខ្សែផ្ទាល់ដែរ។ អ្នកតំណាងដែលមិនមែនជាមេធាវីត្រូវមានលិខិតប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរ[31]។

ចំពោះជនដែលជាសាក្សីត្រូវតែចូលបង្ហាញខ្លួននៅចំពោះមុខតុលាការតាមការកោះហៅ។ ប៉ុន្តែក្នុងករណីសាក្សីនោះរឹងទទឹងមិនព្រមចូលបង្ហាញខ្លួនតាមការកោះហៅទេនោះ។ តុលាការអាចប្រើកងកម្លាំងសាធារណៈដើម្បីបង្ខំសាក្សីឲ្យចូលបង្ហាញខ្លួននៅចំពោះមុខតុលាការបាន[32]។

## កថាខណ្ឌទី២ ការដឹកនាំសម្បថ

ការដឹកនាំសម្បថគឺជានីតិវិធីមួយដែលត្រូវបានធ្វើឡើងមុននឹងតុលាការធ្វើការបើកសវនាការដើម្បីធ្វើកិច្ចពិភាក្សាដេញដោលលើសំណុំរឿងព្រហ្មទណ្ឌ។ ទន្ទឹមនឹងនោះ ការដឹកនាំសម្បថគឺត្រូវបានដឹកនាំដោយក្រឡាបញ្ជីសវនាការ ដែលត្រូវនាំបុគ្គលពាក់ព័ន្ធមួយចំនួនដែលច្បាប់តម្រូវឱ្យធ្វើសម្បថមុននឹងផ្តល់ចម្លើយជូនដល់តុលាការពីដំណើរនៃរឿងដែលខ្លួនបានដឹង។

### ២.១ បុគ្គលដែលត្រូវធ្វើសម្បថ

មុននឹងប្រធានតុលាការ ធ្វើការសាកសួរចម្លើយដើម្បីបានជាពត៌មានមកធ្វើការពិចារណាអំពីអត្ថិភាព ឬនត្ថិភាពនៃបទល្មើស។ តុលាការត្រូវឲ្យបុគ្គលដែលត្រូវសួរចម្លើយនោះស្បថអំពីថាខ្លួននិយាយតែការពិតស្របតាមសាសនា ឬជំនឿរបស់ខ្លួន ដោយក្នុងនោះបុគ្គលដែលត្រូវធ្វើសម្បថមានដូចជា សាក្សី អ្នកបកប្រែ ជាដើម[33] ។ប៉ុន្តែបើសិនជាបុគ្គលទាំងនេះ បានធ្វើសម្បថម្តងរួចមកហើយនៅដំណាក់កាលថៅក្រមស៊ើបសួរ តុលាការមិនចាំបាច់ឱ្យជនទាំងនោះធ្វើសម្បថម្តងទៀតទេ។ទន្ទឹមនឹងនោះ ក្រមនីតិវិធីព្រហ្មទណ្ឌក៏បានបញ្ញត្តិអំពីសាក្សី និងអ្នកបកប្រែមួយចំនួនដែលឲ្យរួចផុតពីសម្បថផងដែរ ដោយក្នុងនោះបុគ្គលដែលត្រូវបានស្តាប់ចម្លើយដោយមិនចំបាច់ធ្វើសម្បថក្រោមៈ

- ឪពុក ម្តាយ និងបុព្វជនគ្រប់រូបរបស់ជនត្រូវចោទ។
- កូនប្រុស កូនស្រី និងបច្ឆាជនគ្រប់រូបផ្សេងទៀតរបស់ជនត្រូវចោទ។
- បង ប្អូនប្រុស ស្រីរបស់ជនត្រូវចោទ។
- បង ប្អូនថ្លៃប្រុស ស្រីរបស់ជនត្រូវចោទ។
- ប្តី ឬប្រពន្ធរបស់ជនត្រូវចោទ ទោះបីបានលែងលះគ្នាហើយក៏ដោយ។
- កុមារអាយុតិចជាង១៨ឆ្នាំ[34]។

[31] មាត្រា៣១៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

[32] មាត្រា៣១៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

[33] មាត្រា៣២៨ , មាត្រា៣៣០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

[34] មាត្រា១៥៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

### ២.២ នីតិវិធីនៃការធ្វើសម្បថ

ក្រឡាបញ្ជីជាអ្នកដឹកនាំជនដែលជាសាក្សី អ្នកបកប្រែឲ្យធ្វើសម្បថមុននឹងការប្រកាសបើកសវនាការ។ ការធ្វើសច្ចាប្រណិធាន ត្រូវដឹកនាំដោយក្រឡាបញ្ជីមួយរូប ហើយត្រូវធ្វើនៅចំពោះមុខវត្ថុសក្តិសិទ្ធិនៅទីកន្លែងនៃតុលាការ។ មុននឹងចាប់ផ្តើមធ្វើសម្បថ អ្នកស្បថត្រូវអុជទៀន ធូប បូជាចំពោះវត្ថុសក្តសិទ្ធិដែលខ្លួនត្រូវស្បថនោះ។ បន្ទាប់មកក្រឡាបញ្ជីត្រូវអានប្រារព្វវាទខ្លាំងៗ ច្បាស់ៗ ឲ្យអ្នកស្បថស្តាប់ រួចអានពាក្យសច្ចាប្រណិធាន ឲ្យអ្នកស្បថថាតាម។

ក្រោយពីធ្វើសម្បថរួច ក្រឡាបញ្ជីត្រូវធ្វើកំណត់ហេតុដែលបានឲ្យស្បថនោះ បញ្ជាក់ថាបានធ្វើត្រឹមត្រូវហើយ សេចក្តីបានចេញវាចាឲ្យស្បថយ៉ាងណា ត្រូវកត់ក្នុងកំណត់ហេតុយ៉ាងនោះផង[35]។

## ផ្នែកទី២ លំដាប់លំដោយនៃនីតិវិធីជំនុំជម្រះ

### កថាខណ្ឌទី១ ការប្រកាសបើកសវនាការ

ការប្រកាសបើកសវនាការគឺធ្វើឡើងដើម្បីបើកការពិភាក្សាដេញដោលដើម្បីស្វែងរកឱ្យឃើញពីនត្ថិភាព ឬអត្ថិភាពនៃបទល្មើសមុននឹងតុលាការចេញសេចក្តីសម្រេច។ ទន្ទឹមនឹងនោះ កិច្ចនីតិវិធីនៃការបើកសវនាការមានដូចខាងក្រោម៖

#### ១.១ សវនាការជាសាធារណៈ

សវនាការលើរឿងក្តីព្រហ្មទណ្ឌធ្វើឡើងដោយធ្វើការពិភាក្សាដេញដោលជាសាធារណៈ ដោយបើកការអនុញ្ញាតឲ្យប្រជាពលរដ្ឋអាចចូលស្តាប់ឬជ្រាបច្បាស់អំពីចំណាត់ការរបស់តុលាការចំពោះរឿងក្តីព្រហ្មទណ្ឌ ថាតើតុលាការប្រតិបត្តិការកិច្ចនីតិវិធីដូចម្តេចដើម្បីឈានទៅដល់ការចេញសេចក្តីសម្រេចអំពីនត្ថិភាព ឬអត្ថិភាពនៃបទល្មើស។ ប៉ុន្តែ បើតុលាការយល់ឃើញថាការបើកជាសាធារណៈអាចបង្កឲ្យមានគ្រោះថ្នាក់ដល់សណ្តាប់ធ្នាប់សាធារណៈឬដល់ទំនៀមទម្លាប់ នោះតុលាការតាមសេចក្តីសម្រេចមានសម្អាងហេតុ អាចធ្វើការបង្គាប់ឲ្យការពិភាក្សាដេញដោលទាំងស្រុង ឬមួយផ្នែកជាការសម្ងាត់បាន។ តុលាការត្រូវសម្រេចតាមសេចក្តីសម្រេចមួយដាច់ដោយឡែកពីសាលក្រមអង្គសេចក្តី ឬតាមសេចក្តីសម្រេចពិសេសនៃសាលក្រមអង្គសេចក្តី។ យ៉ាងណាមិញសេចក្តីសម្រេចរបស់តុលាការដែលបង្គាប់ឲ្យធ្វើការពិភាក្សាដេញដោលជាសម្ងាត់នេះ មិនអាចប្តឹងតវ៉ាបានទេ[36]។

#### ១.២ នីតិវិធីនៃការប្រកាសបើកសវនាការ

ក្រឡាបញ្ជី ជាដឹកនាំនីតិវិធីនៅពេលប្រកាសបើកសវនាការដោយត្រូវអានបទបញ្ជាផ្ទៃក្នុងយ៉ាងតិច ២(ពីរ) ទៅ ៣ (បី) ដង និង ប្រាប់ទៅដល់ជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណី សាក្សី អ្នក

[35] ឧបសម្ព័ន្ធ ទំព័រ២០៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ខែសីហា ឆ្នាំ២០០៧

[36] មាត្រា ៣១៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ខែសីហា ឆ្នាំ២០០៧

ទទួលខុសត្រូវរដ្ឋប្បវេណី ជាអាទិ៍ឲ្យក្រោកឈរឡើងនឹងរក្សាភាពស្ងៀមស្ងាត់ នៅពេលដែលក្រុមប្រឹក្សាជំនុំជម្រះ ឬចៅក្រមទោលបានអញ្ជើញចូលមកកាន់សវនាការ។

បន្ទាប់ពីបានកោះហៅភាគីពាក់ព័ន្ធឲ្យចូលសវនាការហើយ ក្រឡាបញ្ជីត្រូវហៅឈ្មោះជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណី ជនរងគ្រោះ សាក្សី និងអ្នកជំនាញ ព្រមទាំងផ្ទៀងផ្ទាត់អត្តសញ្ញាណជនទាំងនោះដើម្បីរាយការណ៍ជូនតុលាការ។ កាលណាដើមបណ្តឹងរដ្ឋប្បវេណីត្រូវតំណាងដោយសហព័ទ្ធ ឬញាតិលោហិតផ្ទាល់ ក្រឡាបញ្ជីត្រូវពិនិត្យមើលអត្តសញ្ញាណនៃអ្នកតំណាង និងសុពលភាពនៃការប្រគល់សិទ្ធិ។ ចំពោះអ្នកទទួលខុសត្រូវរដ្ឋប្បវេណីក៏ត្រូវធ្វើដូចគ្នាផងដែរ។ ក្រឡាបញ្ជីត្រូវសុំយបល់ពីប្រធានសវនាការផងដែរក្នុងករណីចាំបាច់។ ភាគីនីមួយៗ អង្គុយនៅតាមកន្លែងដែលទុកសម្រាប់ឲ្យខ្លួន នៅក្នុងបន្ទប់សវនាការ។ ចំពោះជនជាប់ចោទមិនត្រូវទាក់ទងនឹងគ្នាទេ ។

ចំណែកឯអ្នកជំនាញ និងសាក្សីត្រូវថយខ្លួនទៅនៅក្នុងបន្ទប់រង់ចាំដែលទុកបម្រុងឱ្យខ្លួន ដោយនៅក្នុងបន្ទប់រងចាំនោះ ខ្លួនមិនអាចមើលឃើញ ឬ ឮអ្វីដែលប្រព្រឹត្តទៅនៅក្នុងបន្ទប់សវនាការទេ។ យ៉ាងណាមិញ នៅក្នុងសវនាការ និងនៅក្នុងបន្ទប់រងចាំ សាក្សីមិនត្រូវទាក់ទងនឹងគ្នាទេ[37]។ ដោយបុគ្គលទាំងនេះ ត្រូវរងចាំការកោះហៅពីប្រធានសវនាការឲ្យចូលខ្លួនមកចំពោះមុខតុលាការដើម្បីធ្វើការសួរចម្លើយ និងស្តាប់ចម្លើយដែលទាក់ទងនឹងរឿងក្តី។

## កថាខណ្ឌទី២ កិច្ចពិភាក្សាដេញដោល

ក្នុងរឿងក្តីព្រហ្មទណ្ឌ កិច្ចពិភាក្សាដេញដោលនាពេលសវនាការត្រូវបានដឹកនាំដោយចៅក្រម ទោលក្នុងករណីបទល្មើសជាបទមជ្ឈិម ឬបទហុ និងត្រូវបានដឹកនាំដោយប្រធានក្រុមប្រឹក្សាក្នុងករណី បើកការជំនុំជម្រះជាក្រុមប្រឹក្សាលើបទល្មើសជាបទឧក្រិដ្ឋ។ ដូចនេះ កិច្ចពិភាក្សាដេញដោលត្រូវបានចាប់ផ្តើមនាពេលប្រកាសបើកសវនាការដោយប្រធានក្រុមប្រឹក្សា ឬចៅក្រមទោល។ ក្នុងពេលប្រកាស បើកសវនាការចៅក្រមជំនុំជម្រះត្រូវប្រាប់សិទ្ធិជាមុន ដើម្បីឱ្យភាគីបានដឹងអំពីសិទ្ធិរបស់ខ្លួនក្នុងការនិយាយស្តីនាពេលសវនាការ និងសិទ្ធិអាចពឹងពាក់មេធាវីជាដើម។ បន្ទាប់ពីប្រធានសវនាការបានប្រាប់ សិទ្ធិដល់ភាគីបានជ្រាបហើយនោះ។ ប្រធានសវនាការចាប់ផ្តើមបើកកិច្ចពិភាក្សាដេញដោល ដោយជំហានដំបូង ត្រូវធ្វើការសួរចម្លើយជនជាប់ចោទ ស្តាប់ចម្លើយរបស់សាក្សី ដើមបណ្តឹងរដ្ឋប្បវេណី ឬអ្នកជំនាញផ្សេងទៀតតាមលំដាប់លំដោយ។ ក្នុងគោលបំណងដើម្បីស្វែងរកពត៌មានឱ្យបានគ្រប់ជ្រុងជ្រោយដើម្បីឈានទៅដល់ការចេញសេក្តីសម្រេចមួយដ៏ត្រឹមត្រូវ។

[37] មាត្រា ៣២២នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ខែសីហា ឆ្នាំ២០០៧

## ២.១ ការសួរនិងស្តាប់ចម្លើយ

ចៅក្រមជំនុំជម្រះការអាចធ្វើការសួរចម្លើយជនជាប់ចោទ និងស្តាប់ចម្លើយសាក្សីដើម្បីស្វែងរកឲ្យឃើញការពិតនៃដំណើរហេតុនៃបទល្មើសដែលបានកើតឡើង។ យ៉ាងណាមិញ ដើម្បីបានចម្លើយទៅតាមអ្វីដែលខ្លួនចង់បាន ចៅក្រមជំនុំជម្រះត្រូវមានបច្ចេកទេសច្បាស់លាស់ក្នុងការសួរចម្លើយជនជាប់ចោទ និងសាក្សី។ ចៅក្រមជំនុំជម្រះអាចធ្វើការសាកសួរដោយប្រើបច្ចេកទេសតាំងសំណួរដោយប្រើរូបមន្ត(5W + H) ដូចជា៖

- នរណា?
- អ្វី?
- ពេលណា?
- ហេតុអ្វី?
- របៀបណា?

### ២.១.១ ការសួរចម្លើយជនជាប់ចោទ

មុននឹងធ្វើការសួរចម្លើយជនជាប់ចោទ ចៅក្រមជំនុំជម្រះត្រូវប្រាប់ដល់ជនជាប់ចោទឲ្យបានដឹង អំពីបទល្មើសដែលតំណាងអយ្យការចោទប្រកាន់លើខ្លួនជាមុសិន។ចៅក្រមជំនុំជម្រះអាចសួរបានគ្រប់សំណួរដែលខ្លួនយល់ឃើញថាមានប្រយោជន៍ដល់ការសម្តែងឲ្យឃើញការពិត។ ចៅក្រមជំនុំជម្រះត្រូវមានករណីយកិច្ចសួរចម្លើយជនជាប់ចោទដែលចូលមកចំពោះមុខខ្លួន ទាំងខាងផ្នែកដាក់បន្ទុក និងផ្នែកដោះបន្ទុក[38]។ យ៉ាងណាមិញ ដើម្បីបានចម្លើយទៅតាមអ្វីដែលខ្លួនចង់បាន ចៅក្រមជំនុំជម្រះត្រូវមានបច្ចេកទេសច្បាស់លាស់ក្នុងការសួរចម្លើយជនជាប់ចោទផងដែរ។ ក្រោយពីការប្រាប់ឲ្យដឹងពីបទចោទប្រកាន់ទៅដល់ជនជាប់ចោទរួចហើយ ចៅក្រមជំនុំជម្រះអាចធ្វើការសួរសំណួរទៅជនជាប់ចោទនូវសំណួរទាំងឡាយណាដែលខ្លួនយល់ឃើញថាមានប្រយោជន៍ក្នុងការសម្តែងឱ្យឃើញការពិត។ចៅ ក្រមជំនុំជម្រះអាចប្រើលំដាប់លំដោយនៃការសាកសួរ ដោយធ្វើការសួរជាសំណួរលក្ខណៈទូទៅមានន័យថាឱ្យជនជាប់ចោទមានឱកាសក្នុងការនិយាយរៀបរាប់អំពីអង្គហេតុដែលបានកើតឡើង។ បន្ទាប់ពីទទួលបានពត៌មានសមល្មមហើយនោះ ចៅក្រមជំនុំជម្រះអាចធ្វើការសាកសួរជាសំណួរជាក់លាក់ ដើម្បីឲ្យជនជាប់ចោទផ្តល់ពត៌មានដែលពាក់ព័ន្ធនឹងអង្គហេតុឱ្យកាន់តែច្បាស់បន្ថែមទៀត។ ទន្ទឹមនឹងនោះ ការប្រើបច្ចេកទេសសួរសំណួរជាក់លាក់បែបនេះ ចៅក្រមជំនុំជម្រះមានបំណងចង់ដឹងថាតើជនជាប់ចោទអាចមានការប្រែប្រួលដែរឬទេ? មួយវិញទៀត ចៅក្រមជំនុំជម្រះអាចធ្វើការសាកសួរជាប្រភេទសំណួរបិទ គឺមានន័យថាជាប្រភេទសំណួរដែលជនជាប់ចោទមិនអាចឆ្លើយបង្វែរបានទេ។ ចម្លើយដែលត្រូវឆ្លើយគឺមានត្រឹមតែ **បាទ ឬ ចាស** តែប៉ុណ្ណោះ។ ដូចនេះ ចៅក្រមជំនុំជម្រះអាចនឹងទទួលបានពត៌មានគ្រប់ជ្រុងជ្រោយ បន្ទាប់ពីបានធ្វើការសាកសួរដេញដោលជនជាប់ចោទ។

[38] មាត្រា ៣២៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

មួយវិញទៀត ក្នុងករណីដែលជនជាប់ចោទមានភាពរឹងទទឹងក្នុងការឆ្លើយគេចវេស ឬមិនព្រម ទទួលស្គាល់នូវបទល្មើសដែលតំណាងអយ្យការបានធ្វើការចោទប្រកាន់នោះ។ ចៅក្រមជំនុំជម្រះ ឬតំណាងអយ្យការអាចបង្គាប់ឱ្យក្រឡាបញ្ជីសវនាការអានចម្លើយរបស់ជនជាប់ចោទ ដែលបានឆ្លើយនៅដំណាក់កាលនគរបាលយុត្តិធម៌ ដំណាក់កាលអយ្យការ និងដំណាក់កាលចៅក្រមស៊ើបសួរបាន។ ការបង្គាប់ឱ្យក្រឡាបញ្ជីអានកំណត់ហេតុសួរចម្លើយទាំងបីដំណាក់កាលខាងលើនេះ គឺ ក្នុងគោលបំណង ដាក់បន្ទុកចំពោះជនជាប់ចោទណា ដែលមានចេតនាទុច្ចរិតផ្តល់ចម្លើយផ្ទុយពីការពិតដែលបានកើតឡើងជូនដល់អង្គសវនាការ ព្រមទាំងជាវិធីសាស្ត្រមួយដើម្បីឱ្យជនជាប់ចោទអាចសារភាពអំពីអង្គហេតុពិតដែលបានកើតឡើងផងដែរ។

យ៉ាងណាមិញក្នុងករណីដែលជនជាប់ចោទជាបរទេស ឬ ជាជនគរ ថ្លង់ ដើម្បីធ្វើការសួរចម្លើយជនជាប់ចោទបានទៅយ៉ាងរលូន ចៅក្រមជំនុំជម្រះត្រូវរកជំនួយដូចជាអ្នកបកប្រែជាដើម ដោយអ្នកបកប្រែត្រូវតែធ្វើសម្បថជាមុនសិន ថាខ្លួនជាជំនួយដល់តុលាការ និងធ្វើការបកប្រែចម្លើយឱ្យបានស្មោះត្រង់ទោះបីជាក្នុងករណីណាក៏ដោយ។ មួយវិញទៀត អ្នកបកប្រែមិនត្រូវរើសចេញពីបុគ្គលដែលជាចៅក្រម ក្រឡាបញ្ជី នគរបាល កងរាជអាវុធហត្ថ គូភាគី ឬសាក្សីឡើយ[39]។

ក្រោយពីចៅក្រមជំនុំជម្រះសួរចម្លើយរួចហើយ ចៅក្រមជំនុំជម្រះអាចផ្តល់សិទ្ធិចំពោះព្រះរាជអាជ្ញា មេធាវី និងភាគីអាចលើកជាសំណួរសួរដល់ជនជាប់ចោទផងដែរ។ ទោះបីជាមានការផ្តល់សិទ្ធិឱ្យសាកសួរក៏ពិតមែន ប្រសិនបើតុលាការយល់ឃើញថាសំណួរដែលសួរទៅជនជាប់ចោទពុំមានហេតុដែលពាក់ព័ន្ធនឹងប្រយោជន៍ទេ ចៅក្រមជំនុំជម្រះត្រូវសម្រេចដោយឥតស្បូរចិត្ត ថាតើសំណួរនេះត្រូវសួរឬទេ[40]?

### ២.១.២ ការស្តាប់ចម្លើយ

ប្រធានសវនាការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី ជនរងគ្រោះ សាក្សី និងអ្នកជំនាញតាមលំដាប់លំដោយដែលខ្លួនយល់ឃើញថាប្រយោជន៍ក្នុងការស្តែងឱ្យឃើញពីការពិតដែលបានកើតឡើង។

ប្រធានសវនាការអាចស្តាប់នូវចម្លើយមន្ត្រី និងភ្នាក់ងារនគរបាលយុត្តិធម៌ដែលបានស៊ើបអង្កេតក្នុងឋានៈជាសាក្សី[41]។

ចំពោះការស្តាប់ចម្លើយរបស់សាក្សី គឺប្រធានសវនាការបានផ្តល់ពេលវេលាជាច្រើនដើម្បីឱ្យសាក្សីរៀបរាប់នូវអ្វីដែលខ្លួនបានដឹង ឬបានឃើញ ដោយករណីនេះ ប្រធានសវនាការត្រូវប្រើ

[39] មាត្រា ៣៣០, មាត្រា ៣៣១នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ខែសីហា ឆ្នាំ២០០៧

[40] មាត្រា ៣២៥នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ខែសីហា ឆ្នាំ២០០៧

[41] មាត្រា ៣២៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ខែសីហា ឆ្នាំ២០០៧

បច្ចេកទេសនៃការសាកសួរសំណួរជាប្រភេទសំណួរបើក។ ឧទាហរណ៍ ចូរអ្នករៀបរាប់នូវអ្វីខ្លះដែលអ្នកបានឃើញនូវកន្លែងកើតហេតុ?

ទន្ទឹមនឹងនោះ បន្ទាប់ពីបានស្តាប់នៃការរៀបរាប់របស់សាក្សីហើយ ប្រធានសវនាការអាចធ្វើការសាកសួរជាប្រភេទសំណួរជាក់លាក់ ដើម្បីទទួលបានពត៌មានច្បាស់លាស់ចំពោះចំណុចណាមួយដែលខ្លួនយល់ថាមានប្រយោជន៍នៅក្នុងការចេញសេចក្តីសម្រេចជាដើម។

## ២.២ ការពិនិត្យវត្ថុតាង

ប្រធានសវនាការអាចបង្គាប់ឱ្យជនណាម្នាក់បង្ហាញវត្ថុតាងបាន[42]។ ជាការពិតណាស់ដើម្បីធ្វើការវិនិច្ឆ័យបានត្រឹមត្រូវតុលាការត្រូវពឹងផ្អែកលើភស្តុតាងដែលទាក់ទងជាមួយសំណុំរឿងនោះ។ វត្ថុតាងក៏ត្រូវបានចាត់ទុកថាជាប្រភេទមួយនៃភស្តុតាងផងដែរ ពីព្រោះថាប្រសិនបើតុលាការធ្វើការសម្រេចដោយផ្អែកទៅលើតែបទបញ្ញត្តិច្បាប់ និងចម្លើយដែលទទួលបានពីជនរងគ្រោះ ជនជាប់ចោទ សាក្សីនោះ គឺពុំមានលក្ខណៈគ្រប់គ្រាន់នោះទេ។ដូច្នេះ ដើម្បីការសម្រេចសេចក្តីទទួលបានយុត្តិធម៌ និងមានភាពត្រឹមត្រូវ តុលាការត្រូវឱ្យបុគ្គលពាក់ព័ន្ធយកវត្ថុតាងមកបង្ហាញខ្លួននាពេលសវនាការបាន។ ទន្ទឹមនឹងនោះ វត្ថុតាងទាំងនោះអាច ជាអាវុធដែលជាមធ្យោបាយនៃការប្រព្រឹត្តបទល្មើស ឬវត្ថុផ្សេងៗទៀតដែលមានចំណងទាក់ទងជាមួយនឹងអំពើល្មើសនោះ។ ឧទាហរណ៍ បុគ្គល ក បានសម្លាប់បុគ្គល ខ ដោយប្រើដំបងវាយចំក្បាលពីខាងក្រោយ។ ដូចនេះវត្ថុតាងដែលត្រូវលើកយកពិនិត្យគឺជាដំបងដែលជនល្មើសបានប្រើដើម្បីវាយទៅលើជនរងគ្រោះ។ ដោយវត្ថុតាងទាំងនោះ អាចត្រូវបានរក្សាទុកនៅកន្លែងមានសុវត្ថិភាព និង ត្រូវបានបញ្ជូនមកកាន់តុលាការនាពេលបើកសវនាការ។ទន្ទឹមនឹងនោះ តុលាការក៏ត្រូវសម្រេចពីការប្រគល់វត្ថុដែលចាប់យក[43] ដោយការសម្រេចនេះអាចជាការប្រគល់វត្ថុដែលបានចាប់យកនោះជនម្ចាស់ដើមវិញ បើពិនិត្យឃើញថាពុំមានជាប់ពាក់ព័ន្ធជាមួយនឹងបទល្មើសដែលបានកើតឡើងទេនោះ ឬអាចសម្រេចរឹបអូសទុកជាទ្រព្យសម្បត្តិរបស់រដ្ឋ ឬអាចធ្វើការដុតបំផ្លាញចោល ដូចជាករណីគ្រឿងញៀន ឬទំនិញក្លែងក្លាយជាអាទិ៍។

## ២.៣ សិទ្ធិនិយាយស្តីរបស់ភាគីក្រោយបញ្ចប់កិច្ចពិភាក្សាដេញដោល

បន្ទាប់ពីប្រធានតុលាការធ្វើការសាកសួរ និងស្តាប់ចម្លើយ ជនជាប់ចោទ ជនរងគ្រោះ ដើមបណ្តឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី សាក្សី និងអ្នកជំនាញជាអាទិ៍នៅក្នុងដំណាក់កាលកិច្ចពិភាក្សាដេញដោលរួចមកហើយ ប្រធានសវនាការ(ចៅក្រមជំនុំជម្រះ)អាចបើកឱកាសឱ្យជនខាងក្រោមនេះនិយាយជាបន្តបន្ទាប់គ្នា ៖

- ដើមបណ្តឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី ជនជាប់ចោទ ដើម្បីធ្វើការកត់សំគាល់ខ្លីៗ
- មេធាវីរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីធ្វើសេចក្តីសន្និដ្ឋានការពារ
- ព្រះរាជអាជ្ញា ដើម្បីធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំ

[42] មាត្រា ៣៣២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

[43] មាត្រា ៣៥៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

- មេធាវីរបស់អ្នកទទួលខុសត្រូវរដ្ឋប្បវេណី មេធាវីរបស់ជនជាប់ចោទ ដើម្បីធ្វើសេចក្តីសន្និដ្ឋានការពារ។

ដើមបណ្តឹងរដ្ឋប្បវេណី និងព្រះរាជអាជ្ញា អាចឆ្លើយតបទៅវិញបាន។ ប៉ុន្តែជនជាប់ចោទ និងមេធាវីរបស់ខ្លួនត្រូវនិយាយនៅចុងក្រោយគេបង្អស់ជានិច្ច។ ទន្ទឹមនឹងការបំពេញទម្រង់ការនេះ ក្រឡាបញ្ជីត្រូវតែកត់ត្រាទុកក្នុងកំណត់ហេតុសវនាការ និងក្នុងសាលក្រម[44]។

## កថាខណ្ឌទី៣ ការប្រកាសថយទៅពិភាក្សា

បន្ទាប់ពីបានធ្វើកិច្ចពិភាក្សាដេញដោលរួចហើយ តុលាការបានថយចូលទៅបន្ទប់ពិភាក្សាដើម្បីធ្វើការពិភាក្សាសម្រេច។ ទន្ទឹមនឹងនោះ តុលាការត្រូវប្រកាសឱ្យអ្នកចូលរួមបានដឹងពីកាលបរិច្ឆេទ និងម៉ោងប្រកាសសាលក្រម។

### ៣.១ ការពិភាក្សាសម្រេចរបស់តុលាការ

តុលាការថយខ្លួនចូលទៅក្នុងបន្ទប់ដើម្បីសម្រេច។ ប្រសិនបើតុលាការបានធ្វើការពិភាក្សាហើយយល់ឃើញថា លទ្ធផលដែលបានមកពីការពិភាក្សាដេញដោលនាពេលសវនាការពុំមានលក្ខណៈគ្រប់គ្រាន់នោះ តុលាការអាចធ្វើការស្រាវជ្រាវថ្មីបន្ថែមជាការចាំបាច់ តុលាការអាចបង្គាប់តាមសាលក្រមឱ្យធ្វើការស៊ើបសួរបន្ថែម ដោយសាលក្រមដែលតុលាការចេញនេះជាសលក្រមចាត់របៀប ដើម្បីចាត់តាំងចៅក្រមឱ្យចៅក្រមទទួលភារកិច្ចនេះ។ ក្នុងករណីនេះ អ្នកដែលមានសមត្ថកិច្ចធ្វើការស៊ើបសួរបន្ថែមនេះអាចជាប្រធានសវនាការ ចៅក្រមមួយរូបនៃក្រុមប្រឹក្សាជំនុំជម្រះកាលណាតុលាការសម្រេចជាក្រុមសមូហភាព ឬចៅក្រមដទៃទៀត នៃតុលាការជាន់ដំបូង។ទន្ទឹមនឹងនោះ ចៅក្រមដែលទទួលបន្ទុកធ្វើការស៊ើបសួរបន្ថែមនេះមានអំណាចដូចជាចៅក្រមស៊ើបសួរដូចជាៈ

- ចុះទៅលើគ្រប់វិសាលភាពនៃដែនសមត្ថកិច្ចតុលាការ ឬលើគ្រប់វិសាលភាពនៃដែនដីជាតិ
- ស្តាប់ចម្លើយសាក្សី
- ធ្វើការឆែកឆេរ
- ចាប់យកវត្ថុតាង
- បង្គាប់ឱ្យធ្វើកោសលវិច័យ។

មួយវិញទៀត ដើម្បីអនុវត្តការស៊ើបសួរបន្ថែមក្នុងករណីខាងលើនេះ ចៅក្រមអាចចេញដីកាចាត់ឱ្យស៊ើបសួរជំនួសបានផងដែរ[45]។

[44] មាត្រា ៣៣៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

[45] មាត្រា ៣៣៧, មាត្រា ៣៣៩នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

## ៣.២ អានុភាពនៃការថយខ្លួនដើម្បីពិភាក្សាសម្រេច

ពេលដែលតុលាការ បានសម្រេចបញ្ចប់បិទកិច្ចពិភាក្សាដេញដោលហើយនោះតុលាការបាន ថយខ្លួនចូលទៅក្នុងបន្ទប់ដើម្បីពិភាក្សាសម្រេច។ ក្នុងករណីនេះ ភាគីទាំងអស់មិនអាចដាក់ពាក្យ បណ្តឹងណាមួយទៀតបានឡើយ និងមិនអាចលើកយកទឡ្ហីករណ៍ថ្មីណាមួយអាចលើកយកមក សំអាងទៀតបានឡើយ។ មួយវិញទៀត ការថយខ្លួនដើម្បីធ្វើការពិភាក្សាសម្រេចនោះមានតែ ចៅក្រមជំនុំជម្រះ ឬក្រុមប្រឹក្សាជំនុំជម្រះប៉ុណ្ណោះ។ ចំណែកឯព្រះរាជអាជ្ញា និងក្រឡាបញ្ជីមិនត្រូវ បានអនុញ្ញាតឱ្យចូលទៅពិភាក្សាសម្រេចបានឡើយ[46]។ ដូច្នេះការសម្រេចយ៉ាងណា គឺអាស្រ័យទៅ លើការពិភាក្សាគ្នាដោយផ្អែកលើបទប្បញ្ញត្តិច្បាប់ និងភស្តុតាងនានា ព្រមទាំងពត៌មានទាំងឡាយ ដែលមាននៅក្នុងកំណត់ហេតុសវនាការដែលកត់ត្រាដោយក្រឡាបញ្ជីសវនាការ នាអំឡុងពេល ដែលតុលាការធ្វើកិច្ចពិភាក្សាដេញដោលរហូតដល់ពេលប្រកាសបិទសវនាការ ។

[46] មាត្រា ៣៣៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

# ជំពូកទី៣ ៖
# សាលក្រម

## ផ្នែកទី១ ការតាក់តែងសាលក្រម

សាលក្រមព្រហ្មទណ្ឌ គឺជាសេចក្ដីសម្រេចលើរឿងក្ដីព្រហ្មទណ្ឌរបស់សាលាដំបូង បន្ទាប់ពីបានបើកសវនាការជំនុំជម្រះ ដោយធ្វើឡើងជាលាយលក្ខណ៍អក្សរ ហើយមានលក្ខណៈគ្រប់គ្រាន់តាម ទម្រង់ដែលកំណត់ដោយក្រមនីតិព្រហ្មទណ្ឌ[47]។

ការតាក់តែងសាលក្រម ជាជំហានមួយមុខនឹងប្រកាសសាលក្រម ការតាក់តែងសាលក្រមមួយមានលក្ខណៈតាមគតិយុត្តមួយយ៉ាងល្អ។ ដូច្នេះហើយយើងខ្ញុំមានការបែងចែកឱ្យបានច្បាស់លាស់ពីការរៀបចំតាមលំដាប់ កថាខណ្ឌទី១ ក្បាលនៃសាលក្រម កថាខណ្ឌទី២ សំអាងហេតុនៃសាលក្រម កថាខណ្ឌទី៣ ផ្នែកសម្រេចនៃសាលក្រម។

### កថាខណ្ឌទី១ ក្បាលសាលក្រម

ការតាក់តែងសាលក្រម ជាដំបូងនៃសាលក្រម គឺក្បាលនៃសាលក្រម នៅក្នុងក្បាលសាលក្រមជាដំបូង យើងត្រូវសរសេរពីនិទ្ទេស[48] នៅក្នុងនិទ្ទេសនៃសាលក្រមមានដូចជា៖

- កាលបរិច្ឆេទនៃការប្រកាសសាលក្រម
- ឈ្មោះ និងឋានៈរបស់ចៅក្រមដែលជំនុំជម្រះ
- ឈ្មោះ និងឋានៈតំណាងអយ្យការ
- ឈ្មោះ និងឋានៈតំណាងក្រឡាបញ្ជី
- ឈ្មោះ ទីលំនៅ កាលបរិច្ឆេទ និងទីកន្លែកំណើត មុខរបររបស់ជនជាប់ចោទរបស់ដើមបណ្ដឹងរដ្ឋប្បវេណី និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណី ។
- ឈ្មោះរបស់មេធាវី ។

ក្រោយពីបានសរសេរគោរពតាមនិទ្ទេសរួចមក ប៉ុន្តែនិទ្ទេសដែលត្រូវមានការសរសេរនៅក្បាលសាលក្រមមានការប្រែប្រួលទៅតាមប្រភេទនៃសាលក្រមនីមួយៗ ។

បន្ទាប់និទ្ទេសរួចខាងក្រោមនេះជាទំរងនៃសាលក្រម៖

ជាដំបូង ឈ្មោះប្រទេស និងបាវចនា

សញ្ញា និងឈ្មោះតុលាការ

លេខសំណុំរឿង និងលេខតុលាការ

---

[47] មាត្រា ៣៥៧ ,មាត្រា ៣៥៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

[48] មាត្រា ៣៥៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

# តាងនាមប្រជារាស្ត្រខ្មែរ

# សាលាដំបូង

បានបើកសវនាការជាសាធារណៈ\អសាធារណៈនៅថ្ងៃទី...... ខែ........ ឆ្នាំ........ ដែលមានសមាសភាព៖

## ចៅក្រមជំនុំជម្រះ \ ក្រុមប្រឹក្សាជំនុំជម្រះ

## ដើម្បីជំនុំជម្រះ

សរសេរទៅតាមករណីនីមួយៗដូចខាងក្រោម៖

១. ពាក់ព័ន្ធនឹងការសម្រេចឃុំខ្លួន ឬ មិនឃុំខ្លួនបណ្តោះអាសន្នលើជនជាប់ចោទឈ្មោះ..................

២. លើពាក្យបណ្តឹងសុំដោះលែងឱ្យមានសេរីភាព របស់ជនជាប់ចោទឈ្មោះ................................

៣. លើសំណុំរឿងព្រហ្មទណ្ឌលេខ............ ដែលមានជនជាប់ចោទឈ្មោះ...................................

៤. លើពាក្យបណ្តឹងស្រូបទោសរបស់ជនជាប់ចោទ\ ទណ្ឌិតឈ្មោះ..............................................

៥. លើពាក្យបណ្តឹងសុំបកស្រាយសាលក្រមលេខ.........................................................................

៦. លើពាក្យបណ្តឹងសុំកែតម្រូវរបស់ឈ្មោះ............. ចំពោះសាលក្រមលេខ.................................

ក្រោយពីការសរសេរតាមករណីខាងលើរួចហើយ បន្ទាប់មកសរសេរត្រង់ចំណុច "បានឃើញ" សរសេរទៅតាមករណីនីមួយៗ៖

- បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ...................... របស់អយ្យការ...........................
- បានឃើញ ដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះលេខ............... របស់ចៅក្រមស៊ើបសួរសាលាដំបូង..................
- បានឃើញ ដីកាបញ្ជូនរបស់សភាស៊ើបសួរលេខ........................
- បានឃើញ កំណត់ហេតុស្តីពីការបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាមលេខ.........................
- បានឃើញ សាលក្រមលេខ......... (ករណីបណ្តឹងសុំស្រូបទោស \ កែតម្រូវ \ បកស្រាយ
- បានឃើញ ពាក្យបណ្តឹងសុំ (ករណីសាលក្រមស្រូបទោស)

### ១.១ សំអាងហេតុ

សំអាងហេតុគឺទឡ្ហីករណ៍នៃអង្គហេតុនិងអង្គច្បាប់ដែលនាំឱ្យតុលាការចេញសេចក្តីសម្រេច[49]។ ការប្រើពាក្យពេចន៍ អក្ខរាវិរុទ្ធ នៅក្នុងសំអាងហេតុនេះផងដែរ ត្រូវមានការប្រើអោយបានត្រឹមត្រូវ ងាយយល់ សមហេតុផល គ្រប់ជ្រុងជ្រោយ ដែលរំលេចនូវការអប់រំ បណ្តុះបណ្តាល

[49] មាត្រា ៣៥៧.កថាកខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

ត្រូវតែច្បាស់លាស់ និងគ្មានការសង្ស័យ។ តុលាការត្រូវពិនិត្យមើលបទចោទនីមួយៗ និងទឡ្ហីករណ៍ដែលបានលើកឡើងនាពេលសវនាការ[50]។

ហើយថៅក្រមថ្លឹងថ្លែងដោយ ឥស្សរចិត្ត អំពីតម្លៃភស្តុតាងដែលគេដាក់មកឱ្យខ្លួនពិនិត្យដោយផ្អែកទៅលើ ជំនឿស្មោះត្រង់ពិតប្រាកដរបស់ខ្លួន។ តុលាការត្រូវសរសេរសំអាងហេតុនៅក្នុងសេចក្តីសម្រេចរបស់ខ្លួន ដោយផ្អែកលើភស្តុតាងដែលមានក្នុងសំណុំរឿង ឬដែលត្រូវគេយកមកបង្ហាញនៅពេលសវនាការប៉ុណ្ណោះ[51]។

ក្នុងការសរសេរនៅក្នុងសំអាងហេតុនេះ ផងដែរត្រូវសំអាងហេតុអំពីអង្គច្បាប់ ហើយមិនត្រូវមានភាពផ្ទុយគ្នា ឬ មានភាពផ្ទុយពីសេចក្តីសម្រេចឡើយ មានន័យថាការសរសេរសំអាងហេតុត្រូវមានភាពច្បាស់លាស់ដោយមិនមានការច្របូកច្របល់ក្នុងការវិនិច្ឆ័យដើម្បីឈានដល់ការចេញសេចក្តីសម្រេច។

ចំណុចចុងក្រោយនៃសំអាងហេតុ តុលាការត្រូវឆ្លើយតបទៅនឹងសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សររបស់គូភាគី[52]។ ហើយគប្បីសរសេរលេខរៀងតាមលំដាប់លំដោយ ពាក់ព័ន្ធនឹងអង្គហេតុដែលបានបញ្ជូនមកជំនុំជម្រះ ព្រោះអាចប្រែប្រួលទៅតាមភស្តុតាងដែលបានរកឃើញបន្ទាប់ពីបានធ្វើកិច្ចពិភាក្សាដេញក្នុងពេលសវនការ។

### ១.២ ផ្នែកសម្រេចនៃសាលក្រម

ផ្នែកសម្រេចនៃសាលក្រម គឺជាការសម្រេចរបស់តុលាការ[53]។ ការសរសេរផ្នែកសម្រេចត្រូវមានការចុះនិទ្ទេស អំពីបទល្មើសដែលជនជាប់ចោទបានប្រព្រឹត្តខុសអត្ថបទច្បាប់ដែលត្រូវអនុវត្តទោស និងទណ្ឌកម្មរដ្ឋប្បវេណី[54]។ ទន្ទឹមនឹងនោះ ផ្នែកសម្រេចនៃសាលក្រមត្រូវតែស្របនឹងសំអាងហេតុ។ ក្នុងករណីតុលាការសម្រេចអំពីផលប្រយោជន៍រដ្ឋប្បវេណី[55]។ តុលាការត្រូវតែមានការសរសេរនៅក្នុងសំអាងហេតុដើម្បីបញ្ជាក់អំពីអង្គហេតុដែលទាក់ទងនឹងការទាមទាររបស់ដើមបណ្តឹងនិងចុងចម្លើយរដ្ឋប្បវេណី ឬ អំពីព្យសនកម្មដែលបានកើតឡើងផងដែរ ។

បើក្នុងករណីថាអំពើប្រព្រឹត្តមិនមែនជាបទល្មើស ឬ ជនជាប់ចោទគ្មានកំហុសតុលាការត្រូវសម្រេច "ឱ្យរួចពីបទចោទ"[56]។

---

[50] មាត្រា ៣៥៧.កថាកខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

[51] មាត្រា ៣២១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

[52] មាត្រា ៣៥៧.កថាកខណ្ឌទី៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

[53] មាត្រា ៣៥៧.កថាកខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

[54] មាត្រា ៣៥៧.កថាកខណ្ឌទី៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

[55] មាត្រា ៣៥៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

[56] មាត្រា ៣៥០.កថាកខណ្ឌទី៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

ប៉ុន្តែបើក្នុងករណីដែលសាលក្រមលើបណ្តឹងស្រុបទោស ត្រូវគោរពតាម មាត្រា ៥០១ ពាក្យសុំឱ្យស្រុបទោសបញ្ចូលគ្នា ត្រូវលើកឡើងនៅមុខតុលាការដែលបានសម្រេចចុងក្រោយគេ។ តុលាការនេះទទួលបណ្តឹង តាមពាក្យប្តឹងរបស់តំណាងអយ្យការ ឬរបស់ភាគីពាក់ព័ន្ធ។ តុលាការសម្រេចក្នុងពេលសវនាការសាធារណៈ ក្រោយពីបានស្តាប់តំណាងអយ្យការ ភាគីពាក់ព័ន្ធ និងជាយថាហេតុមេធាវីរបស់ភាគីនេះ[57]។

## ផ្នែកទី២ ប្រភេទសាលក្រម

ចំពោះប្រភេទសាលក្រម នៅក្នុងរឿងក្តីព្រហ្មទណ្ឌគឺពុំមានមាត្រាណាមួយនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ បានបញ្ញត្តិច្បាស់ថាមានប៉ុន្មានប្រភេទនោះទេ។ ប៉ុន្តែបើពិនិត្យឱ្យបានច្បាស់ យើងឃើញថាទោះបីជាក្នុងក្រមនីតិវិធីពុំមានបញ្ញត្តិច្បាស់អំពីប្រភេទនៃសាលក្រមក៏ដោយ យើងនៅតែអាចធ្វើការបែងចែកប្រភេទនៃសាលក្រមបានដែរ។ យើងដឹងហើយថា ក្នុងរឿងក្តីព្រហ្មទណ្ឌ តុលាការធ្វើការជំនុំជម្រះដើម្បីវិនិច្ឆ័យចេញសេចក្តីសម្រេចអំពីរឿងអង្គសេចក្តីដែលមាននៅក្នុងសំណុំរឿង ដោយសេចក្តីសម្រេចនេះគេហៅថា "សាលក្រមអង្គសេចក្តី"។ មួយវិញទៀត ក្រមនីតិវិធីក៏បើកសិទ្ធិឱ្យចៅក្រមជំនុំជម្រះចេញសេចក្តីសម្រេចទាក់ទងលើបញ្ហារឿងមុនអង្គសេចក្តីបានដែរបើសិនជាមាន ករណីចាំបាច់។ ហេតុដូចនេះ ការចេញសេចក្តីសម្រេចអំពីបញ្ហានានាដែលបានកើតឡើងក្រៅពីរឿងអង្គសេចក្តី មុននឹងឈានទៅដល់ចំណាត់ការលើរឿងអង្គសេចក្តី គឺហៅថា "សាលក្រមនីតិវិធី"។

ដូចនេះ ដើម្បីយល់ច្បាស់អំពីប្រភេទនៃសាលក្រមដែលបានលើកឡើងនៅផ្នែកខាងលើនេះ។ យើងគប្បីធ្វើការបែងចែកជាពីរកថាខណ្ឌដើម្បីធ្វើការបកស្រាយដូចខាងក្រោមនេះ៖

### កថាខណ្ឌទី១ សាលក្រមលើអង្គសេចក្តី

សាលក្រមលើអង្គសេចក្តី គឺសាលក្រមមួយប្រភេទដែរការសម្រេចរបស់តុលាការដែលមានសមត្ថកិច្ចអាចចេញសេចក្តីសម្រេចទៅលើបញ្ហារឿងក្តីអង្គសេចក្តីនៅក្នុងរឿងក្តីព្រហ្មទណ្ឌ ។ ដើម្បីអោយមានការយល់អោយបានច្បាស់ផងដែរ ក្នុងសាលក្រមលើអង្គសេចក្តីនោះ យើងនឹងមានការបែងចែកសាលក្រមដូចខាងក្រោម ៖

#### ១.១ សាលក្រមកំបាំងមុខ

ប្រសិនបើជនជាប់ចោទមិនចូលបង្ហាញខ្លួននៅពេលសវនាការទេ ព្រមទាំងគ្មានភស្តុងតាងបង្ហាញឱ្យឃើញថាសាមីខ្លួនមិនបានដឹងអំពីដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឬមិនបានដឹងអំពីការកោះហៅនោះទេ សាលក្រមត្រូវប្រកាសដោយកំបាំងមុខជនជាប់ចោទ។ សាលក្រមកំបាំងមុខជនជាប់ចោទ ត្រូវឱ្យដំណឹងដល់ជនជាប់ចោទនេះ ។ សាលក្រមនេះអាចត្រូវប្តឹងទាស់បាន [58]។

[57] មាត្រា ៥០១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

[58] មាត្រា ៣៦២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

សាលក្រមកំបាំងមុខ គឺជាសេចក្តីសម្រេចមួយប្រភេទ របស់តុលាការព្រហ្មទណ្ឌដែលបានសម្រេចលើអង្គសេចក្តីចំពោះភាគីនៅក្នុងរឿងក្តីព្រហ្មទណ្ឌដែលអវត្តមាននៅពេលសវនាការ ។

ការប្រកាសសាលក្រមដែលចេញចំពោះដើមបណ្តឹងរដ្ឋប្បវេណី ប្រសិនបើដើមបណ្តឹងមិនចូលបង្ហាញខ្លួននៅពេលសវនាការទេ និងគ្មានអ្នកតំណាងត្រឹមត្រូវទេ សាលក្រមត្រូវប្រកាសដោយកំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី។ សាលក្រមកំបាំងមុខនេះ ត្រូវជូនដំណឹងដល់ដើមបណ្តឹងរដ្ឋប្បវេណី។ សាលក្រមនេះអាចប្តឹងទាស់បាន[59]។

ក្នុងលក្ខណៈនេះ ប្រសិនបើដើមបណ្តឹងរដ្ឋប្បវេណី ឬអ្នកតំណាងត្រឹមត្រូវតាមច្បាប់បានអវត្តមាន នៅពេលសវនាការ ឬពេលប្រកាសសាលក្រម ការប្រកាសសាលក្រមជាសាលក្រមកំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី។ ចំពោះពាក្យដែលអ្នកតំណាងត្រឹមត្រូវ អាចជាមេធាវី ដែលដើមបណ្តឹងរដ្ឋប្បវេណី បានផ្ទេរសិទ្ធិអ្នកនាមជាដើមបណ្តឹងរដ្ឋប្បវេណី ។

ចំពោះការប្តឹងទាស់នឹងសាលក្រមកំបាំងមុខ ពិរុទ្ធជនអាចធ្វើបណ្តឹងទាស់នឹងសាលក្រមដែលប្រកាសដោយកំបាំងមុខខ្លួនបាន [60]។

+ រយៈវេលាសម្រាប់ធ្វើបណ្តឹងទាស់នឹងសាលក្រមកំបាំងមុខ៖

បណ្តឹងទាស់ត្រូវតែធ្វើនៅក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ ផ្តើមគិតចាប់ពី៖

- ពីថ្ងៃជូនដំណឹងអំពីសាលក្រមកំបាំងមុខ កាលណាសាលក្រមត្រូវបានប្រគល់ឱ្យពិរុទ្ធជនដោយផ្ទាល់ដៃ ឬ
- ពីថ្ងៃដែលពិរុទ្ធជននេះបានដឹងយ៉ាងពិតប្រាកដអំពីសាលក្រម កាលណាសាលក្រម កាលណាសាលក្រមនេះមិនបានប្រគល់ឱ្យដល់ពិរុទ្ធជនដោយផ្ទាល់ដៃទេ

**+ អានុភាពនៃសាលក្រមកំបាំងមុខ**

សាលក្រមកំបាំងមុខ មានអានុភាពចាប់ពីពេលសេចក្តីជូនដំណឹងពីសាលក្រមកំបាំងមុខនេះ។ ការជូនដំណឹងដល់ពិរុទ្ធជន ចំពោះសាលក្រមកំបាំងមុខ បានធ្វើឡើងតាមរយៈដីកាដែលដីកានោះគេឱ្យឈ្មោះថាដីកាឱ្យដំណឹង ។ ក្នុងការដីកាឱ្យដំណឹង ដោយយោងតាមមាត្រា៤៨២ ដល់មាត្រា ៤៩០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ គេត្រូវមានការបែកចែកជាពីរគឺ៖

- ការឱ្យដំណឹងតាមការជាក់ស្តែង ឬដោយផ្ទាល់ និង
- ការឱ្យដំណឹងតាមការសន្មត់

ការឱ្យដំណឹងតាមការជាក់ស្តែង ឬដោយផ្ទាល់ គឺជាគោលការណ៍គ្រប់ភាគីពាក់ព័ន្ធទាំងអស់ត្រូវបានទទួលដំណឹងអំពីសេចក្តីសម្រេចរបស់តុលាការ ដោយផ្ទាល់ដៃដោយដីកាឱ្យដំណឹងដែលត្រូវភ្ជាប់ដោយលិខិតចម្លងនៃសេចក្តីសម្រេចនោះ ។

ការឱ្យដំណឹងតាមការសន្មត់ គឺការកើតឡើងតាមស្ថានភាពធ្វើឡើងដូចជា៖

---

[59] មាត្រា ៣៦៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

[60] មាត្រា ៣៦៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

- **ភាគីពាក់ព័ន្ធអវត្តមានពីលំនៅឋាន** ប្រសិនបើភាគីអវត្តមានពីលំនៅឋាន អាជ្ញាសាលាត្រូវប្រគល់លិខិតចម្លងនៃសេចក្តីសម្រេចឱ្យបុគ្គល ដែលជានីតិជនដែលមានវត្តមាននៅក្នុងលំនៅឋាន ។
- **ប្រសិនបើភាគីពាក់ព័ន្ធកំពុងជាប់ឃុំពីបទល្មើសដៃទៀត** ត្រូវបានការឱ្យដំណឹងប្រគល់ទៅឱ្យប្រធានពន្ធនាគារ ឬ មណ្ឌលឃុំខ្លួន ហើយប្រធានពន្ធនាគារ ឬ មណ្ឌលឃុំខ្លួនមានតួនាទីដូចព្រះរាជអាជ្ញាដែរ ។
- **ប្រសិនបើភាគីពាក់ព័ន្ធពុំមានលំនៅដ្ឋាន ឬ ទីស្នាក់ការដែលគេស្គាល់ ឬរស់នៅក្រៅដែនជាតិ** តុលាការចាំបាច់ត្រូវធ្វើការផ្សព្វផ្សាយជាសារធារណៈអាចតាមរយៈការសែត វិទ្យុជាតិ និងអន្តរជាតិ ឬទូរស្សន៍ជាតិ និងអន្តរជាតិជាដើម ។

## ១.២ សាលក្រមដែលត្រូវចាត់ទុកថាចំពោះមុខ

សាលក្រមដែលត្រូវចាត់ទុកថាចំពោះមុខ គឺជាសាលក្រមមួយប្រភេទដែល ជនជាប់ចោទមិនចូលមកបង្ហាញខ្លួននៅពេលសវនាការទេ ប៉ុន្តែ សាមីខ្លួនបានដឹងអំពីដីកាបញ្ជូនទៅជំនុំជម្រះផ្ទាល់ ឬបានដឹងពីការកោះហៅហើយនោះ[61]។

ចំពោះសាលក្រមដែលត្រូវចាត់ទុកថាចំពោះមុខ នេះផងដែរត្រូវតែមានការជូនដំណឹងដល់ជនជាប់ចោទ មានន័យថាសាលក្រមនេះជនជាប់ចោទបានដឹងអំពីសាលក្រម ហើយបានដឹងអំពីថ្ងៃចូលមកកាន់សវនាការដែរ ប៉ុន្តែជនជាប់ចោទនោះមិនព្រមចូលមកកាន់សវនាការ។

ចំពោះការមិនចូលរួមរបស់ជនជាប់ចោទក្នុងការប្រកាសសាលក្រមនេះផងដែរ មិនមែនអោយតែភាពអវត្តមានរបស់ជនជាប់ចោទ តុលាការអាចប្រកាសសាលក្រមនោះបានទេ ហើយចាត់ទុកថាសាលក្រមដែលត្រូវចាត់ទុកថាចំពោះមុខបានទេ ។ ការអវត្តមានក្នុងក្រមត្រូវបានមានការបែកចែង ការអវត្តមានដោយគ្មានមូលហេតុសមស្រប និងការមានមូលហេតុសមស្របដែលតុលាការបានទទួលថាត្រឹមត្រូវ ។

តើមូលហេតុអ្វីទៅដែរចាត់ទុកជាមូលហេតុមិនសមស្រប ហើយអ្វីទៅដែរចាប់ទុកថាមូលហេតុសមស្រប ?

ការមិនចូលរួម ឬមិនបង្ហាញខ្លួននៅពេលសវនាការ ដោយមូលហេតុណាមួយដែលតុលាការគិតថាជាមូលហេតុសមស្រប ឬមូលហេតុមិនសមស្រប ។ មូលហេតុដែលតុលាការដែលមានការចាត់ទុកថាមូលហេតុសមស្រប ជាមូលហេតុមួយដែលជនជាប់ចោទ មានធុរៈផ្ទាល់ខ្លួនជាសំខាន់ដូចជា៖ មូលហេតុនៃជម្ងឺ ការរស់នៅប្រទេស, អ្នកនៅក្នុងគ្រួសារបានទទួលមរណៈភាពជាដើម, មូលហេតុធ្ងន់ធ្ងរនៃជម្ងឺ ។ មានមូលហេតុមួយចំនួនដែលតុលាការបានបដិសេធចំពោះមូលហេតុមួយចំនួនដូចជា ៖ មានការរវល់ធ្វើការងារផ្ទាល់ខ្លួនដោយមិនចូលរួម និងមូលហេតុផ្សេងទៀត ។

---

[61] មាត្រា ៣៦១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

ការប្តឹងទៅឧទ្ធរណ៍ ចំពោះសាលក្រមដែលត្រូវចាត់ទុកថាចំពោះមុខ នេះតុលាការបានបើកសិទ្ធិអោយជនជាប់ចោទ ការប្តឹងទៅឧទ្ធរណ៍បាន ។

## ១.៣ សាលក្រមចំពោះមុខ

ប្រសិនបើជនជាប់ចោទបានចូលបង្ហាញខ្លួននៅពេលសវនាការ នោះសាលក្រមជាសាលក្រមចំពោះមុខជនជាប់ចោទ ។ សាលក្រមចំពោះមុខជនជាប់ចោទមិនត្រូវឱ្យដំណឹងដល់ជននោះទេ។ សាលក្រមចំពោះមុខអាចត្រូវប្តឹងឧទ្ធរណ៍បាន ។

សាលក្រមនៅតែជាសាលក្រមចំពោះមុខដដែល ទោះបីជនជាប់ចោទចាកចេញពីបន្ទប់សវនាការក៏ដោយ ។

សាលក្រមក៏ជាសាលក្រមចំពោះមុខដែរ កាលណាជនជាប់ចោទត្រូវបានសួរចម្លើយនៅក្នុងលក្ខខណ្ឌដែលមានចែងនៅមាត្រា ៣០៩ (ជនជាប់ចោទដែលពុំអាចចូលបង្ហាញខ្លួន)នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧[62]។

**+ លក្ខណៈដែលចាត់ទុកថាសាលក្រមចំពោះមុខ**

នៅក្នុងមាត្រា ៣៦១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ បានកំណត់ពីលក្ខណសាលក្រមចំពោះមុខរបស់ជនជាប់ចោទ នៅក្នុងមាត្រានោះផងដែរមានការកំណត់អំពីលក្ខណៈមួយចំនួនដែលចំពោះទុកថាចំពោះមុខនៃជនជាប់ចោទ ៖

- ការចូលបង្ហាញខ្លួនរបស់ជនជាប់ចោទនៅពេលសវនាការ
- ការចូលបង្ហាញខ្លួនរបស់ជនជាប់ចោទនៅពេលសវនាការ ប៉ុន្តែជនជាប់ចោទនោះបានចេញពីបន្ទប់សវនាការ មុនពេលប្រកាសសាលក្រមក៏ដោយ
- ការចាត់ទុកថាចំពោះមុខផងដែរ ដែលបានកំណត់ជនជាប់ចោទក្នុងមាត្រា ៣០៩ (ជនជាប់ចោទដែលពុំអាចចូលបង្ហាញខ្លួន) នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ ។

ក្រោយពីបានកំណត់អំពីការចាត់ទុកថាចំពោះមុខចំពោះជនជាប់ចោទ ការប្រកាសសាលក្រមនឹងមានអនុភាពចាប់ពីពេលប្រកាសសាលក្រមនោះតែម្តង ហើយចំពោះការជូនដំណឹងទៅជនជាប់ចោទក៏មិនមានការជូនដំណឹងទេ ពីព្រោះជនជាប់បានដឹង និងបានចូលរួមក្នុងសវនាការរួចមកហើយ ។

ក្រោយពីតុលាការបានប្រកាសសាលក្រមរួច ជនជាប់ចោទមានសិទ្ធិក្នុងការប្តឹងទៅឧទ្ធរណ៍ចំពោះ សាលក្រមចំពោះមុខរបស់ខ្លួនតាមរយៈពេលដូចខាងក្រោម៖

- ១ (មួយ) ខែចំពោះបណ្តឹងឧទ្ធរណ៍របស់ពិរុទ្ធជន ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណី ដែលផ្តើមគិតពីពេលប្រកាសសាលក្រម[63]។
- ១ (មួយ) ខែចំពោះបណ្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញាដែលផ្តើមគិតពីពេលប្រកាសសាលក្រម

[62] មាត្រា ៣៦០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

[63] មាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

- ៣ (បី) ខែចំពោះបណ្តឹងឧទ្ធរណ៍របស់អគ្គព្រះរាជអាជ្ញា ដែលផ្តើមគិតពីពេលប្រកាសសាលក្រម[64]។

## កថាខណ្ឌទី២ សាលក្រមនីតិវិធី

សាលក្រមនីតិវិធី ជាសាលក្រមមួយប្រភេទដែលសម្រេចទាក់ទងនឹងបញ្ហានីតិវិធីផ្សេងៗមុននឹងឈានដល់ចំណាត់ការលើរឿងអង្គសេចក្តី។ទន្ទឹមនឹងនោះ ការចេញសេចក្តីសម្រេចអំពីបញ្ហានីតិវិធីនេះគឺមិនមានផលប៉ះពាល់បញ្ហាសារធាតុ ឬ អង្គសេចក្តីនៃរឿងក្តីនោះទេ ។ សាលក្រមនេះយើងមានការបែងចែកជា ពីរប្រភេទគឺ សាលក្រមមុនអង្គសេចក្តី និងសាលក្រមចាត់របៀប។

### ២.១ សាលក្រមមុនអង្គសេចក្តី

សាលក្រមមុនអង្គសេចក្តី ជាសាលក្រមមួយប្រភេទមិនដូចគ្នានឹងសាលក្រមលើអង្គសេចក្តី និងនិងសាលក្រមចាត់របៀបនោះទេ ។ សាលក្រមមុនអង្គសេចក្តី ជាសាលក្រមមួយដែលតុលាការចេញសេចក្តីសម្រេចទាក់ទងនឹងបញ្ហាសេរីភាពរបស់ជនជាប់ចោទ ហើយមិនប៉ះពាល់នឹងបញ្ហានៃរឿងក្តីអង្គសេចក្តី ឬ ដំណើរការនៃនីតិវិធីណាមួយដែលតុលាការនឹងចាត់របៀបនោះទេ។ ពោល គឺតុលាការសម្រេចសេចក្តីតែអំពីការឃុំខ្លួនជនជាប់ចោទបណ្តោះអាសន្ន ឬ ការបង្គាប់ឱ្យដោះលែងជនជាប់ចោទ ឱ្យមានសេរីភាព មុនពេលមានការសម្រេចដល់រឿងអង្គសេចក្តី ។

ក្រៅពីការឃុំខ្លួនជនជាប់ចោទបណ្តោះអាសន្ន តុលាការអាចចេញសាលក្រមបង្គាប់ឱ្យដោះលែងជនជាប់ចោទឱ្យមានសេរីភាព ឬ បន្តការឃុំខ្លួនជនជាប់ចោទដោយឯកឯង ឬ តាមបណ្តឹងសុំឱ្យដោះលែងឱ្យមានសេរីភាពរបស់ជនជាប់ចោទដែលជាប់ឃុំ[65] ។

ដើម្បីសម្គាល់សាលក្រមមួយជាសាលក្រមមុនអង្គសេចក្តី វាមិនខុសពីរបៀបនៃការសម្គាល់សាលក្រមលើអង្គសេចក្តី និងសាលក្រមចាត់របៀបទេ ។ យើងត្រូវពិនិត្យផ្នែកសេចក្តីសម្រេចនៃសាលក្រមនោះ ។ ក្នុងសាលក្រមមុនអង្គសេចក្តីអាចមានសេចក្តីសម្រេចតែពីរប្រភេទប៉ុណ្ណោះ គឺការសម្រេចឃុំខ្លួនជនជាប់ចោទបណ្តោះអាសន្ន ឬ ដោះលែងជនជាប់ចោទឱ្យមានសេរីភាពវិញ ។ ការសម្រេចទាំងពីរនេះត្រូវធ្វើមុនពេលដែលតុលាការសម្រេចដល់រឿងក្តីអង្គសេចក្តី ។

ការដែលឱ្យឈ្មោះថាសាលក្រមខាងលើនេះជាសាលក្រមសម្រេចមុនអង្គសេចក្តី ហើយមិនចាត់ចូលជាប្រភេទនៃសាលក្រមលើអង្គសេចក្តី ឬសាលក្រមចាត់របៀបនោះដោយមូលហេតុដូចខាងក្រោម ៖

-សាលក្រមនេះ មិនមែនជាសេចក្តីសម្រេចចុងក្រោយរបស់តុលាការដែលទាក់ទងនឹងរឿងលើអង្គសេចក្តី ហើយសេចក្តីសម្រេចក្នុងសាលក្រមនេះក៏មិនប៉ះពាល់ដល់រឿងលើអង្គសេចក្តីដែរ ពោល គឺវាពុំមែនជាមូលដ្ឋានដែលនាំឱ្យតុលាការសម្រេចអំពីការមានពិរុទ្ធ ឬ គ្មានពិរុទ្ធលើជនជាប់ចោទទេ ។

---

[64] មាត្រា ៣៨១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

[65] មាត្រា ៣០៦ ដល់ ៣០៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

-សាលក្រមនេះ ជាសេចក្តីសម្រេចមួយរបស់តុលាការជំនុំជម្រះ ក្នុងគោលបំណងធានានូវវត្តមានជនជាប់ចោទនៅចំពោះមុខតុលាការជំនុំជម្រះ ឬ ធានានូវសិទ្ធិមានសេរីភាពរបស់ជនជាប់ចោទហើយមានលក្ខណៈស្រដៀងទៅនឹងវិធានការណ៍និរន្តរាយ ការឃុំខ្លួនបណ្តោះអាសន្នរបស់ចៅក្រមស៊ើបសួរ ។

-សាលក្រមនេះមិនអាចជាសាលក្រមចាត់របៀបនេះទេ ព្រោះសាលក្រមនេះ សម្រេចទាក់ទងនឹងសិទ្ធិសេរីភាពរបស់ជនជាប់ចោទ ដោយមិនសម្រេចអំពីបញ្ហានីតិវិធីដែលតុលាការត្រូវធ្វើ ឬការចាត់ឱ្យធ្វើនីតិវិធីណាមួយទេ ។ មួយវិញទៀត សាលក្រមនេះអាចត្រូវបានប្តឹងឧទ្ធរណ៍ដោយព្រះរាជអាជ្ញាបាន ប្រសិនបើតុលាការចេញសាលក្រមបង្គាប់ឱ្យដោះលែងជនជាប់ចោទ[66]។ កត្តានេះហើយដែលសបញ្ជាក់ឱ្យឃើញលក្ខណៈមួយដែលខុសគ្នាពីសាលក្រមចាត់របៀប។

## ២.២ សាលក្រមចាត់របៀប

ក្រមនីតិវិធីព្រហ្មទណ្ឌ មិនបានផ្តល់និយមន័យអំពីសាលក្រមចាត់របៀបឱ្យបានច្បាស់លាស់នោះទេ។ប៉ុន្តែសាលក្រមនេះគេឃើញមានប្រើប្រាស់នៅក្នុងមាត្រា ៣៨៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ យោងតាមស្មារតីនៃក្រមនីតិវិធីព្រហ្មទណ្ឌ សាលក្រមចាត់របៀបគឺជាសេចក្តីសម្រេចរបស់តុលាការជំនុំជម្រះដែលមិនពាក់ព័ន្ធដល់អង្គសេចក្តី។ សាលក្រមនេះស្តែងឡើងតាមរូបភាពជាសាលក្រមបញ្ចប់នីតិវិធី ឬ សាលក្រមបង្គាប់ឱ្យស៊ើបសួរបន្ថែម ។

សាលក្រមចាត់របៀប គឺជាសេចក្តីសម្រេចចេញក្នុងពេលដំណើរការនីតិវិធីដើម្បីរៀបចំស៊ើបអង្កេត ឬ រកដំណោះស្រាយជាបណ្តោះអាសន្ននូវស្ថានភាពណាមួយ ។

សាលក្រមចាត់របៀប គឺជាសាលក្រមមួយប្រភេទដែលតុលាការចេញដើម្បីដោះស្រាយបញ្ហានីតិវិធី ឬ ដើម្បីស្វែងរកនូវព័ត៌មានណាមួយសម្រាប់ជាមូលដ្ឋានចេញសាលក្រមលើអង្គសេចក្តី។ សាលក្រមរបៀបនេះ មិនសម្រេចលើបញ្ហារឿងអង្គសេចក្តីដូចក្នុងសាលក្រមលើអង្គសេចក្តីទេ ។ ហេតុនេះ សាលក្រមព្រហ្មទណ្ឌទាំងឡាយ ដែលមានសេចក្តីសម្រេចទាក់ទងនឹងការចាត់ឱ្យធ្វើនីតិវិធីទាក់ទងនឹងដំណើរការ ឬ ជាការដោះស្រាយនៃនីតិវិធីណាមួយក្នុងរឿងព្រហ្មទណ្ឌ ត្រូវបានគេឱ្យឈ្មោះថា សាលក្រមចាត់របៀប ។

គេអាចធ្វើការកត់សម្គាល់ថា សាលក្រមមួយជាសាលក្រមចាត់របៀបបាន តាមរយៈការពិនិត្យផ្នែកសេចក្តីសម្រេចក្នុងលិខិតសាលក្រម។ ប្រសិនបើ តុលាការបានសម្រេចបញ្ហានីតិវិធីណាមួយដែលតុលាការត្រូវធ្វើមុនដំណាក់កាលសម្រេចលើរឿងអង្គសេចក្តី។ ប៉ុន្តែបញ្ហានីតិវិធីណាមួយដែលតុលាការអាចសម្រេចក្នុងសាលក្រមចាត់របៀបនេះ ដែលត្រូវបានកម្រិតដោយក្រមនីតិវិធីព្រហ្មទណ្ឌ មានន័យថាតុលាការមិនអាចសម្រេចចាត់របៀបធ្វើអ្វីមួយដែលគ្មានចែងក្នុងច្បាប់នោះទេ។មួយវិញទៀត ចំពោះការសម្រេចសេចក្តីនេះទាក់ទិននឹងនីតិវិធីណាមួយដូចជាៈ

[66] មាត្រា ៣០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

- ការបង្វិលសំណុំរឿងជូនព្រះរាជអាជ្ញា[67] ៖ ក្នុងករណីដែលតុលាការបានទទួលពាក្យបណ្តឹងយល់ថាខ្លួនពុំមានសមត្ថកិច្ចតាមដែនដី តុលាការចេញសាលក្រមដោយប្រកាសថាពុំមានសមត្ថកិច្ច និង បង្គាប់ឱ្យបង្វិលសំណុំរឿងជូនទៅព្រះរាជអាជ្ញា ដើម្បីឱ្យព្រះរាជអាជ្ញាបញ្ជូនសំណុំរឿងនេះជូនតុលាការដែលមានសមត្ថកិច្ចដែនដី។ ប៉ុន្តែបន្ថែមពីនេះ តុលាការក៏សម្រេចបន្តការដាក់ជនជាប់ចោទឱ្យស្ថិតនៅក្នុងការឃុំខ្លួន ឬការត្រួតពិនិត្យតាមផ្លូវតុលាការផងដែរ ។ ការធ្វើបែបនោះដើម្បីធានានូវវត្តមានជនជាប់ចោទចំពោះមុខតុលាការផងដែរ។

- ការបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញាដើម្បីបើកការស៊ើបសួរ ៖ តុលាការដែលទទួលពាក្យបណ្តឹងតាមនីតិវិធីបង្គាប់ឱ្យបង្ហាញខ្លួនភ្លាម ត្រូវសម្រេចបញ្ជូនសំណុំរឿងនោះទៅព្រះរាជអាជ្ញាដើម្បីបើកការស៊ើបសួរវិញ។ ប្រសិនបើតុលាការយល់ឃើញថាលក្ខខណ្ឌនៃការប្រើនីតិវិធីនៃការបង្ហាញខ្លួនភ្លាមមិនបានបំពេញ ឬសំណុំរឿងនោះមានភាពសាំញ៉ាំនៃរឿងក្តីដែលទាមទារជាចាំបាច់ឱ្យធ្វើការស្រាវជ្រាវឱ្យធ្វើការស្រាវជ្រាវឱ្យបានស៊ីជម្រៅបន្ថែម[68]។ ក្រមនីតិវិធីព្រហ្មទណ្ឌមិនបានចែងច្បាស់ថាតុលាការ ត្រូវចេញសេចក្តីសម្រេចក្នុងចំណុចនេះជាសាលក្រមនេះទេ ប៉ុន្តែជាការបកស្រាយដោយឈរលើសេចក្តីសម្រេចដោយសាលក្រម នាំឱ្យតុលាការសម្រេចអំពីករណីមួយនេះជាសាលក្រមចាត់របៀបបាន។

- ការបង្គាប់ឱ្យធ្វើការស៊ើបសួរបន្ថែម ៖ ប្រសិនបើតុលាការយល់ឃើញថាការស្រាវជ្រាវថ្មីជាការចាំបាច់ តុលាការអាចបង្គាប់ឱ្យធ្វើការស៊ើបសួរបន្ថែមបានដោយសាលក្រម។ សិទ្ធិអំណាចក្នុងការបង្គាប់ឱ្យស៊ើបសួរបន្ថែមរបស់តុលាការ ត្រូវកម្រិតព្រំដែនដោយក្រមនីតិវិធីព្រហ្មទណ្ឌពោល គឺអ្នកដែលមានសមត្ថកិច្ចអាចធ្វើការស៊ើបសួរបន្ថែមនេះ មានតែប្រធានសវនាការ ចៅក្រមមួយនៃក្រុមប្រឹក្សាជំនុំជម្រះកាលណាតុលាការសម្រេចជាក្រុមសមូហភាព ឬ ចៅក្រមដទៃទៀតនៃតុលាការជាន់ដំបូងបន្ថែមនេះ ការស៊ើបសួរបន្ថែមអាចធ្វើក្នុងលក្ខខណ្ឌដូចមានកំណត់ក្នុងមាត្រា ៣៣៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

- ការសម្រេចអំពីរឿងអញ្ញត្រកម្ម ៖ ជាទូទៅតុលាការដែលទទួលបណ្តឹងអាជ្ញាមានសមត្ថកិច្ចអាចសម្រេចអំពីគ្រប់អញ្ញត្រកម្មទាំងអស់ ដែលលើកឡើងដោយគូភាគីលើកលែងតែច្បាប់បានបញ្ញត្តិផ្សេងពីនេះ ។ ការសម្រេចអំពីរឿងអញ្ញត្រកម្ម តុលាការអាចចេញសាលក្រមសម្រេចអំពីមោឃៈនីតិវិធី[69] អំពីបញ្ហាបន្ទាប់បន្សំ និងការបង្អង់មិនទាន់សម្រេច[70] ជាដើម។

[67] មាត្រា ២៩០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

[68] មាត្រា ៣០៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

[69] មាត្រា ៣៩២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

[70] មាត្រា ៣៩៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

# សេចក្តីសន្និដ្ឋាន

ក្រោយពីបាន ធ្វើការបកស្រាយនូវចំណោទបញ្ហាដែលបានលើកឡើងខាងលើរួចមក។ យើងពិនិត្យឃើញថាចំណាត់ការរបស់ចៅក្រមជំនុំជម្រះលើរឿងក្តីព្រហ្មទណ្ឌក្នុងដំណាក់កាល សាលាដំបូងគឺមានតួនាទីយ៉ាងសំខាន់ណាស់ មុននឹងចេញសេចក្តីសម្រេចវិនិច្ឆ័យអំពីអត្ថិភាព ឬនត្ថិភាពនៃបទល្មើស ដើម្បីសម្រេចជាសាលក្រមសម្រេចផ្តន្ទាទោស ឬ ចេញសម្រេចឱ្យរួចផុតពីបទចោទដែលតំណាងអយ្យការបានចោទប្រកាន់ជាអាទ៏។ យើងដឹងហើយថា ចំពោះរឿងក្តីព្រហ្មណទណ្ឌ គឺមានសញ្ញាណដំបូងឡើងតាមរយៈការដាក់ពាក្យបណ្តឹងពីជនរងគ្រោះមកកាន់នគរបាលយុត្តិធម៌ ឬកើតឡើងតាមរយៈបណ្តឹងបរិហា មកកាន់តំណាងអយ្យការអមសាលាដំបូងដែលមានសមត្ថកិច្ចជាដើម។ បន្ទាប់ពីមានបណ្តឹងចំពោះរឿងព្រហ្មទណ្ឌបានកើតឡើង គឺត្រូវឆ្លងកាត់ដំណាក់កាលជា ច្រើនដូចជាដំណាក់កាលនគរបាលយុត្តិធម៌ ដំណាក់កាលអយ្យការ ដំណាក់កាលចៅក្រមស៊ើបសួរ និងដំណាក់កាលជំនុំជម្រះជាអាទ៏។ ទន្ទឹមនឹងនោះ ចំណាត់ការរបស់ចៅក្រមជំនុំជម្រះ ជាដំណាក់កាលចុងក្រោយគេបង្អស់ក្នុងការចេញសេចក្តីសម្រេចចុងក្រោយនា ដំណាក់កាលសាលាដំបូងក្នុងរឿងក្តីព្រហ្មទណ្ឌ។ ដូចនេះ ចៅក្រមជំនុំជម្រះត្រូវតែយកចិត្តទុក ដាក់ឱ្យបានខ្ពស់ ក្នុងការចេញសេចក្តីសម្រេចដើម្បីផ្តន្ទាទោសទៅលើពិរុទ្ធជន ពីព្រោះថាការសម្រេចសេចក្តីត្រូវយោងទៅលើបទប្បញ្ញត្តិច្បាប់ និងភស្តុតាងដែលបានដាក់ជូនតុលាការ។ មួយវិញទៀត យោងតាមស្មារតីនៃរដ្ឋធម្មនុញ្ញកម្ពុជាឆ្នាំ១៩៩៣ គឺគោលការណ៍សន្មត់ទុកជាមុនថាគ្មានទោសបើសិនជាជននោះមិនទាន់ត្រូវបានតុលាការចេញសេចក្តីសម្រេចផ្តន្ទាសទោសនោះ។

សរុបសេចក្តីមក ចំពោះសារណាមួយនេះ គឺបានចង្អុលបង្ហាញយ៉ាងច្បាស់អំពីដំណើរការនៃកិច្ចនីតិវិធីរបស់ចៅក្រមជំនុំជម្រះលើរឿងក្តីព្រហ្មទណ្ឌចាប់តាំងពី ដំណាក់កាលទទួលពាក្យបណ្តឹងតាមរយៈរបៀបប្តឹងទៅតុលាការ ក៏ដូចជាដំណាក់កាលនៃការកោះហៅភាគីពាក់ព័ន្ធឱ្យចូលរួមសវនាការ និងដំណាក់កាលសវនាការដែលបានធ្វើកិច្ចពិភាក្សាដេញដោលទៅលើជនជាប់ទាក់ទិនមុននឹងចេញសេចក្តីសម្រេច រហូតមកដល់ដំណាក់កាលចុងក្រោយនៃការចេញសាលក្រមបញ្ចប់កិច្ចនីតិវិធីនៃដំណើរលើរឿងក្តីព្រហ្មទណ្ឌដំណាក់កាលសាលាដំបូងជាអាទ៏។

# អនុសាសន៍

បន្ទាប់ពីបានធ្វើការសិក្សាស្រាវជ្រាវ និងជ្រើសយកប្រធានបទស្តីពី**ចំណាត់ការរបស់ចៅក្រមជំនុំជម្រះលើរឿងក្តីព្រហ្មទណ្ឌដំណាក់កាលសាលាដំបូង** ដើម្បីជាការសរសេរសារណាបញ្ចប់ថ្នាក់ បរិញ្ញាប័ត្ររួចមក។ យើងខ្ញុំមានអនុសាសន៍និងសុំណូមពរនៅបញ្ហាខ្លះៗទាក់ទងនឹងប្រធានបទដូចខាងក្រោមនេះ

១.ចៅក្រមជំនុំជម្រះត្រូវបំពេញភារកិច្ចរបស់ខ្លួនដោយឯករាជ្យ ដោយគោរពច្បាប់យ៉ាងម៉ឹងម៉ាត់ និងឱ្យអស់ពីដួងចិត្តនិងសម្បជញ្ញៈរបស់ខ្លួន។

២.ចំពោះការកោះហៅភាគីឱ្យចូលរួមសវនាការ តុលាការគប្បីកំណត់ពេលវេលាឱ្យបានត្រឹមត្រូវតាមបទប្បញ្ញត្តិច្បាប់ ដើម្បីឱ្យភាគីបានចូលរួមនិងទទួលបានសិទ្ធិក្នុងការជំនុំជម្រះក្តីដោយយុត្តិធម៌។

៣.ការជម្រះក្តីផ្តល់យុត្តិធម៌ ត្រូវធ្វើក្នុងនាមប្រជារាស្ត្រខ្មែរតាមនីតិវិធី និងច្បាប់ជាធរមាន។

# **ឯកសារយោង**

## **ក.លិខិតបទដ្ឋានគតិយុត្តៈ**

១.រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឱ្យប្រើកាលពីថ្ងៃទី២១ កញ្ញា ឆ្នាំ១៩៩៣

២.ក្រមនីតិវិធីព្រហ្មទណ្ឌ ប្រកាសឱ្យប្រើកាលពីថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

៣.ច្បាប់ស្តីពីការៀបចំអង្គតុលាការ ប្រកាសឱ្យប្រើកាលពីថ្ងៃទី១៦ ខែកក្កដា ឆ្នាំ ២០១៤

៤. ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា ប្រកាសឱ្យប្រើកាលពីថ្ងៃទី១៦ ខែកក្កដា ឆ្នាំ ២០១៤

## **ខ.ឯកសារជំនួយស្មារតីៈ**

១.ឯកសារមេរៀនមុខវិជ្ជា **បច្ចេកទេសនៃការសួរចម្លើយ និងការតាក់តែងកំណត់ហេតុ** របស់លោក **សេង រីទ្ធី** គ្រូបង្គោលនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ សម្រាប់បណ្តុះបណ្តាលសិស្សក្រឡាបញ្ជីជំនាន់ទី៥។

២.សៀវភៅមេរៀន **នីតិវិធីព្រហ្មទណ្ឌ** របស់លោកសាស្ត្រាចារ្យ **រុន ពណ្ណារិទ្ធ** , លោកស្រីសាស្ត្រាចារ្យ **ចាំង ស៊ីណាត** និងលោកសាស្ត្រាចារ្យ **ជា ម៉េត**។

៣.ក្រមសីលធម៌ចៅក្រម របស់លោក **តូ តក្តី** បោះពុម្ពផ្សាយកាលពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៨។

៤.ឯកសារមេរៀនមុខវិជ្ជា **បច្ចេកទេសនៃការតាក់តែងសាលក្រម** របស់លោក **សេង នាង** គ្រូបង្គោលនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការសម្រាប់បណ្តុះបណ្តាលសិស្សក្រឡាបញ្ជីជំនាន់ទី៥ (ឆ្នាំ២០១៧-២០១៨) ។

៥.ឯកសារមេរៀនមុខវិជ្ជា **តួនាទីក្រឡាបញ្ជីក្នុងដំណាក់កាលជំនុំជម្រះ** របស់លោក **ខង្យ ម៉ុនវិសុទ្ធ** គ្រូបង្គោលនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការសម្រាប់បណ្តុះបណ្តាលសិស្សក្រឡាបញ្ជីជំនាន់ទី៥ (ឆ្នាំ២០១៧-២០១៨) ។

៦.របាយការណ៍ **ការកោះហៅក្នុងដំណាក់កាលសវនាការ** របស់លោក **កាន់ វិសាល** ជាសិស្សក្រឡាបញ្ជីជំនាន់ទី៤ នៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ (ឆ្នាំ២០១៥-២០១៦) ។

## តារាងឧបសម្ព័ន្ធ

១.ដីកាសន្និដ្ឋានចោទប្រកាន់បញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់

២.ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះ

៣.ដីកាបញ្ជូររឿងទៅជំនុំជម្រះ

៤.ដីការបញ្ជូន

៥.ដីកាសម្រេចយកជនជាប់ចោទមកជំនុំជម្រះ

៦.ដីកាកោះហៅបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់

៧.ដីកាកោះហៅជនជាប់ចោទចូលរួមសវនាការ

៨.ដីកាបង្គាប់ឱ្យនាំជនជាប់ចោទតុលាការ

៩.ដីកាកោះហៅសាក្សីឱ្យចូលរួមសវនាការ

១០.ដីកាកោះហៅដើមបណ្ដឹងរដ្ឋប្បវេណីឱ្យចូលរួមសវនាការ

១១.លិខិតអញ្ជើញអ្នកជំនាញឱ្យចូលរួមសវនាការ

១២.ដីកាអញ្ជើញឱ្យចូលសវនាការ (មន្ត្រីនគរបាលយុត្តិធម៌)

១៣.កំណត់ហេតុស្ដីពីការធ្វើសម្បថ

១៤.កំណត់ហេតុសវនាការ

១៥.សាលក្រមចាត់របៀប

១៦.សាលក្រមមុនអង្គសេចក្ដី

១៧.សាលក្រមអង្គសេចក្ដី

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អយ្យការអម**
**សាលាដំបូងខេត្តពោធិ៍សាត់**

លេខ៖ ...៤៥១...ព.ន./១៧

# ដីកាសន្និដ្ឋានចោទប្រកាន់ ជូនរឿងទៅជំនុំជម្រះផ្ទាល់[១]

**យើង ឆាយ ហុង តំណាងអយ្យការអមសាលាដំបូងខេត្តពោធិ៍សាត់**

- បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ៖៤០០ ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៦។
- បានឃើញមាត្រា ៤៦, ៤៩, ២៩១, ៤៥៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ២០០៧។

**ក្រោយពីបានពិនិត្យសំណុំរឿងចប់សព្វគ្រប់ឃើញថា[២]**

| | | | |
|---|---|---|---|
| នាមត្រកូល | ៖ [redacted] | នាមខ្លួន ៖ [redacted] | ភេទស្រី |
| អាយុ | ៖ ៥៥ឆ្នាំ | | |
| ទីកន្លែងកំណើត | ៖ ភូមិត្រពាំងកក់ ឃុំម្កាក់ ស្រុកអង្គស្នួល ខេត្តកណ្ដាល។ | | |
| លំនៅបច្ចុប្បន្ន | ៖ ភូមិអូរថ្កូវ ឃុំរលាប ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់ ។ | | |
| មុខរបរ | ៖ ធ្វើចំការ | | |
| សញ្ជាតិ | ៖ ខ្មែរ | | |
| នៅលីវ | ឬ ☑រៀបការ ប្ដីឈ្មោ[redacted]នកូនចំនួន ០១នាក់។ | | |
| ឪពុកឈ្មោះ | ៖ [redacted] "ស្លាប់" | ម្ដាយឈ្មោះ ៖ [redacted] "ស្លាប់" ។ | |
| អនីតិជន☐ | ឬ ជានីតិជន☑ ទោសពីមុន ៖ គ្មាន ។ | | |

[១] ដីកានេះ ប្រើសំរាប់ព្រះរាជអាជ្ញា ធ្វើដីកាសន្និដ្ឋានចោទប្រកាន់ជូនរឿងទៅជំនុំជម្រះផ្ទាល់ ចំពោះបទល្មើសជាក់ស្ដែង ឬមិនជាក់ស្ដែង ដែលមានទណ្ឌកម្មកំណត់ក្នុងច្បាប់មិនលើសពីមួយឆ្នាំ ហើយដែលមានភស្តុតាង និងធាតុផ្សំនៃបទល្មើសគ្រប់គ្រាន់។

[២] រៀបរាប់អំពីដំណើររឿង ឬអង្គហេតុសង្ខេបតាមសំណុំរឿង ក្រោយពីបញ្ចប់ការស៊ើបអង្កេត។
សំគាល់ ត្រូវធ្វើការកោះហៅភាគីឱ្យចូលទៅបង្ហាញខ្លួននៅមុខតុលាការនាពេលសវនាការ (មាត្រា៤៥៧)

**យល់ឃើញថា**[៤]៖

-អង្គហេតុបទល្មើសខាងលើ កើតឡើងនៅ ភូមិសាយ ឃុំព្រងិល ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់ ដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់អយ្យការ និងសាលាដំបូងខេត្តពោធិ៍សាត់ តាមមាត្រា ៣៩ និងមាត្រា ២៩០ នៃ**ក្រមនីតិវិធីព្រហ្មទណ្ឌ**។

-គិតចាប់ពីពេលដែលបទល្មើសកើតឡើងកាលពីថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៦ មកដល់ពេលនេះ អាជ្ញាយុកាលនៃបទល្មើសមិនទាន់ផុតរលត់នៅឡើយទេ ដូច្នេះអយ្យការ និងសាលាដំបូងខេត្តពោធិ៍សាត់ នៅតែមានសមត្ថកិច្ចចាត់ការលើសំណុំរឿងនេះ យោងតាមមាត្រា ១០ និងមាត្រា ១១ នៃ**ក្រមនីតិវិធីព្រហ្មទណ្ឌ**។

-ផ្អែកតាមចម្លើយដើមបណ្តឹងរដ្ឋប្បវេណី បានបញ្ជាក់ប្រាប់ថានៅថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៦ វេលាម៉ោង១០ព្រឹក ដើមបណ្តឹងបានជិះម៉ូតូជាមួយឈ្មោះ [redacted] និងឈ្មោះ [redacted] ទៅមើលដីស្ថិតនៅក្នុងភូមិសាយ ឃុំព្រងិល ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់ ពេលទៅដល់ទីតាំងដី ស្រាប់តែមានជនជាប់ចោទឈ្មោះ [redacted] បានដើរមកចង្អុលភ្នែករបស់ដើមបណ្តឹង ហើយស្រែកជេរថា៖ "ដីជីដូនជី តាអ្អែងនៅទីនេះ កន្ទុយម៉ែអ្អែងដីនេះជាដីម៉ែអ្អែងអី ដីនេះជាដីអញទេ អាចុយម្រាយគ្មានដីនៅចំនុចស្រែខ្ទង ភូមិសាយ ឃុំព្រងិល ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់ ទីនោះទេ" ហើយបានចង្អុលមុខដើមបណ្តឹង ហើយជេរផង ជេរពាក្យដដែលៗ ហើយខ្លាំងៗ។ ចម្លើយខាងលើនេះគឺមានភាពស៊ីសង្វាក់ជាមួយចម្លើយរបស់សាក្សីឈ្មោះ [redacted] ភេទប្រុស, ឈ្មោះ [redacted] ភេទស្រី, ឈ្មោះ [redacted] ភេទស្រី, ឈ្មោះ [redacted] ភេទប្រុស បានលឺជនជាប់ចោទស្រែកជេរទៅលើដើមបណ្តឹង ដែលអាចបញ្ជាក់បានថាជនជាប់ចោទគឺពិតជាបានធ្វើសកម្មភាពស្រែកជេរទៅដើមបណ្តឹងប្រាកដមែន។

-ជនជាប់ចោទឈ្មោះ [redacted] ជានីតិជន មានស្មារតី និងសមត្ថភាពគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវចំពោះអំពើរបស់ខ្លួន ហើយមានចេតនាពិតប្រាកដក្នុងការប្រព្រឹត្តអំពើខាងលើ ។

-អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] បានធ្វើឱ្យប៉ះពាល់ដល់សន្តិសុខ សណ្តាប់ធ្នាប់ របៀបរៀបរយសង្គម ប៉ះពាល់ដល់បុគ្គលភាពរបស់អ្នកដទៃ ជាពិសេសច្បាប់បញ្ញត្តិអំពើនេះ ជា**បទជេរប្រមាថជាសាធារណៈ** ដែលចែងឲ្យផ្តន្ទាទោសតាមមាត្រា៣០៧ នៃក្រមព្រហ្មទណ្ឌ។

-មានភស្តុតាង និងធាតុផ្សំគ្រប់គ្រាន់លើឈ្មោះ [redacted] ភេទស្រី អាយុ៥៥ឆ្នាំ ពី**បទ ជេរប្រមាថជាសាធារណៈ** ប្រព្រឹត្តនៅ ភូមិសាយ ឃុំព្រងិល ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់ កាលពីថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៦ ជាបទល្មើសព្រហ្មទណ្ឌ ដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣០៧ នៃក្រមព្រហ្មទណ្ឌ។

---

[៤] សន្និដ្ឋានវាយតម្លៃ ពីអំពើរបស់ជនត្រូវចោទ ទៅលើធាតុផ្សំនៃបទល្មើស សំរាប់បញ្ជាក់ថា មានឬគ្មានពិរុទ្ធភាពគ្រប់គ្រាន់ ឬស្លាប់ ឬគេចខ្លួនបាត់ មានឬគ្មានសាវជាតិគ្រប់គ្រាន់។

**យល់ឃើញថា**[៤] ៖

-អង្គហេតុបទល្មើសខាងលើ កើតឡើងនៅ ភូមិសាយ ឃុំព្រងិល ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់ ដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់អយ្យការ និងសាលាដំបូងខេត្តពោធិ៍សាត់ តាមមាត្រា ៣៩ និងមាត្រា ២៩០ នៃ**ក្រមនីតិវិធីព្រហ្មទណ្ឌ**។

-គិតចាប់ពីពេលដែលបទល្មើសកើតឡើងកាលពីថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៦ មកដល់ពេលនេះ អាជ្ញាយុកាលនៃបទល្មើសមិនទាន់ផុតរលត់នៅឡើយទេ ដូច្នេះអយ្យការ និងសាលាដំបូងខេត្តពោធិ៍សាត់ នៅតែមានសមត្ថកិច្ចចាត់ការលើសំណុំរឿងនេះ យោងតាមមាត្រា ១០ និងមាត្រា ១១ នៃ**ក្រមនីតិវិធីព្រហ្មទណ្ឌ**។

-ផ្អែកតាមចម្លើយដើមបណ្តឹងរដ្ឋប្បវេណី បានបញ្ជាក់ប្រាប់ថានៅថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៦ វេលាម៉ោង១០ព្រឹក ដើមបណ្តឹងបានជិះម៉ូតូជាមួយឈ្មោះ [redacted] និងឈ្មោះ [redacted] ទៅមើលដីស្ថិតនៅក្នុងភូមិសាយ ឃុំព្រងិល ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់ ពេលទៅដល់ទីតាំងដី ស្រាប់តែមានជនជាប់ចោទឈ្មោះ [redacted] បានដើរមកចង្អុលភ្នែករបស់ដើមបណ្តឹង ហើយស្រែកជេរថា៖ "ដីជីដូនជី តាអ៊ែ្លងនៅទីនេះ កន្ទុយម៉ែអ៊ែ្លងដីនេះជាដីម៉ែអ៊ែ្លងអី ដីនេះជាដីអញទេ អាចុយម្រាយគ្មានដីនៅចំនុចស្រែខ្នង ភូមិសាយ ឃុំព្រងិល ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់ ទីនោះទេ" ហើយបានចង្អុលមុខដើមបណ្តឹង ហើយជេរផង ជេរពាក្យដដែលៗ ហើយខ្លាំងៗ។ ចម្លើយខាងលើនេះគឺមានភាពស៊ីសង្វាក់ជាមួយចម្លើយរបស់សាក្សីឈ្មោះ [redacted] ភេទប្រុស, ឈ្មោះ [redacted] ភេទស្រី, ឈ្មោះ [redacted] ភេទស្រី, ឈ្មោះ [redacted] ភេទប្រុស បានឃើញជនជាប់ចោទស្រែកជេរទៅលើដើមបណ្តឹង ដែលអាចបញ្ជាក់បានថាជនជាប់ចោទគឺពិតជាបានធ្វើសកម្មភាពស្រែកជេរទៅដើមបណ្តឹងប្រាកដមែន។

-ជនជាប់ចោទឈ្មោះ [redacted] ជានីតិជន មានស្មារតី និងសមត្ថភាពគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវចំពោះអំពើរបស់ខ្លួន ហើយមានចេតនាពិតប្រាកដក្នុងការប្រព្រឹត្តអំពើខាងលើ ។

-អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] បានធ្វើឱ្យប៉ះពាល់ដល់សន្តិសុខ សណ្តាប់ធ្នាប់ របៀបរៀបរយសង្គម ប៉ះពាល់ដល់បុគ្គលភាពរបស់អ្នកដទៃ ជាពិសេសច្បាប់បញ្ញត្តិអំពើនេះ ជា**បទជេរប្រមាថជាសាធារណៈ** ដែលចែងឲ្យផ្តន្ទាទោសតាមមាត្រា៣០៧ នៃក្រមព្រហ្មទណ្ឌ។

-មានភស្តុតាង និងធាតុផ្សំគ្រប់គ្រាន់លើឈ្មោះ [redacted] ភេទស្រី អាយុ៥៥ឆ្នាំ ពី**បទ ជេរប្រមាថជាសាធារណៈ** ប្រព្រឹត្តនៅ ភូមិសាយ ឃុំព្រងិល ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់ កាលពីថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៦ ជាបទល្មើសព្រហ្មទណ្ឌ ដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣០៧ នៃក្រមព្រហ្មទណ្ឌ។

[៤] សន្និដ្ឋានវាយតម្លៃ ពីអំពើរបស់ជនត្រូវចោទ ទៅលើធាតុផ្សំនៃបទល្មើស សំរាប់បញ្ជាក់ថា មានឬគ្មានពិរុទ្ធភាពគ្រប់គ្រាន់ ឬស្លាប់ ឬគេចខ្លួនបាត់ មានឬគ្មានសាវជាតិគ្រប់គ្រាន់។

**ហេតុដូច្នេះ សម្រេច**

១.ចោទប្រកាន់ឈ្មោះ [redacted] ភេទស្រី អាយុ៥៥ឆ្នាំ ទីកន្លែងកំណើតភូមិត្រពាំងកក់ ឃុំម្កាក់ ស្រុកអង្គស្នួល ខេត្តកណ្តាល ទីលំនៅបច្ចុប្បន្ន ភូមិអូរថ្កូវ សង្កាត់រលាប ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់ ឪពុកឈ្មោះ [redacted] ម្តាយឈ្មោះ [redacted] ពីបទ**ជេរប្រមាថជាសាធារណៈ** ប្រព្រឹត្តនៅ ភូមិសាយ ឃុំព្រងិល ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់ កាលពីថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៦ តាមបញ្ញត្តិមាត្រា៣០៧ នៃក្រមព្រហ្មទណ្ឌ។

២.បញ្ជូនជនជាប់ចោទដូចមានឈ្មោះខាងលើ ក្នុងសំណុំរឿងព្រហ្មទណ្ឌលេខ៤០០ ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៦ ព្រមទាំងបញ្ជីរាយនាមជនដែលជាប់ទាក់ទិនក្នុងសំណុំរឿងនេះ ទៅសាលាដំបូងខេត្តពោធិ៍សាត់ ដើម្បីជំនុំជម្រះតាមច្បាប់។

ធ្វើនៅពោធិ៍សាត់ ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៧

**តំណាងអយ្យការ**



សាលាដំបូងខេត្តពោធិ៍សាត់

បន្ទប់ស៊ើបសួរ( ៥ )

សំណុំរឿងព្រហ្មទណ្ឌ

លេខ:៣៩៥

ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៥

សំណុំរឿងស៊ើបសួរ

លេខ:២២៧

ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៥

ដីកាដំណោះស្រាយ

លេខ:...............

# ព្រះរាជាណាចក្រកម្ពុជា

# ជាតិ សាសនា ព្រះមហាក្សត្រ

# ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះ

យើង ម៉ៅ ស៊ីណា ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តពោធិ៍សាត់ អមដោយលោក ប៉ុល វណ្ណា ជាក្រឡាបញ្ជី

-បានឃើញមាត្រា២៤៧នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

-បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ: ៣៩៥ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៥។

-បានឃើញសំណុំរឿងស៊ើបសួរលេខ: ២២៧ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៥។

-បានឃើញដីកាសន្និដ្ឋានស្ថាពរលេខ: ៥៥៨ ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៦។

-បានឃើញពាក្យបណ្តឹងរបស់ឈ្មោះ [redacted]។ (ឯកសារលេខ:១)

-បានឃើញចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted]។ (ឯកសារលេខ:២១)

-បានឃើញចម្លើយសាក្សីឈ្មោះ [redacted]។ (ឯកសារលេខ:២១)

-បានឃើញចម្លើយជនត្រូវចោទឈ្មោះ [redacted]។ (ឯកសារលេខ:១១,១៦)

## សំអាងហេតុ

មានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ [redacted] ភេទប្រុស អាយុ២៦ឆ្នាំ ជាតិខ្មែរ មុខកសិករ ពីបទ: **ធ្វើឱ្យខូចខាតដោយចេតនាមានស្ថានទម្ងន់ទោសនាំឱ្យខូចប្រយោជន៍សំណង់គ្រឹះស្ថានសាធារណៈ** ប្រព្រឹត្តនៅភូមិអូរព្រាល ឃុំសំរោង ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់ កាលពីថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៥ តាមបញ្ញត្តិមាត្រា៤១១នៃក្រមព្រហ្មទណ្ឌ។

## ហេតុដូច្នេះ សម្រេច

បញ្ជូនសំណុំរឿងលេខ: ៣៩៥ និងជនត្រូវចោទឈ្មោះ [redacted] ភេទប្រុស អាយុ២៦ឆ្នាំ ជាតិខ្មែរ ទៅជំនុំជម្រះតាមច្បាប់។

ធ្វើនៅពោធិ៍សាត់,ថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១៦

**ក្រឡាបញ្ជី** **ចៅក្រមស៊ើបសួរ**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាដំបូងខេត្តពោធិ៍សាត់
លេខ: ៣៤៣ ចណ/១៧

# ដីកាសម្រេចដាក់រឿងជំនុំជំរះ

យើង **រស់ ផូរា** ចៅក្រមជំនុំជំរះនៃសាលាដំបូងខេត្តពោធិ៍សាត់ ។

ដោយមានលោក **ចុល ពិសិដ្ឋ** ជាក្រឡាបញ្ជីសវនាការសាលាដំបូងខេត្តពោធិ៍សាត់អមផង ។

-បានឃើញមាត្រា ២៩២ និងមាត្រា ២៩៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ដែលបានប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ:នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ ២០០៧ ។

-បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ៖ ២៣៩ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៦ របស់តំណាងអយ្យការអមសាលាដំបូងខេត្តពោធិ៍សាត់ ។

-បានឃើញដីកាបញ្ជូនសំណុំរឿងទៅជំនុំជំរះលេខ: ២៨៤ ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១៧ របស់សាលាដំបូងខេត្តពោធិ៍សាត់។

-បានឃើញដីកាចាត់តាំងចៅក្រមជំនុំជំរះលេខ៖ ៧៨ ពស/១៧ ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៧ របស់សាលាដំបូងខេត្តពោធិ៍សាត់។

## ក្រោយពីបានពិនិត្យសំណុំរឿងចប់សព្វគ្រប់

## សម្រេច

បញ្ជូនសំណុំរឿងព្រហ្មទណ្ឌលេខ ២៣៩ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៦ ទាំងមូលទៅព្រះរាជអាជ្ញាអមសាលាដំបូងខេត្តពោធិ៍សាត់ ដើម្បីចាត់ការតាមនីតិវិធី ដោយកំណត់កាលបរិច្ឆេទសវនាការនៅថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១៧ វេលាម៉ោង ៩ និង ០០ នាទីព្រឹក ។

## ចៅក្រមជំនុំជម្រះ

-លោកស្រី **រស់ ផូរា** ចៅក្រមនៃសាលាដំបូងខេត្តពោធិ៍សាត់។

## តំណាងអយ្យការ

-លោក **ឆាយ ហុច** ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងខេត្តពោធិ៍សាត់។

## ក្រឡាបញ្ជីសវនាការ

-លោក **ចុល ពិសិដ្ឋ** ក្រឡាបញ្ជីនៃសាលាដំបូងខេត្តពោធិ៍សាត់។

ពោធិ៍សាត់, ថ្ងៃទី ៣០ ខែតុលា ឆ្នាំ២០១៧

**ចៅក្រមជំនុំជម្រះ**

រស់ ផូរា

**ក្រឡាបញ្ជីសវនាការ**

ចុល ពិសិដ្ឋ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអម
សាលាដំបូងខេត្តពោធិ៍សាត់
លេខ...២២៣...ព.អ.ស/១៨

## ដីកាបញ្ជូន

ផ្ញើជូន លោកស្នងការនគរបាលខេត្តពោធិ៍សាត់

| ល.រ | រាយឈ្មោះលិខិត | ចំនួន | សេចក្តីផ្សេងៗ |
|---|---|---|---|
| ០១ | ដីកាកោះហៅឱ្យចូលសវនាការឈ្មោះ [redacted] ភេទស្រី អាយុ ៤៤ ឆ្នាំ នៅថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៨ វេលាម៉ោង ៥:០០ នាទីព្រឹក | ០២ សន្លឹក | ដើម្បីចាត់ការតាមនីតិវិធី។ |
| ០២ | ដីកាកោះហៅឱ្យចូលសវនាការឈ្មោះ [redacted] ភេទស្រី អាយុ ៤៩ ឆ្នាំ នៅថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៨ វេលាម៉ោង ៥:០០ នាទីព្រឹក | ០២ សន្លឹក | |
| ០៣ | ដីកាកោះហៅឱ្យចូលសវនាការឈ្មោះ [redacted] ភេទស្រី អាយុ ៣៩ ឆ្នាំ នៅថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៨ វេលាម៉ោង ៥:០០ នាទីព្រឹក | ០២ សន្លឹក | |
| ០៤ | ដីកាកោះហៅឱ្យចូលសវនាការឈ្មោះ [redacted] ភេទស្រី អាយុ ៤៨ ឆ្នាំ នៅថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៨ វេលាម៉ោង ៥:០០ នាទីព្រឹក | ០២ សន្លឹក | |
| | សរុប | ០២ សន្លឹក | |

10 - 01 - 2018

ថ្ងៃ............ខែ.......ឆ្នាំរកា ឧប្បស័ក ព.ស ២៥៦១
ខេត្តពោធិ៍សាត់, ថ្ងៃទី០៨...ខែ.......ឆ្នាំ២០១៧
**តំណាងអយ្យការ**

ឈី_តារ៉ា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអម
សាលាដំបូងខេត្តពោធិ៍សាត់
លេខ:...២៩៣...ដិ.ស

**ដីកាសម្រេចបញ្ជូនជាប់ចោទមកជំនុំជម្រះ**

យើង **ឆាយ ហុខ** ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងខេត្តពោធិ៍សាត់ ។

ក្រោយពីបានពិនិត្យសំណុំរឿងព្រហ្មទណ្ឌលេខ ២៣៩ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៦ ដែលមានជនជាប់ចោទ៖

១-ឈ្មោះ [redacted] ភេទប្រុស អាយុ ២១ ឆ្នាំ រស់នៅភូមិកណ្តាល ឃុំអន្លង់ត្នោត ស្រុកក្រគរ ខេត្តពោធិ៍សាត់ ឃុំខ្លួននៅថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៦។

២-ឈ្មោះ [redacted] ភេទប្រុស អាយុ ៣១ ឆ្នាំ រស់នៅភូមិកណ្តាល ឃុំអន្លង់ត្នោត ស្រុកក្រគរ ខេត្តពោធិ៍សាត់ ឃុំខ្លួននៅថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៦។

ជាប់ចោទពីបទ លួច និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិតាកែវលើ ឃុំត្នោតជុំ ស្រុកក្រគរ ខេត្តពោធិ៍សាត់ កាលពីថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០១៦ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣, ៣៥៦ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៣-ឈ្មោះ [redacted] ហៅ [redacted] ភេទប្រុស អាយុ ២៥ ឆ្នាំ រស់នៅភូមិកណ្តាល ឃុំអន្លង់ត្នោត ស្រុកក្រគរ ខេត្តពោធិ៍សាត់ ឃុំខ្លួននៅថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៦។

ជាប់ចោទពីបទ ចាត់ចែងឱ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិតាកែវលើ ឃុំត្នោតជុំ ស្រុកក្រគរ ខេត្តពោធិ៍សាត់ កាលពីថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០១៦ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤២ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

ហេតុដូច្នេះសម្រេច

ក-ឱ្យជនជាប់ចោទឈ្មោះ ៖

១-ឈ្មោះ [redacted] ភេទប្រុស អាយុ ២១ ឆ្នាំ

២-ឈ្មោះ [redacted] ភេទប្រុស អាយុ ៣១ ឆ្នាំ

៣-ឈ្មោះ [redacted] ហៅ [redacted] ភេទប្រុស អាយុ ២៥ ឆ្នាំ

ទៅកាន់សាលាដំបូងខេត្ត ពោធិ៍សាត់ ទីកន្លែងជំនុំជម្រះសវនាការនៅថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១៧ វេលាម៉ោង ៨៖០០ នាទីព្រឹក ដើម្បីជំនុំជម្រះ ។

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អយ្យការអម**
**សាលាដំបូងខេត្តពោធិ៍សាត់**

សំណុំរឿងព្រហ្មទណ្ឌលេខ ៤០០
ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៦

## ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់

**យើង ឆាយ ហុង តំណាងអយ្យការអមសាលាដំបូងខេត្តពោធិ៍សាត់**

**បានបញ្ជាឲ្យចូលទៅបង្ហាញខ្លួននៅសវនាការ:**

នាមត្រកូល ៖ [redacted] នាមខ្លួន ៖ [redacted] ភេទស្រី

អាយុ ៖ ៥៥ឆ្នាំ

ទីកន្លែងកំណើត ៖ ភូមិត្រពាំងកក់ ឃុំម្កាក់ ស្រុកអង្គស្នួល ខេត្តកណ្ដាល។

លំនៅបច្ចុប្បន្ន ៖ ភូមិអូរថ្កូវ ឃុំរលាប ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់ ។

មុខរបរ ៖ ធ្វើចំការ

សញ្ជាតិ ៖ ខ្មែរ

នៅលីវ ឬ ☑រៀបការ ប្ដីឈ្មោះ[redacted]មានកូនចំនួន ០១នាក់។

ឪពុកឈ្មោះ ៖ [redacted] "ស្លាប់" ម្ដាយឈ្មោះ ៖ [redacted] "ស្លាប់" ។

អនីតិជន☐ ឬ ជានីតិជន☑ ទោសពីមុន ៖ គ្មាន ។

***អ្នកត្រូវបានចោទប្រកាន់ពីអង្គហេតុ:***

កាលពីថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៦ វេលាម៉ោង១០ព្រឹក ដើមបណ្ដឹងឈ្មោះ [redacted] ភេទប្រុស អាយុ៥១ឆ្នាំ រស់នៅភូមិបណ្ដុះសណ្ដែក សង្កាត់បន្ទាយដី ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់ បានជិះម៉ូតូជាមួយឈ្មោះ [redacted] និងឈ្មោះ [redacted] ទៅមើលដីស្ថិតនៅក្នុងភូមិសាយ ឃុំព្រងិល ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់។ ពេលទៅដល់ទីតាំងដី ស្រាប់តែមានជនសង្ស័យឈ្មោះ [redacted] ភេទស្រី អាយុ៥៥ឆ្នាំ រស់នៅភូមិអូរថ្កូវ សង្កាត់រលាប ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់ បានដើរមកចង្អុលភ្នែករបស់ដើមបណ្ដឹង ហើយស្រែកជេរថា៖ "ដីជីដូនជីតាអ្អែងនៅទីនេះ កន្ទុយម៉ែអ្អែងដីនេះជាដីម៉ែអ្អែងអី ដីនេះជាដីអញទេ អាចុយម្រាយគ្មានដីនៅចំនុចស្រែខ្នង ភូមិសាយ ឃុំព្រងិល ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់ទីនោះទេ" ហើយបានចង្អុលមុខដើមបណ្ដឹង ហើយជេរផង ជេរពាក្យដដែលៗ ហើយខ្លាំងៗ។ ករណីនេះត្រូវបានដើមបណ្ដឹងសម្រេចដាក់ពាក្យប្ដឹងមកតុលាការដើម្បីចាត់ការតាមនីតិវិធីច្បាប់។៕

អំពើប្រព្រឹត្តរបស់អ្នកខាងលើជាបទ **ធ្វេសប្រហែសបណ្តាលឱ្យស្លាប់មនុស្ស**: ប្រព្រឹត្តនៅ ភូមិសាយ ឃុំព្រងិល ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់ កាលពីថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៦ បទល្មើសព្រហ្មទណ្ឌមានចែង និងបញ្ញត្តិឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣០៧ នៃក្រមព្រហ្មទណ្ឌឈើ។

សវនាការនៃរឿងក្តីនេះ នឹងប្រព្រឹត្តទៅនៅ*ថ្ងៃទី...........ខែ...........ឆ្នាំ២០១៧ វេលាម៉ោង.........* នៅសាលសវនាការនៃសាលាដំបូងខេត្តពោធិ៍សាត់។

## សមាសភាពតុលាការជំនុំជម្រះ

១. លោក ........................... ជាចៅក្រមជំនុំជម្រះ

២. លោក ........................... ជាតំណាងអយ្យការ

៣. លោក ........................... ជាក្រឡាបញ្ជី។

សាមីខ្លួនអាចពឹងមេធាវីឱ្យអមខ្លួនបាន។

សាមីខ្លួនត្រូវបង្ហាញខ្លួនឱ្យទាន់ពេលវេលា និងយកលិខិតផ្សេងៗដែលទាក់ទងនឹងជីវភាពសាមីខ្លួន ឬដំណើររឿងខាងលើមកជាមួយផង ប្រសិនបើមាន។

*ធ្វើនៅពោធិ៍សាត់, ថ្ងៃទី .១៦. ខែឧសភា ឆ្នាំ២០១៧*

**តំណាងអយ្យការ**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអម
សាលាដំបូងខេត្តពោធិ៍សាត់
លេខ: ៦២៧ អ.សរ/១៨

# ដីកាកោះហៅជនជាប់ចោទឱ្យចូលរួមសវនាការ

**យើង លី តារ៉ា** តំណាងអយ្យការអមសាលាដំបូងខេត្តពោធិ៍សាត់។

-បានឃើញ ក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

-បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ: ៣៩៥ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៥។

-យោងដីកាសម្រេចបញ្ជូនរឿងជំនុំជម្រះលេខ ៖ ៧៤៦ ពសព្រទ/១៦ ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១៦ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តពោធិ៍សាត់ដែលបានបញ្ជូនជនជាប់ចោទឈ្មោះ [redacted] ភេទប្រុស អាយុ ២៦ ឆ្នាំ (ក្រៅឃុំ) ទៅតុលាការព្រហ្មទណ្ឌនៃសាលាដំបូងខេត្តពោធិ៍សាត់ដើម្បីជំនុំជំរះពីបទ ៖ **ធ្វើឱ្យខូចខាតដោយចេតនា** (មានស្ថានទម្ងន់ទោសនាំឱ្យខូចប្រយោជន៍សំណង់គ្រឹះស្ថានសាធារណៈ) ប្រព្រឹត្តនៅភូមិអូរព្រាល ឃុំសំរោង ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់ កាលពីថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៥ តាមមាត្រា **៤១១ នៃក្រមព្រហ្មទណ្ឌ**។

បង្គាប់មកជនជាប់ចោទឈ្មោះ [redacted] ភេទប្រុស អាយុ ២៦ ឆ្នាំ (ក្រៅឃុំ) មានទីលំនៅបច្ចុប្បន្ននៅភូមិអូរព្រាល ឃុំសំរោង ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់។

ឱ្យចូលទៅកាន់ទីកន្លែងសាលសវនាការ នៃសាលាដំបូងខេត្តពោធិ៍សាត់ នៅថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៨ វេលាម៉ោង ៨៖០០ នាទីព្រឹក ជាកំហិតដើម្បីធ្វើការជំនុំជំរះ។

**ចៅក្រមជំនុំជំរះ**

-**លោកស្រី រស់ ផូរា** ចៅក្រមនៃសាលាដំបូងខេត្តពោធិ៍សាត់។

**តំណាងអយ្យការ**

-**លោក លី តារ៉ា** ជាព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងខេត្តពោធិ៍សាត់។

**ក្រឡាបញ្ជីសវនាការ**

-**លោក ឌុល ពិសិដ្ឋ** ជាក្រឡាបញ្ជីនៃសាលាដំបូងខេត្តពោធិ៍សាត់។

ថ្ងៃ.......ខែ.......ឆ្នាំរកា នព្វស័ក ព.ស ២៥៦១

ពោធិ៍សាត់, ថ្ងៃទី...០៨...ខែ.......ឆ្នាំ២០១៨

**តំណាងអយ្យការ**

លី តារ៉ា

យើង.....................................បានប្រគល់ដីកាកោះនេះដល់
ឈ្មោះ.....................................................ទីលំនៅ
ភូមិ..................................
ឃុំ......................................
ស្រុក..............................ខេត្ត..................................
នៅថ្ងៃទី.....ខែ............ឆ្នាំ២០........ផ្ទាល់ដៃរួចហើយ។
ធ្វើនៅថ្ងៃទី...........ខែ.................ឆ្នាំ២០.......................

**អ្នកទទួល** **អ្នកប្រគល់**

អំពើប្រព្រឹត្តរបស់អ្នកខាងលើជាបទ **ធ្វេសប្រហែសធ្វើឱ្យឆេះព្រៃ** ប្រព្រឹត្តនៅ ភូមិសាយ ឃុំព្រងិល ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់ កាលពីថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៦ បទល្មើសព្រហ្មទណ្ឌមានចែង និងបញ្ញត្តិឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣០៧ នៃក្រមព្រហ្មទណ្ឌឈើ។

សវនាការនៃរឿងក្តីនេះ នឹងប្រព្រឹត្តទៅនៅ***ថ្ងៃទី...........ខែ...........ឆ្នាំ២០១៧ វេលាម៉ោង........*** នៅសាលសវនាការនៃសាលាដំបូងខេត្តពោធិ៍សាត់។

## សមាសភាពតុលាការជំនុំជម្រះ

១. លោក .......................... ជាចៅក្រមជំនុំជម្រះ

២. លោក .......................... ជាតំណាងអយ្យការ

៣. លោក .......................... ជាក្រឡាបញ្ជី។

សាមីខ្លួនអាចពឹងមេធាវីឱ្យអមខ្លួនបាន។

សាមីខ្លួនត្រូវបង្ហាញខ្លួនឱ្យទាន់ពេលវេលា និងយកលិខិតផ្សេងៗដែលទាក់ទងនឹងជីវភាពសាមីខ្លួន ឬដំណើររឿងខាងលើមកជាមួយផង ប្រសិនបើមាន។

*ធ្វើនៅពោធិ៍សាត់, ថ្ងៃទី .១៨. ខែឧសភាឆ្នាំ២០១៧*

**តំណាងអយ្យការ**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

អយ្យការអម

សាលាដំបូងខេត្តពោធិ៍សាត់

លេខ: ១១.០៤......../១៧

## ដីកាបង្គាប់ឲ្យនាំជនជាប់ចោទទៅតុលាការ

យើង **ឆាយ ហុង** ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងខេត្តពោធិ៍សាត់ ។

បង្គាប់មកលោក ប្រធានពន្ធនាគារខេត្តពោធិ៍សាត់ ឱ្យនាំជនជាប់ចោទមានឈ្មោះដូចខាងក្រោមនេះ ទៅកាន់សាលាដំបូងខេត្តពោធិ៍សាត់ នៅថ្ងៃទី០៧ **ខែវិច្ឆិកា ឆ្នាំ**២០១៧ វេលាម៉ោង ០៨៖០០ នាទីព្រឹក ដើម្បីជំនុំជំរះ ។

| ល.រ | នាមត្រកូល-នាមខ្លួន | បទល្មើស ថ្ងៃ ខែ ឆ្នាំ ប្រព្រឹត្តបទល្មើស | លេខ ថ្ងៃ ខែ ឆ្នាំ ឃុំខ្លួន |
|---|---|---|---|
| ០១ | ឈ្មោះ [redacted] ភេទប្រុស អាយុ ២១ឆ្នាំ | លួច,ចាត់ចែងឲ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន។ ប្រព្រឹត្តនៅភូមិតាកែវលើ ឃុំត្នោតជ្រុំ ស្រុកក្រគរ ខេត្តពោធិ៍សាត់ កាលពីថ្ងៃទី ០៣ ខែមិថុនា ឆ្នាំ ២០១៦ ។ | ៣៥១ (២១.០៦.១៦) |
| ០២ | ឈ្មោះ [redacted] ភេទប្រុស អាយុ ៣១ ឆ្នាំ | | ៣៥៣ (២១.០៦.១៦) |
| ០៣ | ឈ្មោះ [redacted] ហៅ[redacted] ភេទប្រុស អាយុ ២១ ឆ្នាំ | | ៥៣៦ (០១.១២.១៦) |

ពោធិ៍សាត់, ថ្ងៃទី១៧ខែតុលា ឆ្នាំ២០១៧

**តំណាងអយ្យការ**

ឆាយ ហុង

យើង.............................ប្រធានពន្ធនាគារខេត្តពោធិ៍សាត់ សូមបញ្ជាក់ថា ឈ្មោះ ខាងលើនេះពិត ជាបានជាប់ឃុំឃាំងនៅមន្ទីររបស់យើងប្រាកដមែន ហើយយើងនិងចាត់ការបញ្ជូនឲ្យបានទាន់ពេលវេលា តាមការកំណត់របស់តុលាការ ។

ពោធិ៍សាត់.ថ្ងៃទី..........ខែ........ឆ្នាំ ២០១៥

**ប្រធានមន្ទីរឃុំឃាំង**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

អយ្យការអម
សាលាដំបូងខេត្តពោធិ៍សាត់
លេខ: [illegible]

អធិការដ្ឋាននគរបាលស្រុកភ្នំក្រវាញ
ផ្នែកសរនាធិការ
ចូល
លេខ 031
ថ្ងៃទី 19 ខែ 01 ឆ្នាំ 2018
វេលាម៉ោង 4:00 [illegible]

# ដីកាកោះហៅសាក្សីឱ្យចូលរួមសវនាការ

យើង **លី តារ៉ា** តំណាងអយ្យការអមសាលាដំបូងខេត្តពោធិ៍សាត់។

-បានឃើញ ក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

-បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ: ៣៩៥ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៥។

-យោងដីកាសម្រេចបញ្ជូនរឿងជំនុំជម្រះលេខ ៖ ៧៤៦ ពសព្រទ/១៦ ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១៦ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តពោធិ៍សាត់ដែលបានបញ្ជូនជនជាប់ចោទឈ្មោះ [redacted] ភេទប្រុស អាយុ ២៦ ឆ្នាំ (ក្រៅឃុំ) ទៅតុលាការព្រហ្មទណ្ឌនៃសាលាដំបូងខេត្តពោធិ៍សាត់ដើម្បីជំនុំជំរះពីបទ ៖ **ធ្វើឱ្យខូចខាតដោយចេតនា (មានស្ថានទម្ងន់ទោសនាំឱ្យខូចប្រយោជន៍សំណង់គ្រឹះស្ថានសាធារណៈ)** ប្រព្រឹត្តនៅភូមិអូរព្រាល ឃុំសំរោង ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់ កាលពីថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៥ តាមមាត្រា **៤១១ នៃក្រមព្រហ្មទណ្ឌ**។

អញ្ជើញឈ្មោះ [redacted] ភេទស្រី អាយុ [redacted] ឆ្នាំ មានទីលំនៅបច្ចុប្បន្ននៅភូមិអូរព្រាល ឃុំសំរោង ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់។

ឱ្យចូលទៅកាន់ទីកន្លែងសាលសវនាការ នៃសាលាដំបូងខេត្តពោធិ៍សាត់ នៅថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៨ វេលាម៉ោង ៩៖០០ នាទីព្រឹក ជាកំហិតដើម្បីធ្វើការជំនុំជំរះ។

## ចៅក្រមជំនុំជំរះ

-**លោកស្រី រស់ ផូរា** ចៅក្រមនៃសាលាដំបូងខេត្តពោធិ៍សាត់។

## តំណាងអយ្យការ

-**លោក លី តារ៉ា** ជាព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងខេត្តពោធិ៍សាត់។

## ក្រឡាបញ្ជីសវនាការ

-**លោក ថុល ពិសិដ្ឋ** ជាក្រឡាបញ្ជីនៃសាលាដំបូងខេត្តពោធិ៍សាត់។

ថ្ងៃ[illegible] ខែ[illegible] ឆ្នាំរកា នព្វស័ក ព.ស ២៥៦១
ពោធិ៍សាត់, ថ្ងៃទី[illegible] ខែ[illegible] ឆ្នាំ២០១៨
**តំណាងអយ្យការ**

លី តារ៉ា

យើង[illegible] បានប្រគល់ដីកាកោះនេះដល់
ឈ្មោះ [redacted] ........................ ទីលំនៅ
ភូមិ[illegible]
ឃុំ[illegible]
ស្រុក[illegible] ខេត្ត[illegible]
នៅថ្ងៃទី[illegible] ខែ[illegible] ឆ្នាំ២០18 ផ្ទាល់ដៃរួចហើយ។
ធ្វើនៅថ្ងៃទី[illegible] ខែ[illegible] ឆ្នាំ២០18

**អ្នកទទួល** **អ្នកប្រគល់**

[redacted] [redacted]

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអម
សាលាដំបូងខេត្តពោធិ៍សាត់
លេខ: ២២៨...ករស/១៨

## ដីកាកោះហៅ
## ដើម្បីបណ្តឹងរដ្ឋប្បវេណីឱ្យចូលរួមសវនាការ

**យើង លី សារ៉ា** តំណាងអយ្យការអមសាលាដំបូងខេត្តពោធិ៍សាត់។

-បានឃើញ ក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

-បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ: ៣៩៥ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៥។

-យោងដីកាសម្រេចបញ្ជូនរឿងជំនុំជម្រះលេខ ៖ ៧៤៦ ពសព្រទ/១៦ ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១៦ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តពោធិ៍សាត់ដែលបានបញ្ជូនជនជាប់ចោទឈ្មោះ [redacted] ភេទប្រុស អាយុ ២៦ ឆ្នាំ (ក្រៅឃុំ) ទៅតុលាការព្រហ្មទណ្ឌនៃសាលាដំបូងខេត្តពោធិ៍សាត់ដើម្បីជំនុំជំរះពីបទ ៖ **ធ្វើឱ្យខូចខាតដោយចេតនា (មានស្ថានទម្ងន់ទោសនាំឱ្យខូចប្រយោជន៍សំណង់គ្រឹះស្ថានសាធារណៈ)** ប្រព្រឹត្តនៅភូមិអូរព្រាល ឃុំសំរោង ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់ កាលពីថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៥ តាមមាត្រា **៤១១ នៃក្រមព្រហ្មទណ្ឌ**។

អញ្ជើញឈ្មោះ [redacted] ភេទប្រុស អាយុ ៥០ ឆ្នាំ មានទីលំនៅបច្ចុប្បន្ននៅភូមិអូរព្រាល ឃុំសំរោង ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់។

ឱ្យចូលទៅកាន់ទីកន្លែងសាលសវនាការ នៃសាលាដំបូងខេត្តពោធិ៍សាត់ នៅថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៨ វេលាម៉ោង ៩៖០០ នាទីព្រឹក ជាកំហិតដើម្បីធ្វើការជំនុំជំរះ។

### ចៅក្រមជំនុំជំរះ

-**លោកស្រី រស់ ផូរ៉ា** ចៅក្រមនៃសាលាដំបូងខេត្តពោធិ៍សាត់។

### តំណាងអយ្យការ

-**លោក លី សារ៉ា** ជាព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងខេត្តពោធិ៍សាត់។

### ក្រឡាបញ្ជីសវនាការ

-**លោក ឌុល ពិសិដ្ឋ** ជាក្រឡាបញ្ជីនៃសាលាដំបូងខេត្តពោធិ៍សាត់។

ថ្ងៃ[illegible] ខែ [illegible] ឆ្នាំរកា នព្វស័ក ព.ស ២៥៦១
ពោធិ៍សាត់, ថ្ងៃទី...០៥...ខែ...មករា...ឆ្នាំ២០១៨
**តំណាងអយ្យការ**

លី សារ៉ា

យើង.................................បានប្រគល់ដីកាកោះនេះដល់
ឈ្មោះ...................................................ទីលំនៅ
ភូមិ..................................
ឃុំ....................................
ស្រុក..............................ខេត្ត..................................
នៅថ្ងៃទី.....ខែ............ឆ្នាំ២០........ផ្ទាល់ដៃរួចហើយ។
ធ្វើនៅថ្ងៃទី............ខែ.................ឆ្នាំ២០........................

**អ្នកទទួល** **អ្នកប្រគល់**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តពោធិ៍សាត់
លេខ ១៤៧ ពស/១៧

## ដីកាចាត់តាំងក្រុមប្រឹក្សាជំនុំជម្រះ

យើង **អ៊ិត សម្ផស្ស** ប្រធានសាលាដំបូងខេត្ត **ពោធិ៍សាត់**

បានឃើញដីកាសម្រេចលេខ៤៤៩ ពស.ព្រទ/១៧ ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៧ របស់ប្រធានសាលាដំបូងខេត្តពោធិ៍សាត់។

បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ២៦០ ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៦ របស់អយ្យការអមសាលាដំបូងខេត្តពោធិ៍សាត់។

បានឃើញដីកាបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ៣៩៧ ពស.ព្រទ/១៧ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៧ របស់លោកចៅក្រមស៊ើបសួរ ដែលសម្រេចបញ្ជូនៈ

១-ឈ្មោះ [redacted] ភេទប្រុស អាយុ២០ ឆ្នាំ ជាតិខ្មែរ
២-ឈ្មោះ [redacted] ភេទប្រុស អាយុ៤៤ ឆ្នាំ ជាតិខ្មែរ

ពីបទ: ជួញដូរដោយខុសច្បាប់នូវសារធាតុញៀនច្រើនដង, ចាត់ចែងឲ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀនច្រើនដង និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅឃុំអូរសោម ស្រុកវាលវែង ខេត្តពោធិ៍សាត់ កាលពីអំឡុងខែមិថុនា ឆ្នាំ២០១៦។

### <u>សម្រេចចាត់តាំង</u>

១- លោកស្រី រស់ ផូវ៉ា ជាប្រធានក្រុមប្រឹក្សាជំនុំជម្រះ
២- លោក មៅ ស៊ីណា ជាចៅក្រមប្រឹក្សា
៣- លោក សុន នាថធារី ជាចៅក្រមប្រឹក្សា

ដើម្បីជំនុំជម្រះសំណុំរឿងព្រហ្មទណ្ឌលេខ២៦០ ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៦ ។

ពោធិ៍សាត់, ថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៧

អ៊ិត សម្ផស្ស

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអម
សាលាដំបូងខេត្តពោធិ៍សាត់
លេខ:១៩៨២៦ [illegible]/១៨

## ដីកាអញ្ជើញឲ្យចូលសវនាការ

យើង **លី តារ៉ា** ព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងខេត្ត ពោធិ៍សាត់ ។

បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ ២៦០ ចុះថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០១៦ របស់សាលាដំបូងខេត្តពោធិ៍សាត់ ។

បានឃើញដីកាសម្រេចដាក់រឿងជំនុំជម្រះលេខ ........ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០១៨ របស់សាលាដំបូងខេត្តពោធិ៍សាត់ ។

អញ្ជើញលោក [redacted] ជានាយផ្នែកនគរបាលយុត្តិធម៌ ។

ឲ្យចូលទៅកាន់សាលាដំបូងខេត្តពោធិ៍សាត់ នៅថ្ងៃទី២៨ខែមិថុនា ឆ្នាំ២០១៨ វេលាម៉ោង ០៩ និង ០០ នាទីព្រឹក ជាកំហិត ដើម្បីចូលរួមសវនាការ ។

ពីដំណើររឿង ១-ឈ្មោះ [redacted] ភេទ ប្រុស អាយុ ២០ឆ្នាំ ២-ឈ្មោះ [redacted] ភេទ ប្រុស អាយុ ៨៨ឆ្នាំ ជាប់ចោទពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀនច្រើនដង, ចាត់ចែងឲ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀនច្រើនដង និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅឃុំអូរសោម ស្រុកវាលវែង ខេត្តពោធិ៍សាត់ កាលពីអំឡុងខែ មិថុនា ឆ្នាំ ២០១៦ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោស តាមមាត្រា៤០ កថាខណ្ឌទី៥ ចំណុចទី១ មាត្រា៤២ កថាខណ្ឌទី៣ ចំណុចទី១និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

### សមាសភាពជំនុំជម្រះ

| | |
|---|---|
| -លោកស្រី **រស់ ផូរ៉ា** | ប្រធានក្រុមប្រឹក្សាជំនុំជំរះ |
| -លោក **សុន នាថធាទី** | ចៅក្រុមប្រឹក្សា |
| -លោក **ម៉ៅ ស៊ីណា** | ចៅក្រុមប្រឹក្សា |
| -លោក **លី តារ៉ា** | តំណាងអយ្យការ |
| -លោក **ផុល ពិសិដ្ឋ** | ក្រឡាបញ្ជីសវនាការ |

ថ្ងៃ[illegible] ខែជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
ពោធិ៍សាត់ថ្ងៃទី[illegible] ខែ ឧសភា ឆ្នាំ ២០១៨

**ព្រះរាជអាជ្ញារង**

លី តារ៉ា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអម
សាលាដំបូងខេត្តពោធិ៍សាត់
លេខៈ ១៤០៧ ព.ឃ/១៥

# ដីកាកោះហៅជនចោទឱ្យចូលរួមសវនាការ

យើង **លី តារ៉ា** តំណាងអយ្យការអមសាលាដំបូងខេត្តពោធិ៍សាត់

-បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ: ២៨៦ ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៩។

-បានឃើញ ក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

-យោងដីកាសម្រេចបញ្ជូនរឿងជំនុំជម្រះ ៖ ២៩៦៨ ពស១២ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១២ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តពោធិ៍សាត់ដែលបានបញ្ជូនជនជាប់ចោទឈ្មោះ [redacted] ភេទប្រុស អាយុ ២៣ ឆ្នាំ (ក្រៅឃុំ) ទៅតុលាការព្រហ្មទណ្ឌនៃសាលាដំបូងខេត្តពោធិ៍សាត់ដើម្បីជំនុំជំរះពីបទ ៖ **រំលោភលើទំនុកចិត្ត** ប្រព្រឹត្តនៅភូមិចំការចេកខាងជើង សង្កាត់ផ្ទះព្រៃ ក្រុងពោធិ៍សត់ ខេត្តពោធិ៍សាត់ កាលពីថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០០៩ តាមមាត្រា ៤៦ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល។

អញ្ជើញឈ្មោះ [redacted] ភេទប្រុស អាយុ ៣១ ឆ្នាំ មានទីលំនៅបច្ចុប្បន្ននៅភូមិពោធិ៍តាគួយ សង្កាត់លលកស ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់។

ឱ្យចូលទៅកាន់ទីកន្លែងសាលសវនាការ នៃសាលាដំបូងខេត្តពោធិ៍សាត់ នៅថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៨ វេលាម៉ោង ៩៖០០ នាទីព្រឹកជាកំហិត ដើម្បីធ្វើការជំនុំជំរះ។

**ចៅក្រមជំនុំជំរះ**

-**លោកស្រី រស់ ផូរា** ចៅក្រមនៃសាលាដំបូងខេត្តពោធិ៍សាត់។

**តំណាងអយ្យការ**

-**លោក លី តារ៉ា** ជាព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងខេត្តពោធិ៍សាត់។

**ក្រឡាបញ្ជីសវនាការ**

-**លោក ថុល ពិសិដ្ឋ** ជាក្រឡាបញ្ជីនៃសាលាដំបូងខេត្តពោធិ៍សាត់។

ថ្ងៃ...[illegible]...ខែផល្គុន ឆ្នាំរកា ទព្វស័ក ព.ស ២៥៦១
ខេត្តពោធិ៍សាត់, ថ្ងៃទី ០១ ខែ មីនា ឆ្នាំ២០១៨

**តំណាងអយ្យការ**

លី តារ៉ា

យើង....................................បានប្រគល់ដីកាកោះនេះដល់
ឈ្មោះ.....................................................ទីលំនៅ
ភូមិ..................................
ឃុំ....................................
ស្រុក..............................ខេត្ត..................................
នៅថ្ងៃទី.....ខែ............ឆ្នាំ២០........ផ្ទាល់ដៃរួចហើយ។
ធ្វើនៅថ្ងៃទី............ខែ.................ឆ្នាំ២០.......................

**អ្នកទទួល** **អ្នកប្រគល់**

ខ-សមាសភាពក្រុមជំនុំជម្រះ

-លោកស្រី **រស់ ផូរា** ចៅក្រមជំនុំជំរះ

-លោក **ឆាយ ហុង** តំណាងអយ្យការ

-លោក **ឌុល ពិសិដ្ឋ** ក្រឡាបញ្ជីសវនាការ

គ-ឲ្យដំណឹងទៅជនជាប់ចោទពីសិទ្ធិរបស់ខ្លួន នៅចំពោះមុខតុលាការដូចតទៅ ៖

-សិទ្ធិទទួលដឹងពីដីកាសន្និដ្ឋានស្ថាពរ និង ដីកាកោះឲ្យចូលសវនាការ

-សិទ្ធិបង្ហាញភស្តុតាង សំអាងសាក្សី ឬ ធ្វើសំណូមពរផ្សេងៗ

-សិទ្ធិប្ដឹងជំទាស់ចិត្តចៅក្រមជំនុំជម្រះ

-សិទ្ធិការពារខ្លួនដោយខ្លួនឯង ឬ ពឹងឲ្យមេធាវីការពារខ្លួន

ពោធិ៍សាត់, ថ្ងៃទី០៦..ខែកក្កដា..ឆ្នាំ ២០១៧

**តំណាងអយ្យការ**

ឆាយ ហុង

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តពោធិ៍សាត់

## កំណត់ហេតុស្ដីពីការធ្វើសម្បថ

សំណុំរឿងព្រហ្មទណ្ឌលេខ..០៥.......ចុះថ្ងៃទី០៦..ខែ[illegible].....ឆ្នាំ២០១៧....។

ឆ្នាំពីរពាន់ដប់ប្រាំពីរ....ខែ[illegible]....ថ្ងៃទី[illegible]..វេលាម៉ោង[illegible].....និង[illegible]...។

យើង [redacted] ក្រឡាបញ្ជីអមសាលាដំបូងខេត្តពោធិ៍សាត់ បានដឹកនាំឱ្យឈ្មោះ [redacted]..........ភេទ[illegible].អាយុ.51..ឆ្នាំ សញ្ជាតិ.ខ្មែរ....សាសនា.ព្រះពុទ្ធ..មានទីលំនៅបច្ចុប្បន្ន នៅភូមិ[illegible]....ឃុំ/សង្កាត់.[illegible].......ស្រុក/ក្រុង[illegible]ខេត្ត[illegible]......មុខរបរ.[illegible]... ជា..[illegible]........ ធ្វើសច្ចាប្រណិធាន នៅចំពោះមុខវត្ថុស័ក្តិសិទ្ធិនៃសាលាដំបូងខេត្តពោធិ៍សាត់។

ក្រោយពីអ្នកស្បថបានអុជទៀន ធូប បូជាចំពោះមុខវត្ថុស័ក្តិសិទ្ធិរួចហើយ យើងបានអានប្រាប់ឮខ្លាំងៗ ច្បាស់ៗ ឱ្យអ្នកស្បថស្ដាប់ រួចអានពាក្យសច្ចាប្រណិធានឱ្យអ្នកស្បថថាតាមដែលមានសេចក្ដីដូចខាងក្រោម៖

ខ្ញុំសូមឆ្លើយតែការពិត ដែលខ្ញុំបានឃើញ បានឮ បានដឹង និងចាំផ្ទាល់។

បើខ្ញុំឆ្លើយមិនពិត ដោយប្រការណាមួយ សូមអស់ទេវតាព្រឹក្ស អារក្សអ្នកតា និងបារមីស័ក្តិសិទ្ធិទាំងអស់បរាមុខខ្ញុំ ឱ្យវិនាសលាញ អន្តរាយទ្រព្យសម្បត្តិ និងស្លាប់តែហោងយ៉ាងវេទនា តែបើខ្ញុំឆ្លើយពិតត្រង់ សូមទេវតាជួយឱ្យខ្ញុំ មានទ្រព្យសម្បត្តិហូរហៀរ និងរស់នៅប្រកបដោយមានសេចក្ដីសុខក្សេមក្សាន្ត ជួបជុំបងប្អូន កូនចៅ ញាតិផៅសណ្ដាន ជារៀងរហូតគ្រប់ជាតិ កុំបីរាកខានឡើយ។

ពាក្យសច្ចាប្រណិធានខាងលើនេះ ឈ្មោះ..[redacted]..............បានថាតាមយើងយ៉ាងច្បាស់ៗ គ្មានចន្លោះពាក្យត្រង់ណាមួយឡើយ។

បញ្ចប់កំណត់ហេតុនេះនៅវេលាម៉ោង[illegible].....ថ្ងៃ ខែ ឆ្នាំ ដដែលហើយបានអានឱ្យឈ្មោះខាងលើស្ដាប់ ឆ្លើយថាត្រឹមត្រូវ និងយល់ព្រមផ្ដិតមេដៃជាមួយយើង។

| | |
|---|---|
| **អ្នកស្បថ** | **ក្រឡាបញ្ជី** |
| [redacted] | ឌុល ពិសិដ្ឋ |

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តពោធិ៍សាត់

## បញ្ជីវត្តមានពេលសវនាការ

សំណុំរឿងព្រហ្មទណ្ឌលេខ ០៩ ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៧

| ល.រ | ឈ្មោះជនជាប់ទាក់ទិន | ត្រូវជា | ស្នាមមេដៃ ឬហត្ថលេខា |
|---|---|---|---|
| ០១ | [redacted] | ជនជាប់ចោទ | |
| ០២ | [redacted] | មេធាវី | [redacted] |
| ០៣ | [redacted] | មេធាវី | [illegible] |
| ០៤ | [redacted] | សាក្សី | [illegible] |
| ០៥ | [redacted] | សាក្សី | [illegible] |
| ០៦ | [redacted] | សាក្សី | |

ថ្ងៃ.[illegible]....ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស ២៥៦១

ពោធិ៍សាត់, ថ្ងៃទី២១..ខែកុម្ភៈ ឆ្នាំ២០១៨

ក្រឡាបញ្ជី

ជុល ពិសិដ្ឋ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តពោធិ៍សាត់**

សំណុំរឿងព្រហ្មទណ្ឌលេខ ៤០៥

ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៤

**សាលក្រមព្រហ្មទណ្ឌ**

**លេខៈ ១៧០ (ខ)**

ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៨

*តាងនាមប្រជារាស្ត្រខ្មែរ*

*សាលាដំបូងខេត្តពោធិ៍សាត់*

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៨ វេលាម៉ោង ពីរ និងសូន្យនាទីរសៀល។

ដោយមានសមាសភាពដូចខាងក្រោមៈ

**ចៅក្រមជំនុំជម្រះ**

-លោកស្រី **រស់ ផូរា** ចៅក្រមនៃសាលាដំបូងខេត្តពោធិ៍សាត់។

**តំណាងអយ្យការ**

-លោក **លី តារ៉ា** ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងខេត្តពោធិ៍សាត់។

**ក្រឡាបញ្ជីសវនាការ**

-លោក **ថុល ពិសិដ្ឋ** ក្រឡាបញ្ជីសវនាការនៃសាលាដំបូងខេត្តពោធិ៍សាត់។

ដើម្បីធ្វើការជំនុំជម្រះសំណុំរឿងព្រហ្មទណ្ឌលេខ ៤០៥ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៤ ដែលមានជនជាប់ចោទឈ្មោះ៖

-ឈ្មោះ [redacted] ភេទប្រុស អាយុ ២៥ ឆ្នាំ ជាតិខ្មែរ មុខរបរ កសិករ ទំលំនៅបច្ចុប្បន្នភូមិព្រៃដំរី ឃុំបឹងខ្នារ ស្រុកបាកាន ខេត្តពោធិ៍សាត់។

ត្រូវបានដាក់ឱ្យស្ថិតក្រោមការពិនិត្យពីបទ ហិង្សាដោយចេតនាដោយមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅភូមិព្រៃដំរី ឃុំបឹងខ្នារ ស្រុកបាកាន ខេត្តពោធិ៍សាត់ កាលពីថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៤ បទល្មើសព្រហ្មទណ្ឌ មានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២១៨ នៃក្រមព្រហ្មទណ្ឌ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ភេទស្រី អាយុ ៣៨ ឆ្នាំ រស់នៅភូមិព្រៃដំរី ឃុំបឹងខ្នារ ស្រុកបាកាន ខេត្តពោធិ៍សាត់។

**អង្គហេតុមានដូចតទៅ:**

កាលពីថ្ងៃទី៣១ ខែកក្កដា ឆ្នាំ ២០១៤ ឈ្មោះ [redacted] ភេទប្រុស អាយុ ២៥ ឆ្នាំ រស់នៅភូមិព្រៃដំរី ឃុំបឹងខ្នារ ស្រុកបាកាន ខេត្តពោធិ៍សាត់ បានឈ្លោះប្រកែកគ្នាជាមួយឈ្មោះ [redacted] ហើយ [redacted] ក៏បាន [redacted] ទៅវាយ លើឈ្មោះ [redacted] ជាច្រើនដៃហើយបន្ទាប់មកក៏បានអ្នកជិតខាងជួយចាប់បំបែក លុះម៉ោង ប្រហែលជា ៩

យប់ ពេលនោះឈ្មោះ [redacted] ដើរត្រលប់មកផ្ទះវិញក៏ស្រាប់តែឈ្មោះ [redacted] កាន់ដំបងមកវាយឈ្មោះ [redacted] ពីក្រោយត្រូវជាច្រើនដំបងបណ្តាលឱ្យបែកចក្ខើមខាងស្តាំហូរឈាម ហើយជនត្រូវចោទក៏បានរត់គេចខ្លួនបាត់។

**នាពេលសវនាការ**

-ក្រោយពីដំណើរការនៃកិច្ចពិភាក្សាដេញដោល

-ក្រោយពីបានស្តាប់អំណានចម្លើយដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់អំណានចម្លើយជនរងគ្រោះ

-ក្រោយពីបានស្តាប់អំណានចម្លើយសាក្សី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីបានពិនិត្យឯកសារដែលមាននៅក្នុងសំណុំរឿង

-ក្រោយពីបានពិនិត្យ និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ។

**<u>សាលាដំបូងខេត្តពោធិ៍សាត់ យល់ឃើញថា:</u>**

-អំពើប្រព្រឹត្តរបស់ជនជាប់ចោទឈ្មោះ [redacted] ភេទប្រុស អាយុ ២៥ឆ្នាំ ដែលបានប្រព្រឹត្តកាលពីថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៤ នៅភូមិព្រៃដំរី ឃុំបឹងខ្នារ ស្រុកបាកាន ខេត្តពោធិ៍សាត់ គឺជាអំពើហិង្សាស្រាលបំពានដោយចេតនាលើមាត្រា ២២៨ នៃក្រមព្រហ្មទណ្ឌ។

-តាមអំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] បានឆ្លើយថា: កាលពីថ្ងៃខែឆ្នាំមិនចាំ ឈ្មោះ [redacted] បានចូលមកលួចវាយប្តី ខ្លួនពីក្រោយបណ្តាលឱ្យបាក់ឆ្អឹងជំនី ពេលដែលគេវាយប្តីខ្លួនរួចហើយជននោះក៏រត់គេចខ្លួនបាត់។ ប៉ុន្តែសព្វថ្ងៃនេះ ឈ្មោះ [redacted] បានត្រលប់មករស់នៅផ្ទះរបស់គេវិញហើយស្ថិតនៅភូមិព្រៃដំរី ឃុំបឹងខ្នារ ស្រុកបាកាន ខេត្តពោធិ៍សាត់។ ខ្លួនបានចំណាយប្រាក់អស់ ៨.០០០.០០០ (ប្រាំបីលាន) រៀល ដើម្បីព្យាបាលប្តីរបស់ខ្លួនរហូតដល់ជាសះស្បើយ។

-តាមអំណានចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted] បានឆ្លើយថា: កាលពីថ្ងៃខែឆ្នាំមិនចាំ វេលាម៉ោង ០៧ យប់ ខ្លួនបានទៅយកថ្លៃមៀន ដែលទិញហើយភ្លេចយកនៅផ្ទះរបស់ឈ្មោះ [redacted] នៅភូមិជាមួយគ្នា ពេលដែលបានទៅដល់ក៏បានជួប នឹងឈ្មោះ [redacted] នៅទីនោះដែរ។ ស្រាប់តែឈ្មោះ [redacted] បានជេរថា "អាចុយម្រាយ អញវាយអាចុយម្រាយឥលូវ" ហើយខ្លួនក៏បានសួរវាថា "ហ្អែងជេរអាណា បើទីនេះមនុស្សចាស់មានតែអញហ្នឹង" ក៏បណ្តាលឱ្យទាស់សំដីគ្នា រួចឈ្មោះ [redacted] ក៏បានលោតមកវាយតប់លើខ្លួនជាច្រើនដៃ ខ្លួនក៏រត់ទៅផ្ទះឈ្មោះ [redacted] និងឈ្មោះ [redacted] ដែលនៅជិតគ្នា ពេលនោះឈ្មោះ [redacted] ក៏បានវាយខ្លួននឹងដំបងត្រូវឆ្អឹងជំនី បាក់ដំបងជាពីរកំណាត់ ខ្លួនមិនបានតបវិញទេ ព្រោះខ្លួនមិនដឹងខ្លួន។ សព្វថ្ងៃឈ្មោះ [redacted] រស់នៅភូមិព្រៃដំរី ឃុំបឹងខ្នារ ស្រុកបាកាន ខេត្តពោធិ៍សាត់។ បន្ទាប់ពីគេវាយខ្លួនបានដេកពេទ្យអស់រយៈពេល ០២ ខែ និងព្យាបាលអស់ប្រាក់ចំនួន ៨.០០០.០០០. (ប្រាំបីលាន) រៀល កន្លងមកខ្លួនមិនដែលមានទំនាស់គ្នាជាមួយឈ្មោះ [redacted] ទេ។

-តាមអំណានរបស់សាក្សីឈ្មោះ [redacted] បានឆ្លើយថា: កាលពីថ្ងៃ៣០ ខែកក្កដា ឆ្នាំ២០១៤ ពេលល្ងាច ឈ្មោះ [redacted] បានទិញថ្លៃមៀនហើយភ្លេចយកទៅផ្ទះ រហូតដល់ម៉ោង ០៩ យប់ ឈ្មោះ [redacted] ក៏បានមកយកវិញ។ ពេលនោះឈ្មោះ [redacted] និងឈ្មោះ [redacted] បានជិះម៉ូតូមកដល់ផ្ទះខ្លួន ដោយឈ្មោះ [redacted] បានទិញស្រាបៀមួយកំប៉ុងផឹក ពេលនោះក៏បានស្រែកជេរថា "អាចុយម្រាយ អញវាយហ្វែងចុយម្រាយឥឡូវ"ឈ្មោះ [redacted] លឺជេរក៏សួរថា "ហ្វែងជេរអ្នកណា" ឈ្មោះ [redacted] ក៏បានតបថា "ខ្ញុំជេរគ្នាខ្ញុំតើ" ពេលនោះអ្នកទាំងពីរឈ្លោះគ្នានៅមុខផ្ទះរបស់ខ្លួន ស្រាប់តែឈ្មោះ [redacted] បានរត់តាមមកពីក្រោយក៏បានវាយឈ្មោះ [redacted] ជាច្រើនដៃ ពេលនោះអ្នកស្រុកក៏ចេញមក ជួយចាប់បំបែកគ្នាចេញ។ បន្ទាប់មកឈ្មោះ [redacted] ក៏បានរត់ទៅត្បូងហើយបានត្រលប់មកវិញបានយកដំបងប៉ុនកំភួនដៃ វាយទៅលើឈ្មោះ [redacted] ចំនួន ០១ ដំបងហើយក៏រត់គេចទៅត្បូងបាត់ទៅ។

-តាមអំណានចម្លើយរបស់សាក្សីឈ្មោះ [redacted] បានឆ្លើយថា: កាលពីថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៤ វេលាប្រហែលជាម៉ោង ០៩ យប់ ខ្លួនកំពុងតែសម្រាកស្រាប់តែលឺសម្លេងឡូឡានៅមុខផ្ទះខ្លួន ពេលនោះខ្លួនក៏បានស្ទុះងើបហើយបានឃើញមនុស្សពីរនាក់កំពុងវាយគ្នា ខ្លួនក៏បានចុះទៅមើលស្រាប់តែឃើញឈ្មោះ [redacted] វាយគ្នាជាមួយឈ្មោះ [redacted] ដោយដៃ និងដៃ ហើយក៏មានអ្នកភូមិជួយបំបែកផងដែរ។ ពេលនោះឈ្មោះ [redacted] ក៏បានរត់ទៅត្បូងមួយសន្ទុះក្រោយមកស្រាប់តែឈ្មោះ [redacted] បានរត់មកវិញ ដោយមានដំបងកាន់នឹងដៃក៏បានវាយទៅលើឈ្មោះ [redacted] មួយដំបងហើយក៏បានរត់គេចខ្លួនបាត់ទៅ។

-លោកតំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំនាពេលសវនាការថា ក្រោយពីបានស្តាប់អំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សីនាពេលសវនាការរួចមកពិនិត្យឃើញថា ជនជាប់ចោទឈ្មោះ [redacted] ភេទប្រុស អាយុ ២៥ឆ្នាំ សញ្ជាតិខ្មែរ ទីលំនៅបច្ចុប្បន្ននៅភូមិព្រៃដំរី ឃុំបឹងខ្នារ ស្រុកបាកាន ខេត្តពោធិ៍សាត់ ពិតជាបាន ប្រព្រឹត្តអំពើហិង្សាដោយចេតនាដោយមានស្ថានទម្ងន់ទោស នៅភូមិព្រៃដំរី ឃុំបឹងខ្នារ ស្រុកបាកាន ខេត្តពោធិ៍សាត់ កាលពីថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៤ ពិតប្រាកដមែន ជាបទល្មើសដែលបញ្ញត្តិតាមមាត្រា២១៨ នៃក្រមព្រហ្មទណ្ឌ។ ដោយជនជនជាប់ចោទ ឈ្មោះ [redacted] ភេទប្រុស អាយុ ២៥ឆ្នាំ ជានីតិជន មានស្មារតី និងសមត្ថភាពគ្រប់គ្រាន់ ក្នុងការទទួលខុសត្រូវ ចំពោះអំពើរបស់ខ្លួនហើយមានចេតនាពិតប្រាកដក្នុងការប្រព្រឹត្តអំពើខាងលើ។ ម្យ៉ាងទៀត អំពើរបស់ជនជាប់ចោទពិតជាធ្វើឱ្យ ប៉ះពាល់ដល់សន្តិសុខ សណ្តាប់ធ្នាប់ របៀបរៀបរយសង្គម និងប៉ះពាល់ដល់បុគ្គលភាពរបស់អ្នកដទៃ។ ប៉ុន្តែដោយសារ ជនជាប់ចោទពុំមានអត្តសញ្ញាណគ្រប់គ្រប់គ្រាន់ តុលាការគួរធ្វើការស្វែងរកអត្តសញ្ញានជនជាប់ចោទឱ្យបានច្បាស់លាស់ជាមុនសិន មុននឹងធ្វើការផ្តន្ទាទោសជនជាប់ចោទទៅតាមច្បាប់។ ហេតុដូចនេះ តំណាងអយ្យការស្នើសុំឱ្យតុលាការសម្រេចចាត់របៀបដើម្បីស្រាវជ្រាវបំពេញអត្តសញ្ញាណរបស់ជនជាប់ចោទ។

## ហេតុដូច្នេះ សាលាដំបូងខេត្តពោធិ៍សាត់
## វិនិច្ឆ័យសេចក្តី

១. ចាត់របៀបដើម្បីស្រាវជ្រាវពីសាវតាជាតិរបស់ជនជាប់ចោទឈ្មោះ [redacted] ។

២. ចាត់តាំងលោកស្រី [redacted] ជាចៅក្រមស៊ើបសួរដើម្បីបំពេញកិច្ចស្រាវជ្រាវនេះ។

៣. លោកស្រី [redacted] ត្រូវធ្វើការស្រាវជ្រាវឱ្យបានលឿនបំផុតតាមដែលអាចធ្វើទៅបាន។

៤. សាលក្រមនេះជំនុំជម្រះនៅថ្ងៃ២៨ ខែកុម្ភៈ ឆ្នាំ២០១៨ និងប្រកាសជាសាធារណៈនៅថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៨ កំបាំងមុខជនជាប់ចោទ និងដើមបណ្ដឹងរដ្ឋប្បវេណី។

ក្រឡាបញ្ជី

ថុល ពិសិដ្ឋ

ចៅក្រមជំនុំជម្រះ

រស់_ផ្ទា

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តពោធិ៍សាត់**
សំណុំរឿងព្រហ្មទណ្ឌលេខ ១៤
ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០០២
**សាលក្រមព្រហ្មទណ្ឌ**
**លេខ: ១៧១ (ខ)**
ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៨

*តាងនាមប្រជារាស្ត្រខ្មែរ*

*សាលាដំបូងខេត្តពោធិ៍សាត់*

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៨

វេលាម៉ោងប្រាំបួនព្រឹក ដោយមានសមាសភាពៈ

**ចៅក្រមជំនុំជម្រះ**

-លោកស្រី **រស់ ផូវា** ចៅក្រមនៃសាលាដំបូងខេត្តពោធិ៍សាត់។

**តំណាងអយ្យការ**

-លោក **លី តារ៉ា** ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តពោធិ៍សាត់។

**ក្រឡាបញ្ជីសវនាការ**

-លោក **ថុល ពិសិដ្ឋ** ក្រឡាបញ្ជីនៃសាលាដំបូងខេត្តពោធិ៍សាត់។

ដើម្បីធ្វើការជំនុំជម្រះសំណុំរឿងព្រហ្មទណ្ឌលេខ ១៤ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០១២ ដែលមានជនជាប់ចោទឈ្មោះ៖

-ឈ្មោះ [redacted] ភេទប្រុស អាយុ ២៣ ឆ្នាំ ជាតិខ្មែរ ទីកន្លែងកំណើតភូមិចំការចេកខាងត្បូង ឃុំផ្ទះព្រៃ ស្រុកសំពៅមាស ខេត្តពោធិ៍សាត់ ទីលំនៅបច្ចុប្បន្ននៅភូមិចំការចេកខាងត្បូង សង្កាត់ផ្ទះព្រៃ ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់ ឪពុកឈ្មោះ [redacted] ម្តាយឈ្មោះ [redacted] ជានីតិជន ទោសពីមុន៖ គ្មាន។

-ឈ្មោះ [redacted] ភេទប្រុស អាយុ ២២ ឆ្នាំ ជាតិខ្មែរ ទីកន្លែងកំណើតភូមិពាលញែក១ ឃុំផ្ទះព្រៃ ស្រុកសំពៅមាស ខេត្តពោធិ៍សាត់ ទីលំនៅបច្ចុប្បន្ននៅភូមិពាលញែក១ សង្កាត់ផ្ទះព្រៃ ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់ មុខរបរ ជាងទូរស័ព្ទ ឪពុកឈ្មោះ [redacted] ម្តាយឈ្មោះ [redacted] ប្រពន្ធឈ្មោះ [redacted] ជានីតិជន ទោសពីមុន៖ គ្មាន។

ត្រូវបានដាក់ឲ្យស្ថិតក្រោមការពិនិត្យពីបទ ហិង្សាដោយចេតនា ប្រព្រឹត្តនៅភូមិពាលញែក១ សង្កាត់ផ្ទះព្រៃ ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់ កាលពីថ្ងៃទី០៩ ខែមករា ឆ្នាំ២០១២ បទល្មើសព្រហ្មទណ្ឌមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២១៧ នៃក្រមព្រហ្មទណ្ឌ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ភេទស្រី អាយុ ២៩ ឆ្នាំ មានទីលំនៅបច្ចុប្បន្ននៅភូមិចំការចេកខាងត្បូង សង្កាត់ផ្ទះព្រៃ ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់ និងឈ្មោះ [redacted] ភេទប្រុស អាយុ ៥១ ឆ្នាំ មានទីលំនៅបច្ចុប្បន្ន ភូមិពាលញែក១ សង្កាត់ផ្ទះព្រៃ ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់។

## អង្គហេតុមានដូចតទៅ:

កាលពីថ្ងៃទី០៩ ខែមករា ឆ្នាំ២០១២ វេលាម៉ោងប្រហែល ៦ ល្ងាចឈ្មោះ [redacted] កំពុងតែអង្គុយហូបពងទាកូននៅចំណុចឡានំប៉័ងផ្សារចាស់ក្នុងភូមិពាលញែក១ សង្កាត់ផ្ទះព្រៃ ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់ ស្រាប់តែមានឈ្មោះ [redacted] បានធ្វើសកម្មភាពវាយលើឈ្មោះ [redacted] ចំនួនពីរ ទៅបីដៃ និងចាប់ហែកអាវ ពេលនោះក៏មានអ្នកបំបែកចេញ ហើយក៏ត្រលប់ទៅផ្ទះរៀងខ្លួន។ លុះដល់ម៉ោងប្រហែល ៧ យប់ឈ្មោះ [redacted] កំពុងតែលេងប៊ូលនៅម្តុំបេនឡានផ្សារចាស់ ក៏មានគេមកប្រាប់ថាមានគេវាយប្អូនរបស់ខ្លួន ឈ្មោះ [redacted] ក៏បានទៅវាយឈ្មោះ [redacted] និងឈ្មោះ [redacted] ដោយអាយកូមបណ្តាលឲ្យមានរបួស រីឯឈ្មោះ [redacted] ក៏ត្រូវរបួសដែរ។

## នាពេលសវនាការ

ក្រោយពីដំណើរការនៃកិច្ចពិភាក្សាដេញដោល

ក្រោយពីបានស្តាប់អំណានចម្លើយជនជាប់ចោទ

ក្រោយពីបានស្តាប់អំណានចម្លើយដើមបណ្តឹងរដ្ឋប្បវេណី

ក្រោយពីបានស្តាប់អំណានចម្លើយសាក្សី

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

ក្រោយពីបានពិនិត្យឯកសារដែលមានក្នុងសំណុំរឿងចប់សព្វគ្រប់ហើយ

ក្រោយពីបានពិនិត្យ និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ។

## <u>យល់ឃើញថា:</u>

-អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] ភេទប្រុស អាយុ ២៣ ឆ្នាំ និងឈ្មោះ [redacted] ភេទប្រុស អាយុ ២២ ឆ្នាំ ដែលបានប្រព្រឹត្តនៅភូមិពាលញែក១ សង្កាត់ផ្ទះព្រៃ ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់ កាលពីថ្ងៃទី០៩ ខែមករា ឆ្នាំ២០១២ គឺជាអំពើហិង្សាស្រាល ដែលបំពានលើមាត្រា ២២៨ នៃក្រមព្រហ្មទណ្ឌ។

-តាមអំណានចម្លើយជនជាប់ចោទឈ្មោះ [redacted] បានឆ្លើយថា: កាលពីថ្ងៃទី០៩ ខែមករា ឆ្នាំ២០១២ វេលាម៉ោង ២ រសៀល ខ្លួនបានទៅលេងបុកប៊ីយ៉ាជាមួយឈ្មោះ [redacted] ក៏បានទាស់សំដីជាមួយគ្នា រួចក៏ទៅផ្ទះរៀងៗខ្លួន។ លុះម៉ោង ៧ យប់ខ្លួនបានទៅដើរលេង ក៏បានឃើញឈ្មោះ [redacted] កំពុងស៊ីពងទាកូន ខ្លួនក៏ដើរចូលទៅចាប់ក៏អាវ និងដាល់វាមួយដៃចំផ្ទៃមុខ រួចវាក៏ប្រតាយប្រតបជាមួយខ្លួនវិញ ហើយវាក៏ទៅផ្ទះ ចំណែកខ្លួនមិនបានទៅណាទេ។ មួយសន្ទុះក្រោយមកឈ្មោះ [redacted] ក៏បានមកដល់ហើយក៏បានទាស់សំដីជាមួយនឹងប្អូនប្រុសរបស់ខ្លួន ហើយបានប្រតាយប្រតបគ្នា ហើយខ្លួនក៏បានចូលទៅជួយ ម្តាយនិងបងស្រីខ្លួនក៏បានទៅជួយចាប់បំបែក។

ឈ្មោះ [redacted] បានយកអាយក្ងមក្រវាយចំក្បាលរបស់បងស្រីរបស់ខ្លួន ហើយសមត្ថកិច្ចមកដល់ក៏បានចាប់ពួកខ្លួនតែម្តង។

-តាមអំណានចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] បានឆ្លើយថា: នៅថ្ងៃទី០៩ ខែមករា ឆ្នាំ២០១២ វេលាម៉ោងប្រហែល ៦ ល្ងាច មានគេមកប្រាប់ខ្លួនថា គេវាយប្អូនរបស់ខ្លួនឈ្មោះ [redacted] នៅផ្ទះម៉ែ [redacted] ខ្លួនក៏ជិះម៉ូតូជាមួយឈ្មោះ [redacted] ពេលជិះទៅដល់មិនឃើញគេវាយគ្នាទេ ខ្លួនក៏អង្គុយនៅលើម៉ូតូ មួយសន្ទុះក្រោយមកឈ្មោះ [redacted] និងឈ្មោះ [redacted] បានដើរចូលមកវាយ ពេលនោះក៏មានការប្រតាយប្រតបគ្នា រួចក៏មានគេចូលមកបំបែក។ ពេលដែលកំពុងប្រតាយប្រតបជាមួយនឹងឈ្មោះ [redacted] ខ្លួនបានយកអាយក្ងមក្រវាយត្រូវក្បាលរបស់បងស្រីរបស់ឈ្មោះ [redacted]។

-តាមអំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted], ឈ្មោះ [redacted] និងសាក្សីឈ្មោះ [redacted] និងឈ្មោះ [redacted] បានឆ្លើយប្រហាក់ប្រហែលគ្នាថា ពិតជាមានករណីហិង្សាទៅវិញទៅមកពិតប្រាកដមែនដែលបង្កដោយឈ្មោះ [redacted] និងឈ្មោះ [redacted]។

-លោកតំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំ នាពេលសវនាការថា: ផ្អែងតាមកិច្ចពិភាក្សាដេញដោលបង្ហាញថា កាលពីថ្ងៃទី០៩ ខែមករា ឆ្នាំ២០១២ ពិតជាមានករណីហិង្សា ដែលបង្កដោយជនជាប់ចោទ ឈ្មោះ [redacted] ភេទប្រុស អាយុ ២៣ ឆ្នាំ និងឈ្មោះ [redacted] ភេទប្រុស អាយុ ២២ ឆ្នាំ ពិតប្រាកដមែន។ ចៅក្រមស៊ើបសួរបានចេញដីកាបញ្ជូនសំណុំរឿងទៅជំនុំជម្រះកាលពីថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១២ មកដល់ពេលនេះមានរយៈពេល ៦ ឆ្នាំហើយ ដែលសាលាដំបូងខេត្តពោធិ៍សាត់បើកសវនាការជំនុំជម្រះលើសំណុំរឿងនេះ ដោយបទល្មើសនេះជាបទល្មើសលហុ អាជ្ញាយុកាលនៃបទល្មើសមានរយៈពេល ១ ឆ្នាំ ដូច្នេះសំណុំរឿងនេះ ផុតអាជ្ញាយុកាលនៃបទល្មើសហើយ។ តំណាងអយ្យការ ស្នើសុំឱ្យចៅក្រមសម្រេចឱ្យជនជាប់ចោទរួចផុតពីបទចោទ តាមបញ្ញត្តិមាត្រា ១០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

-អាជ្ញាយុកាលនៃបទល្មើសដែលបានចោទប្រកាន់ខាងលើ បានកន្លងផុតទៅហើយ ហេតុដូច្នេះតុលាការ គប្បីសម្រេចឱ្យជនជាប់ចោទរួចផុតពីបទចោទ។

## ហេតុដូច្នេះ សាលាដំបូងខេត្តពោធិ៍សាត់
## វិនិច្ឆ័យសេចក្តី

១-ឱ្យជនជាប់ចោទ៖

-ឈ្មោះ [redacted] ភេទប្រុស អាយុ ២៣ ឆ្នាំ (មានអត្តសញ្ញាណដូចខាងលើ)

-និងឈ្មោះ [redacted] ភេទប្រុស អាយុ ២២ ឆ្នាំ (មានអត្តសញ្ញាណដូចខាងលើ) រួចផុតពីបទចោទ ពីបទហិង្សាស្រាល ប្រព្រឹត្តនៅភូមិពាលញែក១ សង្កាត់ផ្ទះព្រៃ ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់ កាលពីថ្ងៃទី០៩ ខែមករា ឆ្នាំ២០១២ បទល្មើសព្រហ្មទណ្ឌមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២២៨នៃក្រមព្រហ្មទណ្ឌ។

២-សាលក្រមនេះជំនុំជម្រះនៅថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៨ និងប្រកាសជាសាធារណៈនៅថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៨ ចំពោះមុខជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី ទុកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

ក្រឡាបញ្ជី

ថុល ពិសិដ្ឋ

ចៅក្រមជំនុំជម្រះ

ទស់-ផូរ៉ា

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តពោធិ៍សាត់**
សំណុំរឿងព្រហ្មទណ្ឌលេខ:២១០
ចុះថ្ងៃទី[illegible] ខែឧសភា ឆ្នាំ២០១៧
លេខ: [illegible]

## លិខិតជូនដំណឹងពីសាលក្រមកំបាំងមុខ

យើង **ថុល ពិសិដ្ឋ** ក្រឡាបញ្ជីសាលាដំបូងខេត្តពោធិ៍សាត់។

ប្រាប់មកឈ្មោះ [redacted] ហៅ [redacted] ភេទស្រី អាយុ ៣២ ឆ្នាំ ជនជាតិខ្មែរ ទីកន្លែងកំណើតនៅភូមិបឹងវាល ឃុំត្នោតជុំ ស្រុកក្រគរ ខេត្តពោធិ៍សាត់ ទីលំនៅបច្ចុប្បន្ននៅភូមិបឹងវាល ឃុំត្នោតជុំ ស្រុកក្រគរ ខេត្តពោធិ៍សាត់ មុខរបរ ធ្វើស្រែចំការ ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (រ) ប្តីឈ្មោះ [redacted] ហៅជា មានកូន ០៣ នាក់ ឲ្យដឹងថាតាមសាលក្រមកំបាំងមុខលេខ: ២៣៥ (ខ) ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ ២០១៧ របស់សាលាដំបូងខេត្តពោធិ៍សាត់ ដែលបានសម្រេចសេចក្តីដូចខាងក្រោម:

១. សម្រេចផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] ហៅ [redacted] ភេទស្រី អាយុ ៣២ ឆ្នាំ (មានអត្តសញ្ញាណដូចខាងលើ) ដោយពិន័យជាប្រាក់ចំនួន ១០០.០០០ (មួយសែន) រៀល តែទោសនេះត្រូវព្យួរ ពីបទ ជេរប្រមាថជាសាធារណៈ ប្រព្រឹត្តនៅភូមិបឹងវាល ឃុំត្នោតជុំ ស្រុកក្រគរ ខេត្តពោធិ៍សាត់ កាលពីថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣០៧ នៃក្រមព្រហ្មទណ្ឌ។

២. បង្គាប់ឲ្យជនជាប់ចោទឈ្មោះ [redacted] ហៅ [redacted] សងសំណងជម្ងឺចិត្តជាប្រាក់ចំនួន ៣.០០០.០០០ (បីលាន) រៀល ទៅឲ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ចាប់ពីពេលសាលក្រមចូលស្ថាពរ។

សាលក្រមនេះជំនុំជម្រះនៅថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៧ និងប្រកាសជាសាធារណៈនៅថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៧ កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] ហៅ [redacted] និងចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណី ទុកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

ថ្ងៃពុធ ៣រោច ខែពិសាខ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២
ពោធិ៍សាត់ ថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៨
**ក្រឡាបញ្ជីសវនាការ**

ថុល ពិសិដ្ឋ

ក្រឡាបញ្ជី ថុល ពិសិដ្ឋ
លេខទូរស័ព្ទ៖ ០៩៧ ៣១៧ ៤២៣៥

យើង [illegible]

បានប្រគល់លិខិតជូនដំណឹងនេះឲ្យឈ្មោះ [redacted] [illegible] [redacted]

ទីលំនៅបច្ចុប្បន្ននៅភូមិ [illegible] ឃុំ/សង្កាត់ [illegible]

ស្រុក/ខណ្ឌ [illegible] ខេត្ត/ក្រុង [illegible]

នៅថ្ងៃទី ០២ ខែ ០៥ ឆ្នាំ ២០១៩ ផ្ទាល់រួចហើយ ហើយប្រាប់ថាបើមិនសុខចិត្តនិងដីកាសម្រេចនេះទេ ត្រូវចូលប្ដឹងទាស់ និងប្ដឹងឧទ្ធរណ៍តាមកំណត់ច្បាប់ឲ្យបានទាន់ពេលវេលា។

| អ្នកទទួលលិខិត<br>ហត្ថលេខា ឬស្នាមមេដៃ | អ្នកប្រគល់<br>ហត្ថលេខា ឬស្នាមមេដៃ |
| --- | --- |

ក្រឡាបញ្ជី ជុល ពិសិដ្ឋ

លេខទូរស័ព្ទ៖ ០៩៧ ៣១៧ ៤២៣៥